## ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រស្ដីអំពី
## ផលប៉ះពាល់ផ្នែកបរិស្ថានរបស់ទំនប់វារីអគ្គិសនី
## តាមដងទន្លេមេនៃទន្លេមេគង្គ





# សេចក្ដីសង្ខេប

# នៃរបាយការណ៍ចុងក្រោយ





រៀបចំសម្រាប់

គណៈកម្មការទន្លេមេគង្គ

*ដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន*

ខែ តុលា ឆ្នាំ ២០១០









**សេចក្តីប្រកាសបដិសេធ**

ឯកសារនេះ ត្រូវបានរៀបរៀងឡើងដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន សម្រាប់លេខាធិការដ្ឋានគណៈកម្មាការទន្លេមេគង្គ ដោយមានគោលបំណងសម្រួលដល់ការរៀបចំការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថានរបស់គម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម។

ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានធ្វើឡើងដោយមានកិច្ចសហប្រតិបត្តិការរវាងលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ គណៈកម្មាធិការជាតិទន្លេមេគង្គរបស់ប្រទេសទាំងបួន រួមទាំងសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត។ ឯកសារនេះត្រូវបានរៀបរៀងឡើងដោយក្រុមជំនាញការមួយក្រុម សម្រាប់ជាជំនួយដល់ផ្នែកមួយនៃសកម្មភាពប្រមូលព័ត៌មានរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។ គំនិតយោបល់ ការសន្និដ្ឋាន និងអនុសាសន៍ទាំងអស់ក្នុងឯកសារនេះ មិនមែនជាគំនិតយោបល់របស់គណៈកម្មការទន្លេមេគង្គឡើយ។ រាល់គំនិតយោបល់ ការសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មការទន្លេមេគង្គនឹងមានបញ្ជាក់យ៉ាងច្បាស់នៅក្នុងរបាយការណ៍របស់គណៈកម្មការទន្លេមេគង្គតែប៉ុណ្ណោះ។

សម្រាប់ព័ត៌មានបន្ថែមស្តីអំពីគំនិតផ្តួចផ្តើមរបស់គណៈកម្មការទន្លេមេគង្គពាក់ព័ន្ធនឹងការសាងសង់ទំនប់វារីអគ្គីសនីប្រកបដោយចីរភាព និងការអនុវត្តការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រស្តីអំពីផលប៉ះពាល់ផ្នែកបរិស្ថាន របស់សំណើគម្រោងអភិវឌ្ឍន៍ សូមមើលគេហទំព័ររបស់គណៈកម្មការទន្លេមេគង្គ:

http://www.mrcmekong.org/ish/ish.htm និង http://www.mrcmekong.org/ish/SEA.htm

គោលជំហររបស់គណៈកម្មការទន្លេមេគង្គទៅលើការអភិវឌ្ឍវារីអគ្គិសនីតាមដងទន្លេមេគង្គ មានបញ្ជាក់ជូននៅលើគេហទំព័ររបស់គណៈកម្មការទន្លេមេគង្គ ឆ្នាំ២០០៩។

**គោលជំហររបស់គណៈកម្មការទន្លេមេគង្គ លើសំណើគម្រោងសាងសង់ទំនប់វារីអគ្គិសនីតាមដងទន្លេមេនៃអាងទន្លេមេគង្គក្រោម**

*គម្រោងសាងសង់ទំនប់វារីអគ្គីសនីចំនួន ១២ នៅតាមដងទន្លេមេនៃអាងទន្លេមេគង្គក្រោម កំពុងស្ថិតក្រោមការសិក្សារបស់ក្រុមហ៊ុនសាងសង់ឯកជន។ យោងតាមកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ បញ្ជាក់ថា រាល់គម្រោងអភិវឌ្ឍន៍ប្រភេទនេះ ត្រូវធ្វើការពិភាក្សាឱ្យបានទូលំទូលាយ ក្នុងចំណោមប្រទេសទាំងបួនមុននឹងឈានដល់ការសម្រេចណាមួយ។ ដោយមានការសម្របសម្រួលរបស់គណៈកម្មការទន្លេមេគង្គ ការពិភាក្សានេះត្រូវធ្វើការពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយលើផលប៉ះពាល់ផ្នែកសង្គម បរិស្ថាន និងការអភិវឌ្ឍអន្តរវិស័យក្នុងអាងទន្លេមេគង្គ។ រហូតមកដល់ពេលនេះ មានគម្រោងនៅតាមទន្លេមេនៃទន្លេមេគង្គចំនួន ១ បានឈានដល់ដំណាក់កាលជូនដំណឹង និងការពិគ្រោះយោបល់ជាមុន ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គ ឆ្នាំ ១៩៩៥។ ទាក់ទីននឹងគម្រោងស្នើសុំនេះ គណៈកម្មការទន្លេមេគង្គបានរៀបចំរួចហើយនូវការសិក្សាទូលំទូលាយលើផលប៉ះពាល់នៃគម្រោងទៅលើវិស័យជលផល និងជីវភាពរស់នៅរបស់ប្រជាជន ហើយព័ត៌មាននេះគឺបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ឧទាហរណ៍ ដូចជារបាយការណ៍កិច្ចប្រជុំក្រុមអ្នកឯកទេសលើបញ្ហាទំនប់វារីអគ្គិសនី និងវិស័យជលផលជាដើម។ នាពេលនេះ គណៈកម្មការទន្លេមេគង្គកំពុងរៀបចំការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រស្តីអំពីផលប៉ះពាល់ផ្នែកបរិស្ថានរបស់គម្រោងសាងសង់ទំនប់តាមទន្លេមេនៃទន្លេមេគង្គ ក្នុងគោលបំណងស្វែងយល់ឱ្យបានកាន់តែទូលំទូលាយពីកាលានុវត្តភាព និងហានិភ័យនៃគម្រោងអភិវឌ្ឍន៍ទាំងនេះ។ នាពេលបច្ចុប្បន្ន ដោយមានការសម្របសម្រួលរបស់គណៈកម្មការទន្លេមេគង្គ ការពិភាក្សាអំពីគម្រោងស្នើសុំកំពុងតែដំណើរការជាមួយស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ហើយរាល់យោបល់ទាំងអស់ កំពុងត្រូវបានគេយកមកពិចារណា។*

| | |
|---|---|
| រៀបរៀងដោយ : | មជ្ឈមណ្ឌលអន្តរជាតិ សម្រាប់ការគ្រប់គ្រងបរិស្ថាន ប្រទេសអូស្ត្រាលី |
| រៀបរៀងសម្រាប់ : | គណៈកម្មការទន្លេមេគង្គ |
| កម្មសិទ្ធ : | គណៈកម្មការទន្លេមេគង្គ |
| ការដកស្រង់ : | ICEM, 2010, *MRC Strategic Environmental Assessment (SEA) of hydropower on the Mekong mainstream: summary of the final report*, Hanoi, Viet Nam. |
| ព័ត៌មានបន្ថែម | www.icem.com.au \| http://www.mrcmekong.org/ish/SEA.htm<br>មជ្ឈមណ្ឌលអន្តរជាតិ សម្រាប់ការគ្រប់គ្រងបរិស្ថាន ប្រទេសអូស្ត្រាលី<br>14A Wallis Avenue,<br>Glen Iris, Victoria 3146,<br>Australia |
| រូបភាពគម្រប : | គណៈកម្មការទន្លេមេគង្គ ឆ្នាំ ២០១០<br>Zeb Hogan, 2009<br>Peter-John Meynell, 2010<br>Peter Ward, 2003 |

## ព័ត៌មានអំពីការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន របស់គម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គ

គណៈកម្មការទន្លេមេគង្គ គឺជាអង្គការទន្លេអន្តររដ្ឋាភិបាល ដែលផ្តល់ក្របខ័ណ្ឌស្ថាប័នថ្នាក់តំបន់ ក្នុងការអនុវត្តកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ សម្រាប់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ក្នុងអាងទន្លេមេគង្គ។ រដ្ឋាភិបាលប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គនេះ។ ប្រទេសទាំងបួន បានព្រមព្រៀងគ្នាលើការគ្រប់គ្រងរួមគ្នាលើធនធានទឹករួមរបស់ខ្លួន តាមរយៈការធ្វើកិច្ចសហការក្នុងឥរិយាបទផ្តល់ប្រយោជន៍ដល់គ្នាទៅវិញទៅមក និងប្រកបដោយស្មារតីស្ថាបនា ការអភិវឌ្ឍ ការប្រើប្រាស់ ការអភិរក្ស និងការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃធនធានទឹក និងធនធានដែលពាក់ព័ន្ធនឹងទន្លេមេគង្គ។

ការកាត់បន្ថយភាពក្រីក្រ ដែលជាការចូលរួមចំណែកដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ ក៏ជាអាទិភាពមួយក្នុងកិច្ចព្រមព្រៀងនេះផងដែរ។ លើសពីនេះ ប្រទេសដែលស្ថិតនៅផ្នែកខាងលើនៃអាងទន្លេមេគង្គ រួមមានសាធារណរដ្ឋប្រជាមានិតចិន និងសហភាពមីយ៉ាន់ម៉ា គឺជាដៃគូពិភាក្សារបស់គណៈកម្មការទន្លេមេគង្គ។

ដោយសារការលូតលាស់ផ្នែកសេដ្ឋកិច្ច និងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងតំបន់ គណៈកម្មការទន្លេមេគង្គយល់ឃើញថា ការអភិវឌ្ឍវារីអគ្គិសនីនៅតាមដងទន្លេមេគង្គ គឺជាបញ្ហាប្រឈមជាយុទ្ធសាស្ត្រសំខាន់បំផុតមួយសម្រាប់តំបន់ទន្លេមេគង្គក្រោម។ តាមរយៈចំណេះដឹងដែលទទួលបានពីកម្មវិធីរបស់ខ្លួនទាំងអស់ គណៈកម្មការទន្លេមេគង្គ បានរៀបចំអោយមានការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ដើម្បីជួយដល់ប្រទេសជាសមាជិកធ្វើការរួមគ្នា និងធ្វើការសម្រេចចិត្តដ៏ល្អបំផុតសម្រាប់អាងទន្លេមេគង្គ។

គម្រោងវារីអគ្គិសនីចំនួន ១២ ដែលបានស្នើឡើងតាមទន្លេមេនៃទន្លេមេគង្គ គឺស្ថិតក្នុងប្រទេសឡាវ នៅតាមព្រំដែនឡាវ-ថៃ និងនៅប្រទេសកម្ពុជា។ ការអនុវត្តគម្រោងណាមួយដែលត្រូវបានស្នើឡើង ឬក៏ការអនុវត្តគម្រោងទាំងអស់ នៅតាមអាងទន្លេមេគង្គក្រោម អាចមានផលប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចសង្គម និងបរិស្ថានរបស់ប្រទេសទាំង ៤ ដែលនៅជាប់តាមដងទន្លេ។

ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាននេះ ត្រូវបានរៀបចំធ្វើឡើង ក្នុងគោលបំណងកំណត់កាលានុវត្តភាព និងហានិភ័យ ក៏ដូចជាការចូលរួមរបស់គម្រោងដែលបានស្នើឡើងទាំងនេះ ក្នុងការអភិវឌ្ឍថ្នាក់តំបន់ ដោយមានការវាយតម្លៃជម្រើសជាយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍវារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ។ ពិសេសជាងនេះទៅទៀត ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ផ្តោតសំខាន់លើការបែងចែកគ្នានូវការខាតបង់ និងអត្ថប្រយោជន៍ក៏រិតតំបន់ ដោយគិតជាពិសេសទៅលើការអភិវឌ្ឍសេដ្ឋកិច្ចទៅលើសមភាពសង្គម និងទៅលើការការពារបរិស្ថាន។ ក្នុងន័យនេះ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពី

ផលប៉ះពាល់ផ្នែកបរិស្ថាន គាំទ្រដល់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍ថ្នាក់អាងទន្លេឱ្យកាន់តែធំ ដោយដាក់បន្ថែមនូវការប៉ាន់ប្រមាណអំពីសេណារីយ៉ូសំរាប់ការអភិវឌ្ឍនៅទូទាំងអាងទន្លេមេគង្គទាំងមូលរបស់គណៈកម្មាការទន្លេមេគង្គស្តីអំពីការរៀបចំអភិវឌ្ឍន៍អាងទន្លេឱ្យបានទូលំទូលាយ ដោយវិភាគឱ្យកាន់តែស៊ីជម្រៅថែមទៀតអំពីកាលានុវត្តភាពនៃការអភិវឌ្ឍថាមពល និងការអភិវឌ្ឍអន្តរវិស័យ ព្រមទាំងប៉ាន់ប្រមាណអំពីហានិភ័យរបស់គម្រោងអភិវឌ្ឍន៍វារីអគ្គិសនីនៅតាមទន្លេមេដែលត្រូវបានស្នើឡើងនៅតាមអាងទន្លេមេគង្គក្រោមនេះ។

ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ត្រូវបានសម្របសម្រួលរៀបចំដោយកម្មវិធីគំនិតផ្តួចផ្តើមអំពីការអភិវឌ្ឍវារីអគ្គិសនីដោយនិរន្តរភាព ដែលជាគំនិតផ្តួចផ្តើមមួយមានលក្ខណៈជាប់ពាក់ព័ន្ធគ្នា និងធ្វើការសហការជាមួយនឹងកម្មវិធីការងារដទៃៗទៀតរបស់គណៈកម្មការទន្លេមេគង្គ។ លើសពីនេះទៀត ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន លើកកម្ពស់ព័ត៌មានជាមូលដ្ឋាន និងក្របខ័ណ្ឌវាយតម្លៃសម្រាប់ការពិនិត្យឡើងវិញរបស់រដ្ឋាភិបាលនៃប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ ទៅលើការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថានរបស់គម្រោងនីមួយៗ ដែលក្រុមហ៊ុនសាងសង់ដាក់បញ្ជូនមកប្រទេសមាជិកគណៈកម្មការទន្លេមេគង្គ តាមរយៈលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាននេះ ទៀតសោត ក៏ផ្តល់ជាព័ត៌មានអំពីមធ្យោបាយដ៏ល្អបំផុតសម្រាប់គណៈកម្មការទន្លេមេគង្គ ក្នុងការលើកកម្ពស់ការគាំទ្ររបស់ខ្លួនដល់ប្រទេសជាសមាជិក នៅពេលដែលគេចាប់ផ្តើមដំណើរការជាផ្លូវការនៃការពិគ្រោះយោបល់ជាមុន ទៅលើសំណើគម្រោងសាងសង់វារីអគ្គិសនីណាមួយនៅតាមទន្លេមេនៃទន្លេមេគង្គ (ដូចជា នីតិវិធីសំរាប់ជូនដំណឹងការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង)។ លើសពីនេះទៀត លទ្ធផលរកឃើញដែលទទួលបានពីការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ក៏បានផ្តល់ជាគំនិតសម្រាប់គណៈកម្មការទន្លេមេគង្គធ្វើការពិចារណាលើវដ្តផែនការយុទ្ធសាស្ត្រជំហានបន្ទាប់របស់ខ្លួន (២០១១-២០១៥)ផងដែរ។ ទន្ទឹមនឹងនោះ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ក៏ជួយជាដំណោះស្រាយចំពោះបញ្ហាកង្វះចំណេះដឹង និងភាពមិនប្រាកដប្រជា តាមវិស័យមួយចំនួន ក៏ដូចជាហានិភ័យពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ ដែលត្រូវបានស្នើឡើងនៅតាមទន្លេមេនៃទន្លេមេគង្គ។

ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានចាប់ផ្តើមក្នុងខែមិថុនា ឆ្នាំ២០០៩ ហើយបានបញ្ចប់ក្នុងរយៈពេល ១៦ខែក្រោយមក ដោយចេញផ្សាយរបាយការណ៍បញ្ចប់ និងអនុសាសន៍ នៅក្នុងខែកញ្ញា ឆ្នាំ២០១០។ ឯកសារនេះ គឺជាឯកសារចុងក្រោយក្នុងចំណោមឯកសារមួយចំនួនដែលបានមកពី

*កម្មវិធីពិគ្រោះយោបល់យ៉ាងទូលំទូលាយរៀបចំឡើងនៅតាមប្រទេសអាងទន្លេមេគង្គក្រោម និងដោយមានការវិភាគលម្អិតដោយអ្នកឯកទេស ទាក់ទងនឹងការអភិវឌ្ឍវារីអគ្គិសនីនៅតាមដងទន្លេមេគង្គ។ ឯកសារនៃការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ត្រូវបានផ្សព្វផ្សាយជាបន្តបន្ទាប់ជាសាធារណៈ និងមានការពិនិត្យឡើងវិញ ដោយមានការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យអ្នកពាក់ព័ន្ធអាចចូលរួមចំណែកក្នុងការប៉ាន់ប្រមាណអំពីផលប៉ះពាល់ផ្នែកបរិស្ថានរបស់គម្រោងវារីអគ្គិសនីដែលគេស្នើឡើងប្រកបដោយអត្ថន័យ។ ចំពោះបញ្ជីពេញលេញរបស់ឯកសារ គឺអាចរកបាននៅលើគេហទំព័ររបស់គណៈកម្មការទន្លេមេគង្គដែលនិយាយអំពីការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន។*

## ក្រុមការងារធ្វើការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថានរួមមាន៖

*មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន*

| | | |
|---|---|---|
| បណ្ឌិត | Jeremy Carew-Reid | ប្រធានក្រុម និងជាអ្នកឯកទេសខាងការប្រែប្រួលអាកាសធាតុ |
| លោក | Peter-John Meynell | អ្នកឯកទេសប្រព័ន្ធធម្មជាតិ និងប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន |
| បណ្ឌិត | Eric Baran | អ្នកឯកទេសជលផល (មជ្ឈមណ្ឌល WorldFish) |
| បណ្ឌិត | Elizabeth Mann | អ្នកឯកទេសប្រព័ន្ធសង្គម |
| សាស្ត្រាចារ្យ | Peter Ward | វិស្វករវារីអគ្គិសនី និងអ្នកឯកទេសខាងមូលដ្ឋានធារាសាស្ត្រ |
| លោក | John Sawdon | អ្នកឯកទេសខាងសេដ្ឋកិច្ច និងសង្គម |
| បណ្ឌិត | Benoit LaPlante | អ្នកឯកទេសខាងសេដ្ឋកិច្ចបរិស្ថាន |
| បណ្ឌិត | Carlos Yermoli | អ្នកឯកទេសខាងវិស័យថាមពល |
| លោក | Cong An Tranh | អ្នកឯកទេសខាងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| លោក | Tarek Ketelsen | អ្នកសម្របសម្រួលគម្រោង និងអ្នកឯកទេសខាងធារាសាស្ត្រ |
| | | |
| បណ្ឌិត | Apichart Annukalumphai | ប្រធានក្រុមថៃ និងវិស្វករធនធានទឹក |
| បណ្ឌិត | Suppakorn Chinnarvo | អ្នកឯកទេសខាងសេដ្ឋកិច្ចសង្គមមកពីប្រទេសថៃ ( SEA START) |
| បណ្ឌិត | Kanokwan Manoram | អ្នកឯកទេសខាងជីវភាពរស់នៅ (MSSRC) |
| អ្នកនាង | Piyathip Eawpanich | អ្នកសម្របសម្រួលមកពីប្រទេសថៃ |
| | | |
| បណ្ឌិត | Nguyen Huu Thien | ប្រធានក្រុមវៀតណាម និងអ្នកឯកទេសខាងប្រព័ន្ធតំបន់ដីសើម |
| បណ្ឌិត | Nguyen Xuan Nguyen | អ្នកឯកទេសខាងប្រព័ន្ធសេដ្ឋកិច្ចមកពីប្រទេសវៀតណាម |
| បណ្ឌិត | Nguyen Van San | អ្នកឯកទេសប្រព័ន្ធលើដីមកពីប្រទេសវៀតណាម |
| អ្នកនាង | Nguyen Thi Nga | អ្នកសម្របសម្រួលមកពីប្រទេសវៀតណាម |
| | | |
| លោក | Meng Monyrak | ប្រធានក្រុមមកពីប្រទេសកម្ពុជា និងអ្នកឯកទេសខាងប្រព័ន្ធអេកូឡូស៊ីទឹក |
| លោក | Try Thuon | អ្នកឯកទេសខាងជីវភាពរស់នៅមកពីប្រទេសកម្ពុជា |

| | | |
|---|---|---|
| លោក | Phaknakhone Rattana | ប្រធានក្រុមមកពីប្រទេសឡាវ<br>និងអ្នកឯកទេសខាងហេដ្ឋារចនាសម្ព័ន្ធ |
| លោក | Sae Senpaty | អ្នកស្រាវជ្រាវខាងជីវភាពរស់នៅមកពីប្រទេសឡាវ |
| លោក | Bonheung Phantasith | អ្នកឯកទេសប្រព័ន្ធធម្មជាតិមកពីប្រទេសឡាវ |

ក្រុមជំនាញការធ្វើការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន សូមថ្លែងអំណរគុណចំពោះការគាំទ្រយ៉ាងសកម្មពីសំណាក់ស្ថាប័ន ជាង ១០០ មកពីស្ថាប័នរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល និងអង្គការនានាមកពីប្រទេសទន្លេមេគង្គក្រោម។ ការប្រឹងប្រែងរបស់អ្នកទាំងនោះក្នុងការផ្តល់ព័ត៌មាន ការកំណត់វិសាលភាពនៃការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន និងការពិនិត្យឡើងវិញនូវរបាយការណ៍រីកចំរើនពិតជាមានសារៈសំខាន់ចំពោះភាពជោគជ័យនៃដំណើរការប៉ាន់ប្រមាណរយៈពេល ១៦ ខែ នេះ។

ពិសេសជាងនេះទៅទៀត ក្រុមជំនាញការធ្វើការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថានក៏សូមសំដែងនូវអំណរគុណចំពោះការគាំទ្ររបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ឡាវ ថៃ និងវៀតណាមចំពោះការប្រឹងប្រែងក្នុងការសម្របសម្រួលការពិគ្រោះយោបល់ ហើយនិងអរគុណចំពោះកម្មវិធីបច្ចេកទេសរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គចំពោះការផ្តល់ធនធាន និងព័ត៌មានដែលមានក្នុងលេខាធិការដ្ឋាន ដល់ក្រុមជំនាញការធ្វើការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន។

ការថ្លែងអំណរគុណជាពិសេស ចំពោះកម្មវិធីគំនិតផ្តួចផ្តើមស្តីអំពីការអភិវឌ្ឍវារីអគ្គីសនីប្រកបដោយនិរន្តរភាព ដែលដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលការងារប៉ាន់ប្រមាណនៅក្នុងលេខាធិការដ្ឋានទន្លេមេគង្គ និងក៏រិតគណៈកម្មការទន្លេមេគង្គ ព្រមទាំងជួយសម្របសម្រួលក្នុងដំណើរការជួបជាមួយនឹងភាគីផ្សេងៗទៀតដែលពាក់ព័ន្ធជាមួយនឹងគណៈកម្មការទន្លេមេគង្គ។



## សេចក្តីសង្ខេប

ទន្លេមេគង្គ គឺទន្លេមួយដែលវែងបំផុតចុងក្រោយបង្អស់នៅលើភពផែនដី ដែលមិនទាន់មានការសាងសង់ទំនប់នៅតាមបណ្តោយភាគច្រើននៃទន្លេមេ។ ទន្លេមេគង្គ ក៏ជាទន្លេតែមួយគត់ ដែលមានទឹកហូរដោយសេរីចូលទៅក្នុងសមុទ្រ ដោយហូរកាត់តាមប្រទេសចំនួនប្រាំ ក្នុងចំណោមប្រទេសចំនួនប្រាំមួយ ដែលរួមមានសហភាពមីយ៉ាន់មា ប្រទេសឡាវ ថៃ កម្ពុជា និងវៀតណាម។ ប្រទេសចិន បានសាងសង់ទំនប់ចំនួនបួនដំបូងនៅក្នុងចំណោមគម្រោងវារីអគ្គិសនីទាំង ៨ ដែលចិនបានគ្រោងសាងសង់[១]។ ចាប់តាំងពីឆ្នាំ ២០០៦ មក ចំណាប់អារម្មណ៍ក្នុងការសាងសង់វារីអគ្គិសនីក្នុងតាមអាងទន្លេមេគង្គក្រោម មានការកើនឡើង ស្របពេលជាមួយនឹងកំណើនវិនិយោគវិស័យឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធថាមពល។ នៅតាមដៃទន្លេមេគង្គភាគច្រើនមានទំនប់ជាច្រើនដែលត្រូវបានសាងសង់រួច ឬក៏មានផែនការសាងសង់ ដែលក្នុងនោះមានគម្រោងចំនួន ៧១ ត្រូវគេរំពឹងថានឹងត្រូវសាងសង់ឡើងនៅត្រឹមឆ្នាំ២០៣០។ នៅក្នុងរយៈពេលប៉ុន្មាន ២-៣ឆ្នាំចុងក្រោយនេះ វិនិយោគិននិងក្រុមហ៊ុនសាងសង់ភាគច្រើនមកពីប្រទេសចិន ម៉ាឡេស៊ី ថៃ និងវៀតណាម បានដាក់សំណើគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីចំនួន ១២ នៅតាមទន្លេមេនៃអាងទន្លេគេង្គក្រោម ដោយផ្អែកលើទស្សនទានអភិវឌ្ឍន៍ពីទសវត្សរ៍មុនៗ (សូមមើលគំនូសតាងទី១)[២]។ សំណើគម្រោងទាំងនោះ គឺជាការអភិវឌ្ឍដែលធំ និងមានសារៈសំខាន់បំផុត ដែលប្រទេសទន្លេមេគង្គក្រោមមិនធ្លាប់បានសាងសង់កន្លងមកនៅលើអាងទន្លេមេគង្គ។

គម្រោងតាមទន្លេមេនៃទន្លេមេគង្គដែលបានស្នើឡើងចំនួន ១០ នឹងពាក់ព័ន្ធដល់ការសាងសង់ទំនប់កាត់ប្រព័ន្ធទន្លេទាំងមូល ដែលក្នុងនោះមានគម្រោងចំនួន ៨ ស្ថិតនៅក្នុងប្រទេសឡាវ។ គម្រោងចំនួន ២ ស្ថិតនៅតាមព្រំប្រទល់ឡាវ និងថៃ និងគម្រោងចំនួន ២ ទៀត ស្ថិតនៅក្នុងប្រទេសកម្ពុជា។ គម្រោងចំនួន ២ ដែលស្ថិតនៅជិតល្បាក់ខោនក្នុងប្រទេសឡាវ ជាគម្រោងទំនប់វារីអគ្គិសនីនៅតាមផ្នែកខ្លះនៃទន្លេ (គម្រោងទំនប់ដន សាហុង)

---

[១] តាមព័ត៌មានថ្មីចុងក្រោយអោយដឹងថា គម្រោងសាងសង់ទំនប់ម៉េង សុង ដែលស្ថិតនៅខាងក្រោមគេបំផុតនៃគំរោងវារីអគ្គិសនីទាំង ៨ នៅតាមទន្លេមេគង្គលើប្រទេសចិន ត្រូវបានពន្យារពេលដោយមិនមានការកំណត់កាលបរិច្ឆេទការសាងសង់ជាក់លាក់ឡើយ។

[២] គម្រោង ១១ ក្នុងចំណោមគម្រោងវារីអគ្គិសនី ១២ នៅអាងទន្លេមេគង្គក្រោម ផ្អែកលើការរៀបចំសិក្សាពីលទ្ធភាព នៅដំណាក់កាលដំបូង ដែលរៀបចំឡើងដោយលេខាធិការដ្ឋានគណៈកម្មការធិការទន្លេមេគង្គ ក្នុងឆ្នាំ១៩៩៤ ហើយនិងយកតាមទស្សនទានពីមុនៗរបស់គម្រោងវារីអគ្គីសនីតាមដៃទន្លេមេគង្គ ដែលបានចាប់ផ្តើមក្នុងទសវត្សរ៍ឆ្នាំ ១៩៦០។

និងជាគម្រោងបង្វែរទឹក (គម្រោងបង្វែរទឹក ថាខូ)។ នៅក្នុងខេត្តយូណាន ប្រទេសចិន មានទំនប់វារីអគ្គិសនីចំនួន ៨ ដែលបានលាតសន្ធឹងតាមដងទន្លេឡានឆាង ហើយទំនប់មួយចំនួនកំពុងធ្វើការសាងសង់ និងមួយចំនួនទៀតស្ថិតនៅជាគម្រោងសាងសង់។ នេះ គឺជាសេចក្តីសម្រេចរបស់ប្រទេសចិនក្នុងការអភិវឌ្ឍទន្លេមេគង្គ ក្នុងខេត្តយូណាន និងធ្វើឱ្យមានការផ្លាស់ប្តូរនូវរបបធារទឹកតាមរដូវកាល ដែលបានកាត់បន្ថយការស្ទាក់ស្ទើរធ្លាប់មានពីមុនក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ទន្លេមេគង្គបែបនេះ នៅតាមអាងទន្លេមេគង្គក្រោម និងបានធ្វើឱ្យគម្រោងតាមទន្លេមេនឹងទទួលបានចំណេញច្រើន[៣]។ កត្តាអន្តរជាតិផ្សេងៗទៀត រួមមានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលផ្ទុយពីជម្រើសផលិតអគ្គិសនីដោយប្រើឥន្ធនៈផូស៊ីល និងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការពឹងផ្អែកលើថាមពលដែលបានពីការនាំចូល និងការកើនឡើងនូវភាពសម្បូរបែបនៃការផ្គត់ផ្គង់ បានធ្វើឱ្យថាមពលនឹងទទួលបានពីវារីអគ្គិសនី ក្លាយចំណាប់អារម្មណ៍របស់ប្រទេសនៅទន្លេមេគង្គក្រោម។

**គំនូសតាងទី១: គម្រោងវារីអគ្គីសនីនៅតាមទន្លេមេ ដែលបានស្នើឡើងនៅអាងទន្លេមេគង្គក្រោម និងខេត្ត យូណាន ប្រទេសចិន**




[៣] អាងស្តុកទឹកក្នុងប្រទេសចិន អាចរក្សាទឹកនៅរដូវវស្សា ហើយបង្ហូរទឹកចេញនៅរដូវប្រាំង ដោយផ្តល់របាយធារទឹកប្រចាំ ឆ្នាំមានលក្ខណៈដូចគ្នា សម្រាប់ប្រតិបត្តិការវារីអគ្គីសនីនៅអាងទន្លេមេគង្គក្រោម។

រដ្ឋាភិបាលប្រទេសឡាវ និងរដ្ឋាបាលកម្ពុជាបាន និងកំពុងធ្វើការពិនិត្យឡើងវិញ នូវសំណើគម្រោងសាងសង់ទំនប់វារីអគ្គិសនីតាមទន្លេមេទាំងនេះ ជាពិសេសដោយផ្អែកលើមូលដ្ឋានគម្រោងមួយៗ។ ប្រទេសឡាវបានរៀបចំសិក្សាពីផលចំណេញខ្ពស់បំផុតពីគម្រោងតាមដងទន្លេមេគង្គនេះ សម្រាប់តំបន់ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងទំនប់ចំនួន ៦ នៅតាមទន្លេមេនៃទន្លេមេគង្គខាងលើទីក្រុងវៀងច័ន្ទ។ ក្រៅពីការពិចារណារបស់ខ្លួនក្នុង ដំណើរការរៀបចំផែនការផ្អែអាងទន្លេថ្នាក់តំបន់របស់គណៈកម្មាការទន្លេមេគង្គ គម្រោងទាំងនេះបានដំណើរការទៅមុខ ដោយពុំមានគម្រោងអភិវឌ្ឍន៍ទីតាំង ឬអភិវឌ្ឍន៍រួមសម្រាប់ទន្លេនេះទេ ទាំងកំរិតប្រទេសនីមួយៗ ឬទាំងថ្នាក់តំបន់[៤]។ ចំពោះអវត្តមានរបស់ក្របខ័ណ្ឌណែនាំនេះ ស្ថាប័នបរិស្ថាន និងថាមពលជាតិកំពុងប្រើប្រាស់នីតិវិធី និងស្តង់ដារត្រួតពិនិត្យគម្រោងជាក់លាក់ ដែលរួមមានការវាយតម្លៃផលប៉ះពាល់បរិស្ថានមុនពេលធ្វើសេចក្តីសម្រេចថ្នាក់ជាតិលើករណីនីមួយៗ។

នៅថ្នាក់តំបន់ ប្រទេសតាមអាងទន្លេមេគង្គក្រោមបានអនុម័តលើកិច្ចព្រមព្រៀងមួយ ដែលចិតក្រោមកិច្ចព្រមព្រៀងទន្លេមេគង្គ ដោយទាមទារឱ្យប្រទេសទាំងនោះជូនដំណឹងដល់ប្រទេសជិតខាង ទាក់ទងនឹងគម្រោងស្នើឡើងតាមទន្លេមេនៃទន្លេមេគង្គ នៅពេលមានព័ត៌មានគ្រប់គ្រាន់ ហើយបន្ទាប់មកទៀតធ្វើការប្រឹក្សា និងសម្រេចកិច្ចព្រមព្រៀមថាតើគួរតែបន្តគម្រោង ឬអត់ ហើយប្រសិនបើបន្តដំណើរការ គួរប្រើប្រាស់លក្ខខណ្ឌបែបណា។ នីតិវិធីជូនដំណឹងពេញលេញ ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង គឺបានលើកឡើងដំបូងកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ដោយមានការជូនដំណឹងជាផ្លូវការពីប្រទេសឡាវ ទាក់ទងនឹងការស្នើឡើងនូវគម្រោងតាមដងទន្លេមេដែលមានឈ្មោះថាសាយ៉ា ឬរី។ សំណើគម្រោងវារីអគ្គិសនីតាមទន្លេមេមួយនេះនឹងក្លាយជាការសាកល្បងមួយដ៏សំខាន់ចំពោះនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងនិងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ក្នុងការអនុវត្តកិច្ចព្រមព្រៀងទន្លេមេគង្គ ឆ្នាំ១៩៩៥។

## ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន

នេះហាក់ដូចជាការរីកចំរើនយ៉ាងឆាប់រហ័ស ដែលគម្រោងស្នើសុំជាច្រើនធ្វើឡើងក្នុងពេលដំណាលគ្នា និងនៅលើទន្លេតែមួយ ដែលជាហេតុនាំឱ្យប្រទេសទាំងអស់ក្នុងអាងទន្លេមេគង្គក្រោម ធ្វើការអំពាវនាវឱ្យមានការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពី ផលប៉ះពាល់ផ្នែកបរិស្ថាន សម្រាប់គម្រោងទាំង ១២ ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរបស់គណៈកម្មការទន្លេមេគង្គ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន

[៤] ផែនការអភិវឌ្ឍន៍អាងរបស់គណៈកម្មការទន្លេមេគង្គ បង្ហាញពីដំណើរការចាប់ផ្តើមដ៏សំខាន់ ក្នុងការសម្របសម្រួលលើការ ធ្វើផែនការថ្នាក់តំបន់នាឆ្នាំថ្មីៗនេះ។

ផ្តោតលើបញ្ហាយុទ្ធសាស្ត្រ ដែលមានលក្ខណៈទូលំទូលាយ ហើយជាទូទៅពាក់ព័ន្ធលើការងារគម្រោងលើសពីមួយ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន (Strategic Environmental Assessment, SEA)អនុវត្តជំហានប្រហាក់ប្រហែលគ្នា នឹងការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន (Environmental Impact Assessments, EIAs) ប៉ុន្តែមានវិសាលភាព ពេលវេលា ទីកន្លែង និងប្រធានបទទូលំទូលាយជាង។

ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន គឺជាឧបករណ៍មួយសំរាប់ការត្រួតពិនិត្យបញ្ហាជាយុទ្ធសាស្ត្រចម្បងៗ ដែលត្រូវធ្វើការដោះស្រាយ និងធ្វើការសម្រេចចិត្តមុនពេលមានការសម្រេចចិត្តជាក់លាក់ទាក់ទងនឹងគម្រោងក្រុមហ៊ុនអភិវឌ្ឍន៍ស្នើឡើង។ ក្នុងករណីនេះ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ដែលបានសម្របសម្រួលដោយគណៈកម្មការទន្លេមេគង្គ ត្រូវបានស្នើឱ្យធ្វើឡើងដើម្បីផ្តល់ការយល់ដឹងអំពីបញ្ហាពាក់ព័ន្ធរបស់ការអភិវឌ្ឍវារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ និងផ្តល់អនុសាសន៍ពីមធ្យោបាយល្អបំផុតបើគម្រោងត្រូវអនុវត្តបន្ត។ លើសពីនេះ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ធ្វើឡើងក្នុងគោលបំណងចូលរួមចំណែកដល់ដំណើរការនៃនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង ដើម្បីពង្រឹងបន្ថែមដល់ការរៀបចំផែនការអភិវឌ្ឍន៍នៅទូទាំងអាងទន្លេមេគង្គ និងជាចុងក្រោយ ដើម្បីគាំទ្រដល់ការសម្រេចចិត្តថ្នាក់ជាតិទាក់ទងនឹងសំណើគម្រោងតាមទន្លេមេនៃទន្លេមេគង្គ។

ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ផ្តោតការយកចិត្តទុកដាក់លើសំណើគម្រោងដែលស្ថិតក្នុងតំបន់វារីអេកូឡូស៊ី ដោយមានលក្ខណៈដាច់ដោយឡែកក្នុងទីតាំងចំនួន ៣ និងធ្វើការវាយតម្លៃគម្រោងទាំងនោះជាក្រុមផ្សេងៗគ្នាចំនួន ៥: ទី(១) រាល់ទំនប់តាមដងទន្លេមេក្នុងអាងមេគង្គក្រោម ដែលបានស្នើឡើងទាំងអស់ ទី(២) គម្រោងប៉ែកខាងលើរបស់ប្រទេសឡាវចំនួន ៦គម្រោង ដែលស្ថិតនៅប៉ែកខាងលើទីក្រុងវៀងច័ន្ទ ទី(៣) គម្រោងប៉ែកកណ្តាលប្រទេសឡាវចំនួន ២ ដែលនៅខាងលើ និងខាងក្រោមខេត្តប៉ាកសេ (គម្រោងវារីអគ្គិសនី បាន គួម និងគម្រោងវារីអគ្គិសនី ឡាត សួ) ទី(៤) គម្រោងតូចៗចំនួន ២ ដែលស្ថិតនៅផ្នែកខាងក្រោមនៃល្បាក់ខោន (គម្រោងវារីអគ្គិសនី ដូន សាហុង និងគម្រោងបង្វែរទឹក ថា ខូ ) និងទី(៥) គម្រោងរបស់ប្រទេសកម្ពុជាចំនួន ២ ដែលស្ថិតនៅប៉ែកខាងលើនៃខេត្តក្រចេះ (គម្រោងវារីអគ្គិសនីស្ទឹងត្រែង និងសំបូរ)។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្របានធ្វើឡើងជា ៤ដំណាក់កាល ក្នុងរយៈពេល ១៦ខែ ដោយគិតចាប់ពីខែឧសភា ឆ្នាំ២០០៩ (១) ដំណាក់កាលវាយតម្លៃពីវិសាលភាព ក្នុងការកំណត់បញ្ហាជាយុទ្ធសាស្ត្រដ៏សំខាន់ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទន្លេមេគង្គ (២) ការវាយតម្លៃជាមូលដ្ឋាន ដើម្បីធ្វើការពិពណ៌នាពីនិន្នាការនៃបញ្ហាទាំងនោះកាលពីមុន និងការព្យាករណ៍ទុករហូតឆ្នាំ២០៣០ ដោយមិនមានវារីអគ្គិសនីតាមដងទន្លេមេ (៣)

ការវាយតម្លៃផលប៉ះពាល់នៃឥទ្ធិពលរបស់វារីអគ្គិសនីតាមដងទន្លេមេទៅលើនិន្នាការទាំងនោះ និង (៤) ដំណាក់កាលកំណត់ពីមធ្យោបាយជៀសវាង និងកាត់បន្ថយហានិភ័យ និងលើកកម្ពស់ផលប្រយោជន៍នៃការអភិវឌ្ឍនេះ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្របានធ្វើការប្រឹក្សាយោបល់យ៉ាងទូលំទូលាយ ដោយមាន ការចូលរួមពីស្ថាប័នពាក់ព័ន្ធចំនួន ៦០ អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលចំនួន ៤០ និងអង្គការ អភិវឌ្ឍន៍អន្តរជាតិចំនួន ២០ នៅក្នុងកិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ។ ដំណើរការវាយតម្លៃបរិស្ថានជា យុទ្ធសាស្ត្រនេះ ក៏មានការចូលរួមពីប្រទេសចិន តាមរយៈគណៈកម្មការសិក្សាប្រព័ន្ធអេកូឡូស៊ីជាន់ខ្ពស់សម្រាប់ទន្លេអន្តរជាតិផងដែរ។

គំនិតយោបល់ និងមតិផ្សេងៗ ដែលបានលើកឡើងក្នុងពេលប្រឹក្សាយោបល់ បានជួយណែនាំ និងកំណត់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នៅគ្រប់ដំណាក់កាលវាយតម្លៃទាំងអស់។ ក្នុងរបាយការណ៍នេះ ក្រុមវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្របានធ្វើការសំយោគ និងវិភាគគំនិតយោបល់ និងព័ត៌មាន ដែលបានពីអ្នកឯកទេសរបស់រដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងសហគមន៍មិនមែនរដ្ឋាភិបាល។ នៅពេលមានការខ្វែងគំនិតគ្នា ចំពោះគំនិតយោបល់ដែលនៅមានទាក់ទងនឹងបញ្ហាសំខាន់ៗ ដូចជាការខាតបង់ និងអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់សំណើគម្រោងតាមដងទន្លេមេ ក្រុមវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រធ្វើការសន្និដ្ឋានផ្ទាល់ ដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន។

យ៉ាងណាមិញ បញ្ហាសំខាន់ៗមួយចំនួន ដែលបានលើកឡើងដោយអ្នកពាក់ព័ន្ធ គឺហួសពីវិសាលភាពនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រក្នុងការត្រួតពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ។ បញ្ហាទាំងនោះតម្រូវឱ្យមានការសិក្សាស្រាវជ្រាវឱ្យបានទូលំទូលាយបន្ថែមទៀត។ ឧទាហរណ៍ ការព្យាករណ៍ពីតម្រូវការថាមពលក្នុងប្រទេសនីមួយៗ និងនៅថ្នាក់តំបន់ (គំនូសតាងទី២) បាននាំឱ្យមានការពិភាក្សា និងភាពខ្វែងគំនិតយ៉ាងច្រើន ដូចជាករណីនៃតម្រូវការថាមពលថ្នាក់ជាតិនាពេលអនាគតក្នុងប្រទេសវៀតណាម ការប៉ាន់ស្មានដែលធ្វើឡើងដោយផ្អែកលើករណីសិក្សារបស់កម្មវិធីអនុតំបន់ទន្លេមេគង្គរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីអំពីថាមពលនាពេលអនាគតត្រូវការចំនួន ៩៤% នៃការប៉ាន់ស្មានផ្លូវការរបស់រដ្ឋាភិបាល ហើយកង្វះខាតនេះ គឺស្មើនឹង ៣,៥ ដងច្រើនជាងការផលិតថាមពលប្រចាំឆ្នាំពី គម្រោងសាងសង់វារីអគ្គិសនីតាមដងទន្លេទាំង១២[៥]។ ស្រដៀងគ្នានេះដែរ បញ្ហាស្តីពីជម្រើស គឺជាកត្តាមួយយ៉ាងសំខាន់ដែលបានលើកមកពិភាក្សាជាមួយនឹងជាមួយអ្នកពាក់ព័ន្ធ ប៉ុន្តែបញ្ហានេះតម្រូវឱ្យក្រុមបំពេញការងារបន្ថែមច្រើនទៀត។ ក្នុងករណីបែបនេះ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានធ្វើការរាយការណ៍តួលេខ និងប្រភពផ្លូវការចុងក្រោយទាក់ទងនឹងព័ត៌មាន

[៥] ការព្យាកររបស់អ្នកជំនាញ IRM នៅឆ្នាំ២០០៨ បោះពុម្ពផ្សាយឡើងវិញនៅឆ្នាំ២០០៩ ក្នុងរបាយការណ៍របស់ ធនាគារអភិវឌ្ឍអាស៊ី "ការបង្កើតថាមពលនាពេលអនាគតប្រកបដោយនិរន្តរភាព មហាអនុតំបន់ទន្លេមេគង្គ ឆ្នាំ២០០៩"។

អំពីទិដ្ឋភាពទូទៅនៃស្ថានភាព ហើយធ្វើការបង្វែរចំណាប់អារម្មណ៍ទៅរកភាពមិនប្រាកដប្រជា ដែលនៅមាន និងស្វែងរកបញ្ហាជាអាទិភាពសម្រាប់ការវិភាគលម្អិតបន្ថែម។

**តំនូសតាងទី២: ការព្យាករណ៍តម្រូវការថ្នាក់តំបន់នៃអាងទន្លេមេគង្គក្រោម រហូតដល់ឆ្នាំ២០២៥ - ការប្រៀបធៀបការព្យាករជាផ្លូវការរបស់រដ្ឋាភិបាល និងការព្យាករណ៍តាមរយៈការសិក្សាពីថាមពលនា ពេលអនាគតរបស់មហាអនុតំបន់ទន្លេមេគង្គដែលអនុវត្តដោយធនាគារអភិវឌ្ឍន៍អាស៊ី** (ADB GMS)




## លទ្ធផលរកឃើញដោយការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន

ការវាយតម្លៃជាមូលដ្ឋាន និងការប៉ាន់ប្រមាណអំពីផលប៉ះពាល់បានលើកឡើងថា ៩៦% នៃតម្រូវការថាមពលរហូតដល់ឆ្នាំ២០២៥ គឺមកពីប្រទេសថៃ និងប្រទេសវៀតណាម ហើយប្រទេសទាំង ២ នេះមានគោលដៅទិញថាមពលប្រមាណ ៩០% នៃថាមពល ដែលបានបង្កើតឡើងដោយគម្រោងតាមទន្លេមេនៃទន្លេមេគង្គ។ ប្រសិនបើប្រទេសថៃ និងប្រទេសវៀតណាម សម្រេចចិត្តថាមិនទិញថាមពលមកពីទន្លេមេនៃទន្លេមេគង្គនោះ គម្រោងទាំងអស់ដែលបានរៀបចំឡើងសម្រាប់ការនាំចេញហាក់ដូចជាមិនអាចដំណើរការទៅមុខបានឡើយ។

លទ្ធផលរកឃើញសំខាន់ៗពីការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ដូចដែលសង្ខេបជូនខាងក្រោម យោងតាមអ្វីដែលអ្នកពាក់ព័ន្ធមកពីស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាលកំណត់ថាជា "បញ្ហាយុទ្ធសាស្ត្រ ចម្បងៗ" ពាក់ព័ន្ធនឹងការអភិវឌ្ឍតាមដងទន្លេមេគង្គ។ បញ្ហាទាំងនេះត្រូវបានកំណត់ឡើងដោយសមាជិកចូលរួមថ្នាក់ជាតិរាប់រយនាក់នៅក្នុងកិច្ចប្រជុំថ្នាក់តំបន់ កិច្ចប្រជុំតុមូល និងសិក្ខាសាលាថ្នាក់តំបន់។ គំនិតយោបល់ទាំងនោះ រួមមាន:

- សន្តិសុខ និងការផលិតថាមពល រួមមានប្រាក់ចំណូល ការធ្វើពាណិជ្ជកម្ម និងការវិនិយោគបរទេស
- ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ
- ភាពត្រឹមត្រូវ និងភាពសម្បូរបែបនៃប្រព័ន្ធអេកូឡូស៊ី ដែលរួមមានភាពមិនទៀតទាត់របស់វារីជាតិជីគោក និងធារាសាស្ត្រ ព្រមទាំងការហូរច្រោះនូវសារធាតុចិញ្ចឹម
- វិស័យជលផល និងសន្តិសុខស្បៀង (រួមទាំងវិស័យកសិកម្ម)
- ប្រព័ន្ធសង្គម ជីវភាពរស់នៅ និងវប្បធម៌នៃការរស់នៅរបស់សហគមន៍ទទួលរងផលប៉ះពាល់។

ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ពិចារណាលើផលប៉ះពាល់ជាក់លាក់ (វិជ្ជមាន និងអវិជ្ជមាន) របស់គម្រោងទំនប់តាមទន្លេមេដែលបានស្នើឡើង។ ផលប៉ះពាល់ទាំងនោះ គឺបន្ថែមទៅលើផលប៉ះពាល់របស់គម្រោងវារីអគ្គិសនីធំៗចំនួន ៤១ ដែលត្រូវធ្វើនៅតាមដងទន្លេមេគង្គនៅត្រឹមឆ្នាំ ២០១៥ គម្រោងវារីអគ្គិសនីដោយមានអាងស្តុកទឹកចំនួន ៨ នៅអាងទន្លេមេគង្គលើក្នុងប្រទេសចិន ក៏ដូចជាផលប៉ះពាល់នៃសំពាធផ្សេងៗដែលមិនមែនបង្កឡើងដោយទំនប់មកលើប្រព័ន្ធធនធានធម្មជាតិរបស់ទន្លេមេគង្គ[៦]។

## ការផលិតថាមពល និងសន្តិសុខ

អំឡុងពេល ២ទៅ៣ ទសវត្សរ៍កន្លងទៅនេះ តំបន់ទន្លេមេគង្គមានកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំង។ ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០៥ កំណើនសេដ្ឋកិច្ច និងតម្រូវការអគ្គិសនីបានកើនឡើងនូវអត្រាប្រចាំឆ្នាំជាមធ្យម ៨% ដែលជាអត្រាមួយខ្ពស់បំផុតក្នុងពិភពលោកក្នុងអំឡុងពេលមួយ។ ទន្ទឹមនឹងអត្រាកំណើនតម្រូវការអគ្គិសនី

[៦] ការព្យាករផ្លូវការឆ្លុះបញ្ចាំងពីការអភិវឌ្ឍថាមពលថ្នាក់ជាតិ។ គម្រោងធនាគារអភិវឌ្ឍន៍អាស៊ី (RETA 6440) ដែលកំពុងអនុវត្តមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងការព្យាករជាផ្លូវការរបស់រដ្ឋាភិបាល ដូចមានបង្ហាញក្នុងគំនូសតាងនេះ។

ក្នុងតំបន់ទន្លេមេគង្គមានអត្រាខ្ពស់ កំណើនតម្រូវការអគ្គិសនីនេះបាន និងកំពុងកើនឡើងពីកម្រិតទាបមួយក្នុងមនុស្សម្នាក់[៧]។

គេរំពឹងថាតម្រូវការថាមពលអគ្គិសនីនឹងកើនឡើងប្រមាណ ៦ ទៅ ៧% ជារៀងរាល់ឆ្នាំរហូតដល់ឆ្នាំ២០២៥។ កំណើនតម្រូវការថាមពលនេះ ស្របពេលជាមួយនឹងកំណើនសកម្មភាពសេដ្ឋកិច្ចនានានៅតំបន់អាងទន្លេមេគង្គ និងកំណើនប្រជាជន។ ប្រទេសវៀតណាម និងថៃ កំពុងបង្កើនចំនួនបង្គោលខ្សែភ្លើងបន្ថែមទៀតដើម្បីបំពេញតាមតម្រូវការនេះ ហើយកម្ពុជា និងឡាវ កំពុងរាយបណ្តាញអគ្គិសនីថ្នាក់ជាតិ ដោយតភ្ជាប់គ្នាទៅវិញទៅមកជាបន្តបន្ទាប់ (សូមមើលគំនូសតាងទី២)។ ក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីថ្នាក់ជាតិ រដ្ឋាភិបាលជ្រើសយកជម្រើសមួយចំនួន រួមមានថាមពលវារីអគ្គិសនី ថាមពលនុយក្លេអ៊ែរ ថាមពលអគ្គិសនីដើរដោយកំដៅ និងការគ្រប់គ្រងតម្រូវការរបស់អ្នកប្រើប្រាស់។

ក្នុងមហាអនុតំបន់ទន្លេមេគង្គ មានសក្តានុពលវារីអគ្គិសនីធំធេង ដោយមានលទ្ធផលផ្តល់ថាមពលអគ្គិសនីតាមលក្ខណៈបច្ចេកទេសពី ១៧៦.៣៥០ ទៅ ២៥០.០០០ មេហ្គាវ៉ាត់។ ប្រទេសតាមអាងទន្លេមេគង្គទាំង ៤ រួមមានប្រទេស កម្ពុជា ឡាវ ថៃ និងវៀតណាម មានសក្តានុពលវារីអគ្គិសនីថ្នាក់ជាតិប្រមាណពី ៥០.០០០ ទៅ ៦៤.៧៥០ មេហ្គាវ៉ាត់ ដែលក្នុងនោះ ថាមពលអគ្គិសនីប្រមាណ ៣០.០០០ មេហ្គាវ៉ាត់ បានមកពីអាងទន្លេមេគង្គក្រោម ដែលរួមមានថាមពលអគ្គិសនីប្រមាណ ១៤.៦៩៧ មេហ្គាវ៉ាត់ បានមកពីគម្រោងការតាមទន្លេមេនៃទន្លេមេគង្គ។ បើយើងរាប់បញ្ចូលទាំងទន្លេមេគង្គលើ ក្នុងខេត្តយូណានទៀតនោះ អាងទន្លេមេគង្គទាំងមូលមានសក្តានុពលផលិតវារីអគ្គីសនីបានប្រមាណ ៥៣.០០០ មេហ្គាវ៉ាត់។

**យោងតាមគម្រោងប្លង់ថ្មីៗ ទំនប់តាមទន្លេមេនៃទន្លេមេគង្គក្រោមចំនួន ១២ អាចផលិតថាមពលអគ្គិសនីដល់ទៅ ១៤.៦៩៧ មេហ្គាវ៉ាត់ ឬប្រមាណ ២៣ ទៅ ២៨% នៃសក្តានុពលវារីអគ្គិសនីថ្នាក់ជាតិរបស់ប្រទេសនៅអាងទន្លេមេគង្គក្រោមទាំងបួន** ហើយថាមពលអគ្គិសនីមានប្រមាណ ៥ ទៅ ៨% នៃសក្តានុពលវារីអគ្គិសនីសរុបក្នុងមហាអនុតំបន់ទន្លេមេគង្គ។ និន្នាការថ្នាក់ជាតិ និងថ្នាក់តំបន់ច្បាស់លាស់ចំនួន ៣ ដែលគាំទ្រដល់ការពង្រីកការចែកចាយថាមពលវារីអគ្គិសនីដល់វិស័យថាមពលរបស់មហាអនុតំបន់ទន្លេមេគង្គ : (១) បង្កើនកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ពាណិជ្ជកម្ម និងការរៀបចំផែនការ (២) គោលបំណងយ៉ាងមុះមុតរបស់ជាតិក្នុងការពង្រីកប្រភពថាមពល និងកាត់បន្ថយការពឹងផ្អែកលើថាមពលបម្រុងឥន្ធនៈផូស៊ីលកម្រ និងមានតិចតួច និង (៣) និន្នាការអន្តរជាតិ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពលនេះ។

**ប្រសិនប្រើទំនប់វារីអគ្គិសនីតាមដងទន្លេមេទាំង ១២ ត្រូវបានសាងសង់ទាំងអស់ នោះគម្រោងទាំងនេះនឹងនាំមកនូវកំណើនថាមពលដែលផលិតបានប្រកបដោយចីរភាព និងសមត្ថភាពផលិតថាមពលអគ្គិសនីក្នុង**

[៧] ត្រឹមឆ្នាំ ២០០៨ ការប្រើប្រាស់អគ្គិសនី ក្នុងមហាអនុតំបន់ទន្លេមេគង្គ គឺ ៩៤០ គីឡូវ៉ាត់ ក្នុងមនុស្សម្នាក់ៗ ក្នុងមួយឆ្នាំ ដែលប្រហែលជា ២ភាគ៣ នៃប្រទេសកំពុងអភិវឌ្ឍន៍គិតជាមធ្យម។

**តំបន់។** ការព្យាករពីតម្រូវការអគ្គិសនីសម្រាប់ប្រទេសនៅខាងក្រោមអាងទន្លេមេគង្គក្នុងឆ្នាំ ២០២៥ មានបរិមាណសរុបប្រមាណ ១៣០.៣៦៦ មេហ្គាវ៉ាត់។ ទំនប់តាមទន្លេមេនៃអាងទន្លេមេគង្គក្រោមទាំងនេះ បង្ហាញពីសមត្ថភាពផ្តល់ថាមពលប្រមាណ ១១% នៃសមត្ថភាពផ្តល់ថាមពលដែលបានសាងសង់បន្ថែមនៅអាងទន្លេមេគង្គ[៨] ដែលត្រូវការរវាងឆ្នាំ២០១០ និងឆ្នាំ២០២៥។ ប្រសិនបើមិនមានគម្រោងតាមទន្លេមេនៃទន្លេមេគង្គចំនួន ២ របស់ប្រទេសកម្ពុជាទេនោះ ភាគរយនេះនឹងធ្លាក់ចុះមកនៅត្រឹម ៩% និងនៅសល់ត្រឹម ៧% ប្រសិនបើមានតែគម្រោងនៅតំបន់ល្បាក់ទឹកភាគខាងលើប្រទេសឡាវ (ប៉ាក បេង រហូតដល់ ប៉ាក ចុម) នៅបន្តសាងសង់។

**តារាងទី១: ការព្យាករតម្រូវការថាមពលថ្នាក់ជាតិ សម្រាប់ប្រទេសនៅតាមអាងទន្លេមេគង្គក្រោមត្រឹមឆ្នាំ ២០២៥**

| | កម្ពុជា | ឡាវ | ថៃ | វៀតណាម | សរុប/ថ្នាក់តំបន់ |
|---|---|---|---|---|---|
| តម្រូវការអគ្គិសនី (មេហ្គាវ៉ាត់) | ២.៤០១ | ២.៦៩៦ | ៥៣.៨២៤ | ៧២.៤៤៥ | ***១៣០.៣៦៦*** |
| តម្រូវការថាមពលថ្នាក់ជាតិ (ជីហ្គាវ៉ាត់/ឆ្នាំ) | ១៤.៣០២ | ១៦.០៦០ | ៣៣៩.៤៧៩ | ៤៥០.៦១៨ | ***៨២០.៤៥៨*** |
| ថាមពលប្រចាំឆ្នាំគិតជាមធ្យមបានមកពីទំនប់តាមទន្លេមេនៃអាងទន្លេមេគង្គក្រោម (ជីហ្គាវ៉ាត់/ឆ្នាំ) | ១៩.៧៤០ | ៤៦.០៥៤ | - | - | ***៦៥.៧៩៤*** |
| បំណែងចែកថាមពលវារីអគ្គិសនី ដែលបានមកពីទន្លេមេនៃអាងទន្លេមេគង្គក្រោម គិតជាភាគរយចំពោះតម្រូវការថ្នាក់ជាតិ * | ១៣,៨% | ២៨,៧% | ១១,៦ % | ៤,៤ % | ***៨,៣ %*** |
| បំណែងចែកថាមពលវារីអគ្គិសនី ដែលបានមកពីទន្លេមេរបស់អាងទន្លេមេគង្គក្រោម គិតជាភាគរយចំពោះតម្រូវការអគ្គិសនីថ្នាក់ជាតិ | | | | | ***១១,៣ %*** |

* គេប៉ាន់ស្មានថា ការផលិតថាមពលប្រមាណ ៩០% នៃការផលិតថាមពលអគ្គិសនីនៅតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម គឺសម្រាប់នាំចេញទៅប្រទេសថៃ និងវៀតណាម ហើយថាមពលអគ្គិសនីប្រមាណ១០% សម្រាប់តម្រូវការក្នុងស្រុក

**ទំនប់វារីអគ្គិសនីទាំង ១២ តាមទន្លេមេនៃទន្លេមេគង្គ បង្ហាញពីតម្រូវការថាមពលអគ្គិសនីប្រមាណ ៦ ទៅ ៨% នៃតម្រូវការថាមពលអគ្គិសនីរបស់អាងទន្លេមេគង្គក្រោម ដែលបានធ្វើការព្យាករទុកសម្រាប់ឆ្នាំ**

[៨] សមត្ថភាពផ្តល់ថាមពល គិតជា វ៉ាត់ ឬចម្រុះ គឺជាសមត្ថភាពផលិតថាមពលជាអគ្គិសនី ដែលបានកំណត់ នៃមាស៊ីនផលិតថាមពល

**២០២៥ ស្មើនឹងអត្រាកំណើនតម្រូវការថាមពលនៅអាងទន្លេមេគង្គក្រោមដែលបានរំពឹងទុកក្នុង១ឆ្នាំ រវាងឆ្នាំ ២០១៥ ដល់ឆ្នាំ២០២៥។** ការព្យាករជាផ្លូវការសម្រាប់ ឆ្នាំ ២០២៥ បានប៉ាន់ប្រមាណថា តម្រូវការថាមពលថ្នាក់តំបន់នៅអាងទន្លេ មេគង្គក្រោមមានប្រមាណ ៨២០ តេរ៉ាវ៉ាត់ក្នុងមួយឆ្នាំ ហើយក្នុងនោះគម្រោងតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម អាចផ្គត់ផ្គង់ដោយធ្វើការប្រកួតប្រជែងបានចំនួន ៦៥ តេរ៉ាវ៉ាត់ក្នុងមួយឆ្នាំ ជាមួយនឹងមធ្យោបាយផ្សេងៗ នៃការផលិតថាមពលនៅក្នុងទីផ្សារនាំចេញ។ ការនាំចេញថាមពលអគ្គិសនីសរុបទៅកាន់ប្រទេសថៃ និងវៀតណាម ដែលទទួលបានពីគម្រោងតាមដងទន្លេមេនៃអាងទន្លេមេគង្គក្រោមមានប្រមាណ ៥៣ តេរ៉ាវ៉ាត់ ក្នុងមួយឆ្នាំ (ថាមពលអគ្គិសនីប្រមាណ ២ ភាគ ៣ ទទួលបានពីប្រទេសឡាវ និង ១ ភាគ ៣ ទទួលបានពីប្រទេសកម្ពុជា) ពីព្រោះថាមពលមួយចំនួនត្រូវប្រើប្រាស់ក្នុងប្រទេសម្ចាស់គម្រោង។ ប្រសិនបើគម្រោងវារីអគ្គិសនីតាមទន្លេមេបានអនុវត្តបន្ត នោះគម្រោងទាំងនេះអាចបំពេញតាមតម្រូវការប្រមាណ ៤,៤% នៃតម្រូវការថាមពលថ្នាក់ជាតិនៅប្រទេសវៀតណាម តម្រូវការថាមពលប្រមាណ ១១,៦% នៃតម្រូវការថាមពលនេះក្នុងប្រទេសថៃ តម្រូវការថាមពលប្រមាណ ១៣,៨% នៃតម្រូវការក្នុងប្រទេសកម្ពុជា និងតម្រូវការថាមពល ២៨,៧% នៃតម្រូវការថាមពលក្នុងប្រទេសឡាវ នៅត្រឹមឆ្នាំ ២០២៥ (តារាងទី១ )[៩]។

**នាពេលបច្ចុប្បន្ន អ៊ីដ្រូកាបួ (ឧទាហរណ៍ ធ្យូងថ្ម ឧស្ម័នធម្មជាតិ និងប្រេង) គ្របដណ្តប់ការផលិតថាមពល (ប្រហែល ៨៥%) ប៉ុន្តែវារីអគ្គិសនីនឹងបន្តដើរតួនាទីជាផ្នែកមួយដ៏សំខាន់មួយ ក្នុងល្បាយផ្គត់ផ្គង់ថាមពលនាពេលអនាគត** ដោយមានទាំងថាមពលកកើតឡើងវិញ ការគ្រប់គ្រងតម្រូវការរបស់អ្នកប្រើប្រាស់ និងប្រសិទ្ធភាពថាមពល ដែលបន្ថែមលើការបង្កើនការផលិតថាមពលតាមបែបធម្មជាតិ។

**ប្រទេសឡាវបានទទួលផលប្រយោជន៍យ៉ាងច្រើនបំផុតពីថាមពលទាំងអស់ ដោយបានចូលរួមដោយផ្ទាល់ជាមួយនឹងគម្រោងវារីអគ្គីសនីនៅតាមទន្លេមេនៃទន្លេមេគង្គ។** ប្រទេសឡាវនឹងទទួលបានអត្ថប្រយោជន៍ពីថាមពលនេះ ច្រើនជាង ៧០% នៃអត្ថប្រយោជន៍ថាមពលសរុបរួមមានប្រាក់ចំណូល និងមិនបាច់ចំណាយលើថាមពលកំដៅ។ ចំណែកប្រទេសកម្ពុជា និងថៃ នឹងទទួលបានអត្ថប្រយោជន៍ពីថាមពលនេះប្រមាណ ១១-១២% ហើយប្រទេសវៀតណាម នឹងទទួលបានអត្ថប្រយោជន៍ប្រមាណ ៥% នៃអត្ថប្រយោជន៍ថាមពលសរុប។ នៅរយៈពេលមធ្យម ប្រសិនបើមិនមានគម្រោងវារីអគ្គិសនីតាមដងទន្លេមេ ក៏ប្រទេសឡាវនៅតែមានសក្តានុពលវារីអគ្គិសនីគ្រប់គ្រាន់ពីប្រភពទឹកទន្លេមេគង្គ ដើម្បីបន្តបង្កើតប្រាក់ចំណូលពីការនាំចេញទៅតាមបំណង និងជំរុញដល់ការវិនិយោគក្នុងសេដ្ឋកិច្ចដែលកំពុងតែមានសន្ទុះរបស់ខ្លួនផងដែរ។

**ក្នុងលក្ខខណ្ឌនៃការផ្គតផ្គត់ថាមពលដែលមានតម្លៃថោក គម្រោងតាមទន្លេមេនៃទន្លេមេគង្គ គឺពិតជាសំខាន់ខ្លាំងណាស់សម្រាប់វិស័យថាមពលរបស់ព្រះរាជាណាចក្រកម្ពុជា ជាពិសេសក្នុងរយៈពេលយូរអង្វែង នៅពេលដែលទំនប់វារីអគ្គិសនីទាំងនេះបង្វែរមកក្រោមសមត្ថកិច្ចថ្នាក់ជាតិ។** នាពេលបច្ចុប្បន្ន តម្រូវការអគ្គិសនី

[៩] សន្និដ្ឋានថាតម្រូវការថាមពលប្រមាណ៩០% ត្រូវនាំចេញទៅប្រទេសថៃ និងវៀតណាម។

ថ្នាក់ជាតិរបស់កម្ពុជាមានការពឹងផ្អែកស្ទើរតែទាំងស្រុងលើឥន្ធនៈផូស៊ីលនាំចូល ហើយជម្រើសសម្រាប់បំពេញតម្រូវការថាមពលថ្នាក់ជាតិ ក៏មានតិចតួចបំផុត។ សក្តានុពលតាមដៃទន្លេរបស់កម្ពុជា មានកម្រិតទាបជាងដៃទន្លេក្នុងប្រទេសឡាវ។ នៅក្នុងរយៈពេលមធ្យម កម្ពុជាមានការបញ្ជាក់ថាតំបន់នៅក្នុងសមុទ្រមានកម្រិតមធ្យមនៃរ៉ែឥន្ធនៈផូស៊ីល[10]។ ទោះជាយ៉ាងនេះក្តី ពុំមានការប៉ាន់ស្មានជាផ្លូវការណាមួយពីចំនួនពិតប្រាកដ ឬចំនួនដែលអាចទាញយកបាននោះនៅឡើយ។ ក្នុងពេលមានការយល់ឃើញថា ធនធានប្រេងនេះមានមួយផ្នែកតូចប៉ុណ្ណោះ ដែលអាចផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច ហើយកន្លែងធនធានរ៉ែប្រេងនេះ កំពុងមានការប្រកួតប្រជែងជាមួយនឹងប្រទេសថៃទៀតនោះ ប្រទេសទាំងពីរ ត្រូវការឱកាសដ៏ចាំបាច់មួយក្នុងការអភិវឌ្ឍវិស័យថាមពលក្នុងប្រទេស[11]។

**វារីអគ្គិសនីតាមដងទន្លេមេមានតិចតួចសម្រាប់វិស័យថាមពលរបស់ប្រទេសថៃនិងវៀតណាម។** គម្រោងអភិវឌ្ឍន៍តាមទន្លេមេនៃទន្លេមេគង្គទាំងនេះ នឹងមានផលប៉ះពាល់តិចតួចដល់តម្លៃអគ្គិសនី (គឺតិចជាង ១,៥%) និងមានឥទ្ធិពលតិចតួចលើយុទ្ធសាស្ត្រផ្គត់ផ្គង់ថាមពលរបស់ប្រទេសទាំងនោះ ដោយសារទំហំនៃវិស័យថាមពលនានារបស់ខ្លួន។

វិស័យថាមពលថ្នាក់តំបន់ នឹងមានផលចំណេញមួយចំនួនពីសក្តានុពលកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុប ពីការផលិតថាមពលកំដៅដែលជំនួសដោយវារីអគ្គិសនី[12]។

ការបង្កើតច្បាប់ និងរៀបចំស្ថាប័នប្រកបដោយប្រសិទ្ធភាព ដែលស្ថិតនៅក្រោមគម្រោងតាមទន្លេមេនៃទន្លេមេគង្គដែលដំណើរការជាលក្ខណៈឯកជនមានភាពស្មុគស្មាញ និងមានការពាក់ព័ន្ធជាលក្ខណៈអន្តរជាតិយ៉ាងទូលំទូលាយ។ ការដាក់ចេញនូវចំណុចវិនិច្ឆ័យណែនាំសម្រាប់ប្រតិបត្តិការសាងសង់ទំនប់តាមទន្លេមេជាច្រើននៅលើទន្លេតែមួយ ក៏មានផលវិបាកជាលក្ខណៈអន្តរជាតិ និងមានការពាក់ព័ន្ធនឹងប្រទេសតាមអាងទន្លេមេគង្គ

[10] មូលនិធិរូបិយវត្ថុអន្តរជាតិ ២០០៧ របាយការណ៍ប្រចាំប្រទេសរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ លេខ ០៧/៣៨៦ ប្រទេសកម្ពុជា ឧបសម្ព័ន្ធស្ថិតិ។

[11] ជម្រើសបច្ចុប្បន្ន ដែលអាចជ្រើសរើសបាន សម្រាប់ការផ្គត់ផ្គង់ថាមពលដុលដល់ប្រទេសកម្ពុជា គឺជាថាមពលដំណើរការដោយធ្យូងថ្មនាំចូល និងថាមពលនាំចូល (ឧ ពីវារីអគ្គិសនីក្នុងប្រទេសឡាវ)។ នៅក្នុងការវាយតម្លៃពីប្រព័ន្ធថាមពលរបស់ខ្លួនរ្វាំ ប្រើប្រាស់តែប្រភពថាមពល ដែលមាននាពេលបច្ចុប្បន្នប៉ុណ្ណោះ។

[12] ការផលិតថាមពលចំនួន ៦៥.០០០ ជីហ្គាវ៉ាត់ ក្នុងមួយឆ្នាំ ដោយវារីអគ្គីសនីតាមដងទន្លេ អាចបញ្ចៀស នូវការផលិតថាមពលពីស្ថានីយ៍ថាមពល ដែលបញ្ចេញកំដៅ (ធ្យូងថ្ម ឧស្ម័នធម្មជាតិ និងប្រេង) នាពេលបច្ចុប្បន្នប្រមាណ៨៥ភាគរយនៃការផលិតថាមពលនៅអាងទន្លេមេគង្គក្រោម។

ក្រោមទាំងបួន ក៏ដូចជាប្រទេសចិន និងប្រទេសភូមាដែរ។ ស្ថានការណ៍មានសភាពកាន់តែស្មុគស្មាញសម្រាប់គម្រោង ២ ដែលស្ថិតនៅតាមព្រំដែនឡាវ និងថៃ ដែលតម្រូវឱ្យមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនយោបាយទ្វេភាគីការបង្កើតគោលការណ៍ជាមូលដ្ឋាន និងបន្ទាប់មកទៀត តម្រូវឱ្យមានគណៈកម្មាធិការអន្តរជាតិទាំងតាមរយៈគណៈកម្មការទន្លេមេគង្គ និងអាជ្ញាធរដែលទទួលបន្ទុកលើគម្រោងមកពីប្រទេសទាំង ២។

បន្ថែមលើតម្រូវការផ្នែកស្ថាប័នជាក់លាក់សម្រាប់គម្រោង នឹងមានតម្រូវការមួយសម្រាប់ស្ថាប័នប្រតិបត្តិការរួមមួយ ដែលយ៉ាងហោចណាស់ ស្ថាប័ននោះអាចដាក់ចេញនូវគោលការណ៍ច្បាប់ជាក់លាក់សម្រាប់ការប្រែប្រួលលំហូររៀងរាល់ម៉ោង និងអនុវត្តការរៀបចំផែនការប្រតិបត្តិការជាអតិបរមា ដើម្បីទទួលបាននូវផលប្រយោជន៍ជាអតិបរមាពីល្បាក់ទឹក និងកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរឱ្យនៅកម្រិតអប្បបរមា។

## ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ

**ប្រសិនបើគម្រោងតាមទន្លេមេនៃទន្លេមេគង្គ ទាំង ១២ ត្រូវបន្តអនុវត្ត នោះប្រទេសឡាវ នឹងទទួលបានប្រាក់ចំណូលប្រមាណ៧០% នៃប្រាក់ចំណូលពីការនាំចេញថាមពលអគ្គិសនីនេះ (២,៦ កោដិដុល្លា អាមេរិក) ដែលបានមកពីទំនប់តាមដងទន្លេ ហើយប្រទេសកម្ពុជានឹងទទួលបានប្រាក់ចំណូលពីថាមពលនេះប្រមាណ ៣០% (១,២ កោដិដុល្លាអាមេរិក)។** ប្រទេសឡាវ នឹងទទួលបានផលប្រយោជន៍ច្រើនជាងគេ ពីព្រោះគម្រោងភាគច្រើនស្ថិតក្នុងប្រទេសនេះ។ ក្រុមប្រជាជនឡាវនៅប៉ែកខាងលើ (ប៉ាក់ បេង ដល់ ប៉ាក់ ចុម) តំណាងឱ្យ ២ភាគ ៣ នៃអត្ថប្រយោជន៍ថាមពលថ្នាក់ជាតិ។ យ៉ាងណាមិញ អំឡុងពេលសម្បទានវារីអគ្គិសនី ទំហំនៃអត្ថប្រយោជន៍ទាំងនោះសម្រាប់ប្រទេសឡាវ និងកម្ពុជា នឹងមិនអាចផ្តល់ឱ្យប្រទេសទាំងមូល ឬមួយដល់រដ្ឋាភិបាលឡើយ ពោលគឺអត្ថប្រយោជន៍នោះនឹងត្រូវផ្តល់ជូនអ្នកសាងសង់ និងអ្នកផ្តល់ថវិកាសម្រាប់សាងសង់គម្រោងនេះជាមុនសិន។ ចំណុចនេះដូចគ្នានឹងប្រាក់ចំណូលពីការនាំចេញដែរ។ ប្រាក់ចំណូលមានចំនួនច្រើន ប៉ុន្តែប្រាក់ចំណូលសុទ្ធសម្រាប់រដ្ឋាភិបាលជាម្ចាស់គម្រោង មានចំនួនតិចជាងតួលេខនៃប្រាក់ចំណូលសរុបទាំងអស់ និងតួលេខអត្ថប្រយោជន៍របស់ថាមពលដែលលើកឡើង។ ប្រាក់ចំណូលសុទ្ធមានប្រមាណពី ២៦ ទៅ ៣១% នៃប្រាក់ចំណូលសរុបក្នុងរយៈពេលព្រមព្រៀងផ្តល់សម្បទាន។ ចំណុចគួរកត់សម្គាល់នោះគឺ ប្រទេសឡាវ និងកម្ពុជានឹងមិនមានលទ្ធភាពសាងសង់គម្រោងវារីអគ្គិសនីទាំងនេះ ដោយមិនមានការវិនិយោគឯកជនបានឡើយ។ នៅដំណាក់កាលបន្ទាប់នៅពេលការធ្វើសម្បទានរយៈពេលប្រហែល ២៥ឆ្នាំ បានបញ្ចប់ហើយ កម្មសិទ្ធគម្រោងត្រូវផ្ទេរ ទៅឱ្យប្រទេសម្ចាស់គម្រោង នោះអត្ថប្រយោជន៍ហិរញ្ញវត្ថុសរុប នឹងត្រូវផ្តល់ជូនមកប្រទេសម្ចាស់គម្រោងវិញ។

ក្នុងប្រទេសឡាវ ការប្រើប្រាស់ប្រាក់ចំណូលវារីអគ្គិសនី ដើម្បីផ្តល់ជាមូលនិធិសម្រាប់ការចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសង្គម (រួមមានការចំណាយលើការសាងសង់ផ្លូវថ្នល់តាមជនបទ សុខភាព និង

វិស័យអប់រំ) ត្រូវបានចាត់ចែងរួចជាស្រេចនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ និងយុទ្ធសាស្ត្រកាត់បន្ថយបំបាត់ភាពក្រីក្រ និងកំណើនជាតិ។

**បរិមាណថវិកាដ៏ច្រើន ដែលបានមកពីការវិនិយោគផ្ទាល់ពីបរទេសមកប្រទេសឡាវ និងកម្ពុជាសម្រាប់ការអនុវត្តគម្រោងវារីអគ្គិសនីតាមទន្លេមេ (មានប្រមាណ ២៥ កោដិដុល្លាអាមេរិក ប្រសិនបើគម្រោងទាំង ១២ នឹងដំណើរការ) ហាក់ដូចជានាំមកនូវការរីកចំរើនផ្នែកសេដ្ឋកិច្ចយ៉ាងខ្លាំងដល់ប្រទេសម្ចាស់គម្រោងក៏ដូចជាតំបន់ទាំងមូល** គឺដោយសារមានតម្រូវការធនធានបន្ថែម (ពលកម្ម សម្ភារៈសំណង់ ធនធាន និងសេវាវិស្វកម្ម)។ ការចំណាយបន្ថែមរបស់រដ្ឋាភិបាល ដោយសារប្រាក់ចំណូលកើនឡើងពីវារីអគ្គិសនី ក៏អាចចូលរួមចំណែកដល់ការជំរុញសេដ្ឋកិច្ចនេះផងដែរ។

**ប្រទេសឡាវទំនងជាមានកំណើនសេដ្ឋកិច្ច តាមរយៈការវិនិយោគលើវារីអគ្គិសនីតាមទន្លេមេ នៃទន្លេមេគង្គនេះ។** ឥទ្ធិពលជំរុញកំណើនសេដ្ឋកិច្ចហាក់ដូចជាមានទំហំធំ បើទោះជាលំហូរវិនិយោគផ្ទាល់ពីបរទេសដែលមានយ៉ាងតិចបំផុត ៥០% ដែលទាក់ទងនឹងគម្រោងវារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គទាំងនេះ ត្រូវប៉ាន់ប្រមាណថា នឹងត្រូវចំណាយលើធនធាននៅក្រៅប្រទេសម្ចាស់គម្រោងក៏ដោយ។

ហានិភ័យ ដែលអាចកើតមានឡើងនោះ គឺការអភិវឌ្ឍនៃអតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ដោយសារកំណើនឡើងខ្ពស់នៃវិស័យវារីអគ្គិសនី ជាពិសេសក្នុងប្រទេសឡាវ បើគិតអំពីទំហំនៃការវិនិយោគវារីអគ្គិសនី និងសេដ្ឋកិច្ចរបស់ប្រទេសនេះ និងការកើនឡើងនូវបំណុលរបស់រដ្ឋាភិបាលចំពោះការផ្តល់មូលនិធិសម្រាប់ចំណែកសមធម៌ក្នុងគម្រោងវារីអគ្គិសនីនេះ។ លក្ខណៈ និងទំហំនៃឱកាស និងហានិភ័យខុសគ្នាយ៉ាងខ្លាំងក្នុងជីវិតនៃគម្រោងតាមទន្លេមេមួយ។

**គម្រោងតាមទន្លេមេនានា អាចមានផលប៉ះពាល់ជាអវិជ្ជមានជាច្រើនមកលើវិស័យជលផល និង វិស័យកសិកម្ម។** ប្រសិនបើគម្រោងទាំងអស់ត្រូវបន្តអនុវត្ត នោះការបាត់បង់ធនធានជលផលដោយផ្ទាល់ ដោយសារទំនប់វារីអគ្គិសនីតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម នឹងមានតម្លៃប្រមាណ ៤៧៦លានដុល្លាអាមេរិក ក្នុងមួយឆ្នាំ ដោយមិនគិតពីផលប៉ះពាល់ចំពោះវិស័យជលផលតាមតំបន់ឆ្នេរ និងតំបន់ដែនដីសណ្តទន្លេមេគង្គ ដែលហាក់ដូចជាមានទំហំធំផងដែរ ប៉ុន្តែនៅមិនទាន់បានសិក្សានៅឡើយ។ លើសពីនេះ ដំណាំនៅតាមដងទន្លេប្រមាណ ៥៤ % នៃដំណាំតាមច្រាំងទន្លេមេគង្គនឹងត្រូវខូចខាត ដែលគិតបញ្ចូលទាំងការខូចខាតដីកសិកម្មនៅតាមទន្លេមេ ហើយបង្គោល និងខ្សែបណ្តាញបញ្ជូនអគ្គិសនី ត្រូវគេប៉ាន់ស្មានថាមានតម្លៃ ២៥,១ លានដុល្លាអាមេរិកក្នុងមួយឆ្នាំ។ តាមការប៉ាន់ស្មាន ការធ្លាក់ចុះនៃដីល្បាប់មានជីជាតិនឹងតម្រូវឱ្យមានការចំណាយប្រមាណ ២៤ លានដុល្លាអាមេរិកក្នុងមួយឆ្នាំ ដើម្បីរក្សាផលិតភាពនៃវិស័យកសិកម្មតាមតំបន់លិចទឹក ពោលគឺមាន ៣៣% ទទួលរងការខូចខាតដោយសារវារីអគ្គិសនីតាមទន្លេមេនៃអាងទន្លេមេគង្គក្រោមនេះ។ គេរំពឹងថា ផលចំណេញ

ទទួលបានមានតម្លៃជាទឹកប្រាក់ប្រមាណ ១៨លានដុល្លាអាមេរិកក្នុងមួយឆ្នាំសំរាប់វិស័យជលផល និង ១៥,៥ ដុល្លាអាមេរិកក្នុងមួយឆ្នាំសម្រាប់វិស័យធារាសាស្ត្រ។

**ផលប៉ះពាល់លើវិស័យជលផល និងវិស័យកសិកម្មអាចកាត់បន្ថយតែចំណែកណាមួយប៉ុណ្ណោះ។** ផ្ទៃអាងដែលបានស្នើឡើងមានសមត្ថភាពផលិតធនធានជលផលបានចំនួន ១០% នៃធនធានជលផលដែលបាត់បង់។ ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិស័យធារាសាស្ត្រ អាចកាត់បន្ថយនៅផ្នែកណាមួយ ប្រសិនបើមានមូលធនគ្រប់គ្រាន់សម្រាប់វិនិយោគលើការបំពាក់សម្ភារៈធារាសាស្ត្រឡើងវិញ ក្នុងការប្រើប្រាស់ទឹកនៅតាមអាងស្តុកទឹក[១៣]។

**គម្រោងផលិតថាមពលវារីអគ្គិសនីតាមដងទន្លេមេនឹងបង្កឱ្យមានការកើនឡើងនូវវិសមភាព ក្នុងបណ្តាប្រទេសតាមអាងទន្លេមេគង្គក្រោម។** អត្ថប្រយោជន៍បានពីវារីអគ្គិសនីអាចផ្តល់ឱ្យអ្នកប្រើប្រាស់អគ្គិសនី ដោយប្រើប្រាស់បង្គោលអគ្គិសនីរបស់ជាតិ ក្រុមហ៊ុនសាងសង់ អ្នកផ្តល់ហិរញ្ញវត្ថុ និងរដ្ឋាភិបាលជាម្ចាស់ ប៉ុន្តែការចំណាយភាគច្រើនធ្លាក់ទៅលើសហគមន៍ក្រីក្រ និងងាយរងគ្រោះដែលរស់នៅតាមដងទន្លេ និងវិស័យសេដ្ឋកិច្ចមួយចំនួន។ អត្ថប្រយោជន៍ក៏មិនបានចែករំលែកឱ្យបានស្មើគ្នាក្នុងចំណោមប្រទេសទាំងអស់ដែរ។ ប្រសិនបើគម្រោងទាំងអស់ត្រូវដំណើរការនោះ ប្រទេសវៀតណាម និងកម្ពុជាហាក់ដូចជាត្រូវទទួលរងការខាតបង់រយៈពេលខ្លី និងមធ្យម ដោយសារផលប៉ះពាល់រួមគ្នាមកលើវិស័យជលផល និងកសិកម្ម នឹងមានបរិមាណច្រើនជាងអត្ថប្រយោជន៍ ដែលទទួលបានពីវិស័យថាមពល។

**ក្នុងរយៈពេលខ្លីទៅមធ្យម ភាពក្រីក្រនឹងកាន់តែមានសភាពធ្ងន់ធ្ងរ ដោយសារតែគម្រោងណាមួយនៃគម្រោងតាមទន្លេមេទាំងនេះ ជាពិសេសក្នុងចំណោមតំបន់ក្រីក្រនៅតាមទីជនបទ និងតំបន់តាមដងទន្លេក្នុងទីក្រុង។** ជាពិសេសជាងនេះទៀត អ្នកនេសាទជាច្រើន ដែលមាននៅក្នុងសហគមន៍តាមអាងទន្លេមេគង្គក្រោមក្រីក្រ និងងាយទទួលរងគ្រោះ នឹងរងផលប៉ះពាល់ដោយសារការខាតបង់ធនធានជលផលទាំងនេះ។ គ្រួសារក្រីក្រជាងនេះក៏នឹងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារផលប៉ះពាល់ដោយផ្ទាល់ពីការសាងសង់វារីអគ្គិសនីដែររួមមានការតាំងទីលំនៅថ្មី ការបាត់បង់ដី និងផលប៉ះពាល់ក្នុងអំឡុងពេលការចុះកិច្ចសន្យា។ ការខាតបង់ធនធានជលផល និងសារធាតុចិញ្ចឹមពាក់ព័ន្ធ នឹងបណ្តាលឱ្យមានភាពទ្រុឌទ្រោមផ្នែកសុខភាព ដោយសារកង្វះសារធាតុចិញ្ចឹមក្នុងចំណោមប្រជាជនដែលរស់នៅតាមអាងទន្លេមេគង្គក្រោម ជាពិសេសក្នុងប្រទេសកម្ពុជា និងឡាវ ដែលក្នុងនោះការផ្គត់ផ្គង់សារធាតុចញ្ចឹមរបស់ប្រទេសប្រមាណ ៣០% នឹងស្ថិតក្នុងសភាពគ្រោះថ្នាក់ ប្រសិនបើទំនប់តាមទន្លេមេត្រូវសាងសង់ឡើង។ បញ្ហាសន្តិសុខស្បៀងនេះ ហាក់ដូចជាជះឥទ្ធិពលដល់ប្រជាជនក្រីក្រនៅទីជនបទ និងប្រជាជននៅទីក្រុង។ លើសពីនេះ កំណើនភាពក្រីក្រតាមទីជនបទហាក់ដូចជា ដើរតួជាកត្តារុញច្រានមួយទៀតដល់ការធ្វើចំណាកស្រុកពីទីជនបទមកទីក្រុង ដែលបង្កឱ្យមានភាពក្រីក្រនៅទីក្រុង។

---

[១៣] ក្នុងករណីជាច្រើន ការផ្លាស់ប្តូរប្រព័ន្ធធារាសាស្ត្រ ដែលមានស្រាប់អាចទទួលបានថវិកាឧបត្ថម្ភ ដែលជាផ្នែកនៃការចំណាយសងការខូចខាតរបស់គម្រោង។

**ការលើកកម្ពស់កិច្ចសហប្រតិបត្តិការសំខាន់ៗនៅថ្នាក់តំបន់ សមត្ថភាពស្ថាប័ន និងសមត្ថភាពផ្លូវច្បាប់ គឺត្រូវការជាចាំបាច់សម្រាប់ការគ្រប់គ្រប់គម្រោងតាមទន្លេមេនៃទន្លេមេគង្គ និងវិធានការក្នុងការកាត់បន្ថយផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាព។** នៅទូទាំងពិភពលោក មានយន្តការចែករំលែកផលប្រយោជន៍ និងវិធានការកាត់បន្ថយផលប៉ះពាល់សម្រាប់វិស័យសេដ្ឋកិច្ចដែលរងផលប៉ះពាល់ ដែលបានបង្ហាញឱ្យឃើញថា ទទួលបានជោគជ័យក្រោមបរិបទស្ថាប័នជាក់លាក់។ ភាពជោគជ័យនៃវិធានការកាត់បន្ថយផលប៉ះពាល់ទ្រទ្រង់ធំ ត្រូវដោះស្រាយបញ្ហាហានិភ័យ និងឱកាស និងការផ្តល់មូលនិធិដល់វិធានការទាំងនេះ (ឧទាហរណ៍ យន្តការបែងចែកផលប្រយោជន៍ពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន និងយន្តការបែងចែកផលប្រយោជន៍ឆ្លងដែន) នឹងត្រូវពឹងផ្អែកលើការកសាងសមត្ថភាពស្ថាប័នគ្រប់គ្រង និងបច្ចេកទេសឱ្យបានកាន់តែប្រសើរឡើង ក្នុងប្រទេសម្ចាស់គម្រោង និងថ្នាក់តំបន់ឱ្យបានទាន់ពេលវេលា សម្រាប់ការសាងសង់គម្រោង និងកាលបរិច្ឆេទចាប់ផ្តើមដំណើរការគម្រោង[១៤]។

**ការអភិវឌ្ឍទំនប់វារីអគ្គិសនីតាមទន្លេមេអាចលើកកម្ពស់លក្ខខណ្ឌការធ្វើចរាចរសម្រាប់នាវាធំៗ** នៅពេលមានការវិនិយោគយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ការលើកកម្ពស់មធ្យោបាយដឹកជញ្ជូនគំរូផ្សេងៗ ព្រមទាំងការត្រួតពិនិត្យ និងវាយតម្លៃផ្លូវទឹកសម្រាប់ធ្វើចរាចរ ដោយមានការសន្យាយ៉ាងមុតមាំក្នុងការប្រើប្រាស់ថវិកាសម្រាប់អភិវឌ្ឍមធ្យោបាយធ្វើដំណើរតាមផ្លូវទឹកសាបក្នុងទន្លេមេគង្គលើ។ ការសម្អាតផ្លូវទឹក ដែលមានទ្រង់ទ្រាយធំនៅភាគខាងលើស្ទឹងប៉ាកបេង នឹងចាំបាច់ត្រូវធ្វើឡើងដើម្បីបង្កភាពងាយស្រួលដល់ការឆ្លងកាត់ ហើយចំណែកឯផ្លូវចរាចរពីទីក្រុងភ្នំពេញទៅសមុទ្រវិញ អាចជួបនឹងបញ្ហាអស្ថេរភាពផ្លូវទឹក ដែលនឹងត្រូវបានគ្រប់គ្រងតាមរយៈការប្រឹងប្រែងបន្ថែមទៀតដើម្បីរក្សាស្ថេរភាពច្រាំងទន្លេនេះ។ ការភ្ជាប់គ្នារវាង មធ្យោបាយដឹកជញ្ជូនទំនិញតូចតាច និងអ្នកដំណើរនឹងត្រូវកាត់បន្ថយ។ ពុំមានមធ្យោបាយកាត់បន្ថយផលប៉ះពាល់ណាមួយដែលអាចចំណេញផ្នែកសេដ្ឋកិច្ច សម្រាប់ការធ្វើដំណើរតូចតាច និងការប្រើប្រាស់របស់សហគមន៍ទេ។

## សុខដុមភាព និងភាពចម្រុះនៃប្រព័ន្ធអេកូឡូស៊ី

**គម្រោងតាមទន្លេមេនៃទន្លេមេគង្គ អាចធ្វើឱ្យខូចខាតដល់បណ្តាញ នៃខ្សែបណ្តោយរបស់ប្រព័ន្ធអេកូឡូស៊ីទន្លេមេគង្គ ដោយធ្វើការបែងចែកប្រព័ន្ធអេកូឡូស៊ីទាំងនេះជាផ្នែកតូចៗ ហើយមិនសូវមានផលិតភាព។** វារីអគ្គិសនីតាមទន្លេមេដែលបានស្នើឡើង គឺផ្តាច់តុល្យភាពខ្លាំងក្លាដែលកំពុងមានពេលបច្ចុប្បន្នរបស់ទន្លេមេគង្គ ដែលកន្លងមកបានបំលែងសក្តានុពលថាមពលជាច្រើន និងថាមពលបង្កើតឡើងដោយចលនារបស់ប្រព័ន្ធទន្លេមេគង្គ ទៅជាដំណើរការតាមលក្ខណៈអេកូស៊ី និងរូបសណ្ឋានទន្លេមេគង្គតាមបណ្តោយទន្លេទាំងមូល។

គម្រោងតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម ត្រូវបានស្នើឡើងក្នុងអំឡុងពេលដែលរបបទឹកទន្លេមេគង្គទទួលរងការផ្លាស់ប្តូរយ៉ាងខ្លាំងដោយសារការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃទំនប់វារីអគ្គិសនីនៅតាមដៃទន្លេ

[១៤] ការបែងចែកផលប្រយោជន៍ ជាពិសេសការបែងចែកប្រាក់ចំណូលគឺដើរតួនាទីយ៉ាងសំខាន់ ក្នុងការធានាឱ្យបានថា ផលប្រយោជន៍ដែលទទួលបាននៅថ្នាក់តំបន់ ឬថ្នាក់ជាតិ បានផ្ទេរទៅថ្នាក់មូលដ្ឋាន។

ទន្លេមេគង្គក្រោម និងនៅតាមទន្លេមេនៃអាងទន្លេមេគង្គលើក្នុងខេត្តយូណានប្រទេសចិន។ **គម្រោងតាមទន្លេមេនៃអាងទន្លេមេគង្គក្រោមអាចមានផលប៉ះពាល់បន្ថែមយ៉ាងខ្លាំងដល់ផ្នែអាងទាំងមូល ជាពិសេសចលនារបស់ទឹក និងកំទេចកំណកក្នុងប្រព័ន្ធអាងទន្លេមេគង្គ រួមទាំងតំបន់ឆ្នេរ និងតំបន់សមុទ្រ។**

ទន្លេមេគង្គមានចរន្តទឹកជំនន់ខ្លាំង ដែលធ្វើការបែងចែកដោយរដូវកាលដាច់ដោយឡែក ៤ ផ្សេងគ្នា និងការឆ្លើយតបទៅនឹងការឡើងចុះនៃកម្រិតទឹក។ វារីអគ្គិសនីតាមដៃទន្លេនៅអាងទន្លេមេគង្គក្រោម និងវារីអគ្គិសនីនៅប្រទេសចិន នឹងបង្កផលប៉ះពាល់ដល់ពេលវេលា និងរយៈពេលនៃរដូវកាលទាំងនេះ។ **ការអនុវត្តគម្រោងតាមដៃទន្លេនៅតាមទន្លេមេគង្គក្រោម ធ្វើឱ្យភាគខាងលើនៃតំបន់ ២ (ខេត្តចៀង សែននៅប្រទេសថៃ ដល់ទីក្រុង ហ្លួងប្រាបាងប្រទេសឡាវ) និងរាល់ទីតាំងដែលទទួលរងទឹកជំនន់ពីអាងទន្លេមេគទាំងអស់ មិនមានរដូវកាលអន្តរកាល ដែលមានតម្លៃជាសំខាន់តាមលក្ខណៈអេកូឡូស៊ីទៀតឡើយ។** រាល់ទីតាំងដែលទទួលទឹកពីទន្លេមេគង្គទាំងអស់នឹងជួបប្រទះនូវការធ្លាក់ចុះនៃរយៈពេលរបស់រដូវកាលអន្តរកាល ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញដំណើរការជីវសាស្ត្រ ក្នុងទីជម្រកតាមដងទន្លេ និងតាមទំនាបលិចទឹក។

ជញ្ជាំងទំនប់វារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គក្រោមមានកម្ពស់ខ្ពស់គ្រប់គ្រាន់ ដែលនឹងធ្វើឱ្យកម្ពស់ទឹកក្នុងអាងរយៈចម្ងាយប្រមាណ ១០ គីឡូម៉ែតពីខាងលើទំនប់ ហើយដែលកម្ពស់ទឹកនេះមិនធ្លាប់មានទេក្នុងកំណត់ត្រាពីមុនមក។ ការផ្លាស់ប្តូរកម្ពស់ទឹកអាចធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ធ្ងរឡើង អាស្រ័យលើយុទ្ធសាស្ត្រប្រតិបត្តិការរបស់គម្រោងទំនប់វារីអគ្គិសនី។ ការប្រតិបត្តិការនៅពេលមានតម្រូវការប្រើប្រាស់ច្រើន (ដូចជាការបង្កើនឱ្យដល់កម្រិតអតិបរមានៃការបញ្ចេញទឹកពីឧបករណ៍ផលិតអគ្គិសនី (Turbine) នៅពេលមានការប្រើប្រាស់ភ្លើង មានកំណើនខ្ពស់ម្តង ឬពីរដងក្នុងមួយថ្ងៃ) អាចបង្កើនល្បឿននៃទឹកតំឡើង និងចំនួននៃការឡើងចុះរបស់ទឹកពីរដូវកាលទៅជាប្រចាំថ្ងៃ ឬ ប្រចាំម៉ោង។ **សក្តានុពលនៃការឡើងទឹក ក្នុងរយៈប៉ុន្មានម៉ោង អាចធ្វើឱ្យកម្ពស់ទឹកឡើងដល់ ៣ ទៅ ៦ ម៉ែត្រ នៅតាមទីប្រជុំជន និងភូមិមួយចំនួន ដែលស្ថិតនៅចម្ងាយ ៤០ ទៅ ៥០ គីឡូម៉ែត្រផ្នែកខាងក្រោមទំនប់។** ប្រសិនបើការបង្ហូរទឹកដោយមិនមានផែនការ ឬការបង្ហូរទឹកបន្ទាន់ ព្រឹត្តការណ៍ប្រតិបត្តិការអតិបរមា អាចមានទ្រង់ទ្រាយធំ ហើយទឹកអាចហូរដល់ភូមិនៅផ្នែកខាងក្រោមទន្លេក្នុងរយៈពេល ១ ទៅ ២ ម៉ោងដោយមានពេលវេលាតិចតួចសម្រាប់ជូនដំណឹងជាមុន។

គម្រោងតាមទន្លេមេនីមួយៗដាច់ដោយឡែក មិនជះឥទ្ធិពលដល់តំបន់លិចទឹក ឬរយៈពេលលិចទឹកនៅតាមទំនាបលិចទឹកប្រទេសកម្ពុជា និងទំនាបលិចទឹកតាមតំបន់ដីសណ្តរ ឬក៏វិសាលភាព និងរយៈពេល នៃការជ្រាបចូលរបស់ទឹកសមុទ្រចូលក្នុងទឹកឡើយ។ ផលប៉ះពាល់បន្ថែមរបស់គម្រោងតាមដងទន្លេទាំងអស់ ទាក់ទឹងនឹងកត្តាទាំងនោះ ត្រូវមានការសិក្សាបន្ថែម ដោយហេតុថាគម្រោងទាំងនោះអាចមានសមត្ថភាពស្តុក ទឹករយៈពេល ៤ ទៅ ៥ សប្តាហ៍ ឬលើសពីនេះ អាស្រ័យលើវិធីសាស្ត្រប្រតិបត្តិការរបស់គម្រោង។

តាមការប៉ាន់ប្រមាណ បរិមាណនៃកំណកកករ ក្នុងទន្លេមេគង្គមានចំនួនប្រមាណ ១៦០ ទៅ ១៦៥ លានតោន ក្នុងមួយឆ្នាំ។ គម្រោងក្នុងប្រទេសចិន និងនៅតាមទន្លេសេសាន សេកុង ស្រែពក (3S) ធ្វើការស្តារបរិមាណកករនោះចេញ រួចយកទៅទុកក្នុងទំនប់វារីអគ្គិសនីដែលមានអាងស្តុកទឹក នៅពេលបន្ទុកលើសពី ៥០ភាគរយ។ **ចំពោះគម្រោងតាមទន្លេមេនៅអាងទន្លេមេគង្គក្រោមទាំង ១២ គឺធ្វើការបូមចេញពាក់កណ្តាល (ឧទាហរណ៍ នៅខេត្តក្រចេះ) នៅពេលបន្ទុកកំទេចកំណរ មានបរិមាណប្រមាណ ២៥% នៃបរិមាណសរុប (ប្រហែល ៤២ លានតោន ក្នុងមួយឆ្នាំ)។** ការកាត់បន្ថយបរិមាណកំទេចកំណរនេះ មានទំនាក់ទំនងជាសំខាន់ចំពោះការហូរនាំនៃដីល្បាប់ដែលផ្តល់ជីធម្មជាតិដល់ប្រព័ន្ធ ទន្លេសាប និង ផ្ទៃដីប្រមាណ ២៣.០០០ ដល់ ២៨.០០០ គីឡូម៉ែតការ៉េ នៃទំនាបទឹកជំនន់ក្នុងប្រទេសកម្ពុជា និងប្រទេសវៀតណាម រួមនឹងការធ្វើឱ្យមានអស្ថេរភាពផ្លូវទឹកទន្លេ ទំនាបមេគង្គ និងខ្សែឆ្នេរនៃតំបន់ដីសណ្តទន្លេមេគង្គ។

ការប្រែប្រួលអាកាសធាតុ បន្ថែមនូវហានិភ័យ និងភាពមិនប្រាកដប្រជា ក្នុងការធ្វើផែនការរយៈពេលយូរអង្វែង ដោយអាចមានទាំងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានទៅលើការអភិវឌ្ឍវារីអគ្គិសនីក្នុងផ្ទៃអាងទន្លេ។ **ការប្រែប្រួលអាកាសធាតុបង្កើននូវការប្រឈមនឹងហេតុការណ៍បរិយាកាសធ្ងន់ធ្ងរ ក្នុងវដ្តជីវិតរបស់គម្រោងតាមទន្លេមេ បូករួមទាំងកត្តាទាំងឡាយដែលជាខ្សែបន្ទាត់សុវត្ថិភាពក្នុងការសាងសង់ទំនប់វារីអគ្គិសនី។** ប្រសិនបើមិនមានការយកចិត្តទុកដាក់ឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការរៀបចំ និងដាក់វិធានការសុវត្ថិភាព ការកើនឡើងនៃការប្រឈមនឹងហេតុការណ៍បរិយាកាសធ្ងន់ធ្ងរ ដោយសារការប្រែប្រួលអាកាសធាតុអាចបង្កើននូវហានិភ័យនៃការបាក់ធ្លាក់នៃទំនប់ ក៏ដូចជាការមិនដំណើរការនៅផ្នែកណាមួយដ៏សំខាន់នៃប្រព័ន្ធធារាសាស្ត្រ (ឧទាហរណ៍ ទ្វារទប់ទឹក)។

**គម្រោងតាមទន្លេមេនៃទន្លេមេគង្គ ហាក់ដូចជាបណ្តាលឱ្យមានភាពខ្ទេចខ្ទាំផ្នែកបរិស្ថានដ៏ធ្ងន់ធ្ងរ និងមិនអាចដោះស្រាយបាន បណ្តាលអោយបាត់បង់សុខភាព និងផលិតភាពរយៈពេលយូរអង្វែងរបស់ប្រព័ន្ធធម្មជាតិ និងការបាត់បង់នូវជីវចម្រុះ និងសុខុមភាពរបស់ប្រព័ន្ធអេកូឡូស៊ី។ ផលប៉ះពាល់ធំបំផុតទៅលើប្រព័ន្ធទន្លេមេគង្គលើដីតាមដងទន្លេ នឹងប៉ះពាល់ដល់តំបន់ដីសើម។** តំបន់ដីសើមទន្លេមេគង្គ ស្ទើរតែ ៤០ភាគរយ ស្ថិតនៅតាមទីតាំងទន្លេ ដែលគេគ្រោងនឹងសាងទំនប់វារីអគ្គិសនី។ ១៧ភាគរយនៃតំបន់ដីសើមទាំងនេះ នឹងទទួលរងទឹកជំនន់ជាអចិន្ត្រៃយ៍ពីគម្រោងវារីអគ្គិសនីតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម។

**គម្រោងវារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ អាចមានផលប៉ះពាល់នៅមូលដ្ឋានយ៉ាងខ្លាំងដល់ផលិតភាពវិស័យកសិកម្ម។** ដីកសិកម្មប្រមាណ ១៣៥.០០០ ហិកតា អាចទទួលរងការលិចលង់ដោយសារតែគម្រោងចំនួន ១១ និងការប្រើប្រាស់ដីសម្រាប់ធ្វើបង្គោលភ្លើង និងធ្វើផ្លូវ។ ដី ១៥០.០០០ ហិកតា នៃសួនដំណាំតាមមាត់ទន្លេ ដីកសិកម្ម និងប្រព័ន្ធធារាសាស្ត្រនឹងទទួលផលប៉ះពាល់ដោយផ្ទាល់ដោយសារផ្ទៃអាងទឹកប្រវែង ៩៩៦ ដែលបង្កើតឡើងដោយគម្រោងចំនួន ១១ រវាងខេត្ត ចៀងសែន និងខេត្តក្រចេះ

(គំនូសតាងទី៣)[១៥]។ ដីកសិកម្មទទួលរងផលប៉ះពាល់ចំនួន ២២ ភាគរយ នឹងបាត់បង់ជាអចិន្ត្រៃយ៍ ដោយសារទឹកជំនន់ និងការកាប់ឆ្ការ ហើយការ ប្រើប្រាស់ និងផលិតភាពរបស់ដីនៅសល់ចំនួន ៨០ភាគរយ សម្រាប់ប្រព័ន្ធធារាសាស្ត្រ នឹងជួបប្រទះនឹងភាពស្មុគស្មាញកាន់តែច្រើននៅក្នុងការគ្រប់គ្រង និងការប្រតិបត្តិក្នុង ប្រព័ន្ធធារាសាស្ត្រ (ឧទាហរណ៍ កម្ពស់ទឹកមានការប្រែប្រួលនៅរៀងរាល់ម៉ោង ឬប្រចាំថ្ងៃ) ដែលតម្រូវឱ្យ មានការវិនិយោគបន្ថែម ដើម្បីដោះស្រាយបញ្ហាទាំងនេះ។

[១៥] គម្រោងតាមដងទន្លេទី ១២ ឈ្មោះថា ថា ខូ មិនមានផ្ទៃអាងស្តុកទឹក ដូច្នេះហើយមិនបង្កឱ្យមានទឹកជំនន់លិចដីឡើយ។

**គំនូសតាងទី៧: ផ្ទៃអាងតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម** : *៥៥ភាគរយនៃទន្លេមេគង្គ (ពីខេត្ត ចៀងសែនប្រទេសថៃ ដល់ខេត្តក្រចេះប្រទេសកម្ពុជា) នឹងត្រូវប្តូរទៅជាអាងស្តុកទឹក។*




**ទំនប់តាមទន្លេមេនៃអាងទន្លេមេគង្គក្រោមជះឥទ្ធិពលជាមូលដ្ឋានដល់សុខុមភាព និងផលិតភាពរបស់ប្រព័ន្ធទឹកទន្លេមេគង្គ** ដោយ: (១) លិចទឹកជាប្រចាំនៅតាមទីជម្រកក្នុងទឹកជាច្រើនក្នុងទន្លេ (២)

ភាពខុសគ្នាតាមរដូវកាលនៃវដ្តទឹកទន្លេនៅកំរិតមូលដ្ឋានមានសភាពកាន់តែធ្ងន់ធ្ងរឡើង និង (៣) កាត់ផ្តាច់ចរាចររបស់កំទេចកំណរ និងសារធាតុចិញ្ចឹម រវាងតំបន់នៅភាគខាងលើ និងទំនាបលិចទឹក។ **បើគិតលើការបាត់បង់ទីជម្រកតែមួយមុខ គឺគម្រោងតាមទន្លេមេនៃទន្លេមេគង្គបង្កឱ្យមានការធ្លាក់ចុះនៃផលិតភាពចំបងរបស់ប្រព័ន្ធវារីជាតិប្រមាណពី ១២ ទៅ ២៧ភាគរយ (ឧទាហរណ៍ ផលិតភាពរបស់រុក្ខជាតិ) ដោយមានពាក់ព័ន្ធនឹងផលិតភាពទូទៅរបស់ទន្លេ និងក្នុងអាងស្តុកទឹកផ្ទាល់**។ បើគិតពីការធ្លាក់ចុះនៃបរិមាណសារធាតុចិញ្ចឹមប្រមាណ ៧៥ ភាគរយដែលបង្ករដោយផលប៉ះពាល់នៃទំនប់តាមទន្លេមេនៃទន្លេមេគង្គទាំងអស់ នោះផលិតភាពដំបូងអាចមានការធ្លាក់ចុះនៅសល់ត្រឹមអត្រាទាប បើប្រៀបធៀបនឹងតម្លៃនាពេលបច្ចុប្បន្ន ហើយការធ្លាក់ចុះនេះនឹងមានផលប៉ះពាល់ជាសំខាន់ដល់ចង្វាក់ផលិតចំណីក្នុងទឹក ដល់ទីជម្រកត្រី និងវិស័យជលផល។ បើគិតតាមការប៉ាន់ស្មានសាមញ្ញមួយ គម្រោងទំនប់តាមទន្លេមេនៃទន្លេមេគង្គក្រោម ត្រូវគេរំពឹងថាបង្កឱ្យមានការធ្លាក់ចុះចំនួន ១ភាគ៣ នៃបរិមាណសារធាតុចិញ្ចឹម និងកំទេចកំណរនៅតាមទន្លេមេគង្គ។ ទន្ទឹមនឹងនេះក៏មានការប៉ាន់ប្រមាណថា នៅត្រឹមឆ្នាំ ២០៣០ ការសាងសង់ទំនប់ទាំង៨ នៅខេត្តយូណានប្រទេសចិន និងនៅតាមដៃផ្សេងៗទៀតបង្កឱ្យ មានការធ្លាក់ចុះចំនួន ២ភាគ៣ នៃសារធាតុទាំងនេះ។

**គម្រោងតាមទន្លេមេ អាចបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ប្រព័ន្ធអេកូឡូស៊ី ដែលមានសារៈសំខាន់ជាអន្តរជាតិ ដល់សត្វនិងត្រីជាច្រើនប្រភេទ និងប្រភេទសត្វទទួលរងគ្រោះជាសាកល ដែលអាចនឹងផុតពូជ**។ ការបាត់បង់ទីជម្រកអាចជំរុញឱ្យមានការកើនឡើងនូវប្រភេទត្រី និងសត្វទូទៅដែលមិនធ្វើបំលាស់ទីឆ្ងាយ អាចធ្វើការពងកូនក្នុងទឹកនៅតាមដែនអាងស្តុកទឹក ហើយមិនត្រូវការទីជម្រកលក្ខណៈជាក់លាក់ ឬមួយការជំរុញពីចលនារបស់ទឹកដើម្បីធ្វើការទំលាក់ពង។ ចំណែកឯប្រភេទដែលត្រូវការលក្ខខណ្ឌចាំបាច់ទាំងនោះ (ឧទាហរណ៍ត្រីប្រា) អាចនឹងមានការធ្លាក់ចុះយ៉ាងខ្លាំង។ ការបែងចែកជាបំណែកតូចៗ នៃប្រព័ន្ធទន្លេ អាចធ្វើឱ្យពពួកវារីសត្វមួយចំនួនរស់នៅដាច់ដោយឡែកក្នុងទីតាំងណាមួយដែលអាចបណ្តាលឱ្យមានការបាត់បង់នូវប្រភេទទាំងនេះ។ ប្រសិនបើរាល់គម្រោងតាមទន្លេមេនៃទន្លេមេគង្គទាំងអស់ត្រូវធ្វើឡើងនោះ ៥៥ភាគរយ នៃទន្លេមេគង្គចាប់ពីខេត្តចៀង សែន ដល់ខេត្តក្រចេះ ត្រូវប្រែក្លាយទៅជាផ្ទៃអាង ដោយផ្លាស់ប្តូរពីបរិស្ថានទន្លេ ទៅបរិស្ថានបឹង (គំនូសតាងទី៣)។ យ៉ាងហោចណាស់ មានត្រីទន្លេចំនួន ៤១ ប្រភេទ ដែលមានតែក្នុងទន្លេមេគង្គភាគខាងលើនៃទីក្រុងវៀងច័ន្ទនឹងទទួលរងការគំរាមកំហែង។

**ការបាត់បង់ជីវចម្រុះនៅអាងទន្លេមេគង្គក្រោម គឺជាការបាត់បង់ជាអចិន្ត្រៃយ៍ របស់ពិភពលោក និងមិនអាចជំនួសមកវិញ ហើយការបាត់បង់នេះមិនអាចទូទាត់សងបានឡើយ**។ ផលប៉ះពាល់ភាគច្រើនរបស់ទំនប់វារីអគ្គិសនីតាមទន្លេមេរបស់អាងទន្លេមេគង្គក្រោមទៅលើប្រព័ន្ធអេកូឡូស៊ីទឹក មិនអាចជៀសផុតបានឡើយ។

ការទាញយកថាមពលសម្រាប់វារីអគ្គិសនីតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម (រហូតដល់ទៅ ១៤.៦៩៧ មេហ្គាវ៉ាត់) នឹងកាត់បន្ថយនូវថាមពលសមស្របសម្រាប់ដំណើរការអេកូ និងរូបសណ្ឋានវិទ្យាពី

ធម្មជាតិរបស់ទន្លេមេគង្គ។ ហេតុនេះ **ផលប៉ះពាល់ធ្ងន់ធ្ងរភាគច្រើនទៅគម្រោងតាមដងទន្លេមេនៃទន្លេមេគង្គ ដែលទាក់ទងទៅនឹងលក្ខណៈជលសាស្ត្រ លក្ខណៈរូបសណ្ឋាន ចលនារបស់ទីជម្រក និងកំទេចកំណរ របស់ទន្លេមេគង្គ គឺមិនអាចជៀសផុតបានឡើយ**។ ប្រសិនបើមានឱកាសក្នុងការកាត់បន្ថយផលប៉ះពាល់នោះ អ្នកប្រតិបត្តិគម្រោងត្រូវធ្វើការកាត់បន្ថយការផលិតអគ្គិសនី តាមរយៈការផ្លាស់ប្តូរការរៀបចំប្រតិបត្តិការ និងការគ្រប់គ្រងរបស់គម្រោងដែលគេបានស្នើឡើង ហើយការងារនេះត្រូវការការអនុវត្តច្បាប់ដោយអាជ្ញាធរឯករាជ ដែលមានសមត្ថភាពបច្ចេកទេស និងអាណត្តិក្នុងការដាក់កំរិត ឬបទបញ្ជា ដើម្បីអនុវត្តនៅកំរិតអាងទន្លេមេគង្គក្រោម ឬនៅកំរិតអាងទន្លេមេគង្គទាំងមូល បើអាចធ្វើទៅបាន។

ជាទូទៅ ផលប៉ះពាល់លើប្រព័ន្ធអេកូឡូស៊ីលើដី ច្រើនកើតមាននៅកម្រិតមូលដ្ឋាន ហើយអាចធ្វើការកាត់បន្ថយ ឬផ្តល់សំណង ដោយប្រើវិធានការស្តារ និងបង្កើតឡើងនូវប្រព័ន្ធអេកូឡូស៊ី ដែលទទួលរងផលប៉ះពាល់ និងតាមរយៈកម្មវិធីអភិរក្ស ដើម្បីទូទាត់សងនូវការបាត់បង់ទីជម្រកជាអចិន្ត្រៃយ៍។ ប្រព័ន្ធដែលពិបាក បំផុតក្នុងការរក្សា និងស្តារឡើងវិញនោះ គឺតំបន់ដីសើមដែលទទួលរងផលប៉ះពាល់។ ការបាត់បង់តំបន់ដីសើមនៅតាមដងទន្លេមិនអាចធ្វើការទូទាត់សង ឬកកើតឡើងវិញបានឡើយ។

## វិស័យផលផល និងសន្តិសុខស្បៀង

អាងទន្លេមេគង្គ មានសហគមន៍ចំនួន ៧០% ដែលស្ថិតនៅទីជនបទ និងមានវិស័យជលផលទឹកសាបដែលផ្តល់ផលច្រើនជាងគេនៅលើពិភពលោក ហើយសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាជន នៅតែពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិរបស់ទន្លេនេះ។ ហានិភ័យ និងការបាត់បង់ដែលបណ្តាលមកពីដីទន្លេមេគង្គ និងប្រព័ន្ធអេកូឡូស៊ី គឺជាសញ្ញាគំរាមកំហែងដល់ជីវភាពរស់នៅរបស់ប្រជាជនរាប់លាននាក់ ជាពិសេសតាមរយៈការកើនឡើងនូវអសន្តិសុខស្បៀងនៅក្នុងផ្ទៃអាងទន្លេមេគង្គ។ ប្រសិនបើផលិតភាពធនធានធម្មជាតិ ធ្លាក់ចុះ ប្រទេសដែលប្រឈមនឹងហានិភ័យខ្លាំងបំផុតនោះគឺប្រទេសកម្ពុជា និងប្រទេសឡាវ។

ទំនប់វារីអគ្គិសនី ត្រូវបានគ្រោងសាងសង់តាមទន្លេមេនៃអាងទន្លេមេគង្គក្រោម ខណៈដែល វារី អគ្គិសនីតាមដៃទន្លេមេគង្គ បានគំរាមកំហែងរួចទៅហើយដល់ភាពសម្បូរបែប និងទំហំនៃវិស័យជលផលក្នុងទន្លេមេគង្គ។ យ៉ាងហោចណាស់ ទិន្នផលត្រីក្នុងទន្លេមេគង្គ ៣៥ ភាគរយ បានមកពីប្រភេទត្រីដែលបំលាស់ទីរយៈចម្ងាយឆ្ងាយ ហើយការបំលាស់ទីរបស់ត្រីទាំងនេះ នឹងត្រូវរារាំងដោយសារទំនប់វារីអគ្គិសនី។ **គម្រោងវារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ នឹងធ្វើឲ្យធ្លាក់ចុះនូវភាពសម្បូរបែប ផលិតភាព និងភាពចម្រុះរបស់ធនធានត្រីក្នុងទន្លេមេគង្គ** ហើយជះឥទ្ធិពលដល់ប្រជាជនមូលដ្ឋានរាប់លាននាក់ ដែលពឹងផ្អែកលើធនធានទាំងនេះសម្រាប់ធ្វើជាម្ហូបអាហារ និងទ្រទ្រង់ជីវភាពរស់នៅ។

គំនូសតាងទី៤ បង្ហាញពីការបាត់បង់ផលិតកម្មត្រីទន្លេមេគង្គ ដោយសារការសាងសង់ទំនប់វារីអគ្គិសនីតាមដៃទន្លេ និងទំនប់វារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ ដែលគេបានស្នើឡើង។ ជាសង្ខេប នៅត្រឹមឆ្នាំ ២០៣០ :

- តាមការប៉ាន់ស្មានដោយប្រើប្រាស់ទិន្នន័យមូលដ្ឋានក្នុងឆ្នាំ២០០០ បង្ហាញថាការសាងសង់ទំនប់វារីអគ្គិសនីនៅទូទាំងអាង ដោយមានទំនប់ចំនួន ៧៧ នៅលើដៃទន្លេនៃអាងទន្លេមេគង្គក្រោម និងនៅតាមទន្លេមេនៃទន្លេមេគង្គលើនៅប្រទេសចិន នឹងបង្កឱ្យមានការបាត់បង់ផលិតកម្មត្រីប្រមាណ ២១០.០០០ ទៅ ៥៤០.០០០ តោន ឬ ១០ ទៅ ២៦ ភាគរយ *នៅពេលទន្លេមេនៃទន្លេមេគង្គក្រោមមិនទាន់មានទំនប់វារីអគ្គិសនីនៅឡើយ។*
- **ប្រសិនបើទំនប់វារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គក្រោម ចំនួន ១១ ត្រូវបានសាងសង់វិញនោះ ការបាត់បង់សរុបនៃធនធានជលផល គឺមានចាប់ពី ៥៥០.០០០ ដល់ ៨៨០.០០០ តោន ឬពី ២៦ ដល់ ៤២ ភាគរយ បើប្រៀបធៀប នឹងទិន្នន័យមូលដ្ឋានឆ្នាំ ២០០០ ដែលក្នុងនោះ ការបាត់បង់ត្រីចំនួន ៣៤០.០០០ តោន បង្កឡើងដោយទំនប់វារីអគ្គិសនីតាមដងទន្លេមេនៃទន្លេមេគង្គ។ បរិមាណវារីជាតិស្លិតប្រឈមនឹងការបាត់បង់ប្រចាំឆ្នាំ ប្រសិនបើទំនប់វារីអគ្គិសនីទាំង ១១ ត្រូវបានសាងសង់ត្រឹមឆ្នាំ២០៣០ គឺ ១១០ភាគរយនៃផលិតកម្មបសុសត្វប្រចាំឆ្នាំសរុបនាពេលបច្ចុប្បន្នរបស់ប្រទេសកម្ពុជា និងប្រទេសឡាវ។**
- ប្រសិនបើទំនប់តាមទន្លេមេនៃទន្លេមេគង្គចំនួន ៩ ត្រូវបានសាងសង់ឡើងនៅខាងលើល្បាក់ខោនប្រទេសឡាវ នោះធនធានជលផលដែលត្រូវបាត់បង់ មានប្រមាណពី ៣៥០.០០០ ទៅ ៦៨០.០០០ តោន ឬ ១៧ ទៅ ៣២ ភាគរយ បើប្រៀបធៀបនឹងទិន្នន័យមូលដ្ឋានឆ្នាំ ២០០០ ហើយក្នុងនោះការបាត់បង់ចំនួន ១៤០.០០០ តោន គឺដោយសារទំនប់វារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ។
- ប្រសិនបើទំនប់ចំនួន ៦ ត្រូវបានសាងសង់នៅប៉ែកខាងលើទីក្រុងវៀងចន្ទ នោះការបាត់បង់អាចមានពី ២៧០.០០០ ដល់ ៦០០.០០០ តោន ឬ ១៣ ទៅ ២៩ ភាគរយ ដែលត្រូវរំពឹងទុកបើប្រៀបធៀបទៅនឹងស្ថានការណ៍ឆ្នាំ ២០០០ ហើយក្នុងនោះការបាត់បង់ប្រហែល ៦០.០០០ តោន គឺបង្កឡើងដោយទំនប់តាមទន្លេមេនៃទន្លេមេគង្គ ឬក៏ការបាត់បង់សារធាតុចិញ្ចឹមប្រចាំឆ្នាំស្មើនឹង ៦០ភាគរយ នៃផលិតកម្មបសុសត្វនាពេលបច្ចុប្បន្នរបស់ប្រទេសឡាវ។

**ធនធានជលផលផ្ទៃអាងស្តុកទឹក មិនអាចទូទាត់សងការបាត់បង់ផលនេសាទនៃធនធានជលផលបានឡើយ** ហើយយ៉ាងច្រើនបំផុត នោះគឺអាចផលិតបាន ១ភាគ ១០ នៃផលិតកម្មផលនេសាទនៃធនធានជលផលដែលបានបាត់បង់។ ក្នុងរយៈពេលវែង តាមការព្យាករសម្រាប់ឆ្នាំ២០៣០ ការធ្លាក់ចុះនៃកម្រិតកំទេចកំណរ

និងសារធាតុចិញ្ចឹម មានពី ៥០ ទៅ ៧៥ ភាគរយនៃបរិមាណប្រចាំឆ្នាំជាមធ្យមនាពេលបច្ចុប្បន្ន ដែលអាចមានផលប៉ះពាល់ដល់វិស័យជលផលតំបន់ឆ្នេរ និងបន្ទាប់មកទៀត មានឥទ្ធិពលដល់វិស័យជលផល និងពាណិជ្ជកម្មត្រីរបស់ប្រទេសវៀតណាមដែលជាវិស័យមួយចូលរួមចំណែកយ៉ាងខ្លាំងដល់កំណើនសេដ្ឋកិច្ចក្នុងរយៈពេល១០ឆ្នាំចុងក្រោយ ហើយផ្តល់ទិន្នផលត្រីប្រចាំឆ្នាំប្រមាណ៥០០.០០០ តោន។

**វារីវប្បកម្មអាចចូលរួមចំណែកដល់ផលនេសាទនៃធនធានជលផលរបស់ទន្លេមេគង្គ ប៉ុន្តែមិនអាចជំនួសឱ្យផលនេសាទបានឡើយ បើគិតក្នុងន័យសន្តិសុខស្បៀង។** វារីវប្បកម្មបង្ហាញពីការរីកចំរើនយ៉ាងឆាប់រហ័សនៅតាមបណ្តាប្រទេសនៅអាងទន្លេមេគង្គក្រោម (រីកចម្រើនបំផុតក្នុងប្រទេសវៀតណាម)។ វារីវប្បកម្មបែបប្រពលវប្បកម្ម (ឧទាហរណ៍ ប្រទេសវៀតណាម) បានផលិតត្រីសម្រាប់នាំចេញ និងរកប្រាក់ចំណូល ប៉ុន្តែប្រជាជនក្រីក្រ មិនបានទទួលផលឡើយ។ វារីវប្បកម្មបែបវិបុលវប្បកម្ម (ឧទាហរណ៍ប្រទេសកម្ពុជា) ផ្គត់ផ្គង់ប្រជាជនក្នុងស្រុក ប៉ុន្តែមិនសូវមានផលិតភាព។ វិស័យនេះ គឺពឹងផ្អែកលើ (១) ការវិនិយោគ (២) ការគ្រប់គ្រងទឹក/ដី និង (៣) ផលនេសាទសម្រាប់បរិភោគ (គ្រប់ប្រទេស) និងសម្រាប់ភ្ញាស់កូន (ជាពិសេសប្រទេសកម្ពុជា)។ បើមានការគ្រប់គ្រងសម្រាប់ការប្រើប្រាស់ចម្រុះ នោះគម្រោងតាមដងទន្លេមេនៃអាងទន្លេមេគង្គក្រោមអាចផ្តល់នូវការវិនិយោគ និងធនធានទឹកដែលត្រូវការសម្រាប់វិស័យវារីវប្បកម្ម។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គម្រោងតាមទន្លេមេនៃទន្លេមេគង្គ នឹងកាត់បន្ថយផលិតភាពនៃការចាប់ទិន្នផលត្រី និងកាត់បន្ថយការផ្គត់ផ្គង់ផលស្តុកចំណីក្នុងវិស័យវារីវប្បកម្ម ដោយសារសមត្ថភាពរបស់វិស័យជលផលក្នុងការស្តារការបាត់បង់ត្រីក្នុងផ្ទៃអាងនៅមានកម្រិត។

**ការធ្លាក់ចុះយ៉ាងខ្លាំងនៃផលនេសាទទឹកសាប និងសមុទ្រ និងវារីវប្បកម្មតាមដែនដីសណ្តអាចមានផលប៉ះពាល់នៅទូទាំងផ្ទៃអាងទន្លេមេគង្គទៅលើវិស័យជលផល** ដោយជាប់ពាក់ព័ន្ធជាចម្បងដល់ឧស្សាហកម្មកែច្នៃ និងដំណើរការផលិតកម្ម និងធនធានជលផលសម្រាប់ជីវភាពរស់នៅ សុខភាព និងម្ហូបអាហារ។

**គំនូសតាងទី៤: ផលប៉ះពាល់ជាសក្តានុពលនៃទំនប់តាមទន្លេមេនៃអាងទន្លេមេគង្គក្រោម ទៅលើផលិតកម្មត្រីនៅទូទាំងអាងទន្លេមេគង្គ**




**ការសាងសង់ច្រកឆ្លងកាត់របស់ត្រី គឺមិនមែនជាជម្រើសនៃកាត់បន្ថយផលប៉ះពាល់ជាក់ស្តែងសម្រាប់អាងទន្លេមេគង្គក្រោម។** ការសាងសង់ផ្លូវសម្រាប់ត្រីបំលាស់ទី អាចជាជម្រើសកាត់បន្ថយផលប៉ះពាល់សម្រាប់ទំនប់ទាបៗនៅតាមដៃទន្លេ ប៉ុន្តែប្រភេទ និងទំហំផ្លូវសម្រាប់ត្រីបំលាស់ទីដែលមានស្រាប់នាពេលនេះ មិនអាចដោះស្រាយ បរិមាណ និងភាពចម្រុះនៃការបំលាស់ទីរបស់ត្រីនៅតាមទន្លេមេបានឡើយ។ ផ្លូវសម្រាប់ត្រីបំលាស់ទីនៅតាមទំនប់វារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គចំនួន ៨ ដែលបានស្នើឡើង គឺខ្ពស់ជាងកម្ពស់អតិបរមារបស់ផ្លូវសម្រាប់ត្រីបំលាស់ទី ដែលអាចដំណើរការបាន។ ផ្លូវសម្រាប់ត្រីបំលាស់ទីនៅទូទាំងពិភពលោក មានប្រសិទ្ធភាព នៅពេលមានការរចនាជាក់លាក់សម្រាប់ប្រភេទត្រីពិសេសមួយចំនួនដែលបំលាស់ទីម្តងក្នុងមួយឆ្នាំ ហើយចំនួនមានកំណត់។ ទន្លេមេគង្គ មានប្រភេទត្រីបំលាស់ទីជាង ៥០ប្រភេទផ្សេងគ្នា ដោយមានចំនួនយ៉ាងច្រើន ក្នុងអំឡុងពេលបំលាស់ទីអតិបរមា និងមានការបំលាស់ទីពី៤ ទៅ ៥ ដងក្នុងមួយឆ្នាំ។ លើសពីនេះ ល្បាក់ទឹករបស់ទំនប់នឹងកាត់បន្ថយយ៉ាងខ្លាំង នូវអត្រាការឆ្លងកាត់ជាទូទៅរបស់ត្រីនៅប៉ែកខាងលើ។

ប្រសិនបើចង់ឱ្យការឆ្លងកាត់របស់ត្រីប្រព្រឹត្តទៅដោយជោគជ័យ នោះអ្នកអនុវត្តគម្រោងត្រូវធ្វើការពិចារណា និងបញ្ចូលចំណុចទាំងនេះនៅដំណាក់កាលដំបូង នៅពេលធ្វើការកំណត់ទីតាំង និងការរៀបចំទំនប់ ហើយការរចនាសម្រាប់ត្រីឆ្លងកាត់ ត្រូវធ្វើឡើងចំពោះប្រភេទត្រីតាមគោលដៅដែលបានកំណត់។ មកដល់ពេលបច្ចុប្បន្ន មានតែទំនប់វារីអគ្គិសនី ៣ ក្នុងចំណោមទំនប់វារីអគ្គិសនីទាំង ១១ នៅតាមទន្លេមេនៃអាង

ទន្លេមេគង្គក្រោម បានបញ្ជាក់ច្បាស់លាស់ពីការបញ្ចូលការឆ្លងកាត់របស់ត្រី ហើយមិនមានគម្រោងណាមួយបានធ្វើការការពិចារណាអំពីការឆ្លងកាត់របស់ត្រីមុនពេលការជ្រើសរើសទីតាំង ហើយក៏មិនមានគម្រោងណាមួយបានធ្វើការរចនាដោយផ្អែកលើការសិក្សាតាមប្រភេទត្រីគោលដៅឡើយ។

**វិស័យកសិកម្មនឹងទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយការសាងសង់ទំនប់វារីអគ្គិសនីតាមទន្លេមេ តាមរយៈទឹកជំនន់លើដីកសិកម្ម និងការបាត់បង់ដំណាំតាមច្រាំងទន្លេ និងដោយសារការពង្រីកបន្ថែមនៃប្រព័ន្ធធារាសាស្ត្រពាក់ព័ន្ធនឹងគម្រោង។** ផលប៉ះពាល់ដល់វិស័យកសិកម្មនៅតាមតំបន់ដីសណ្តហាក់ដូចជាមានភាពធ្ងន់ធ្ងរ ប៉ុន្តែ នៅពេលនេះមិនទាន់មានការសិក្សា និងប៉ាន់ស្មានឱ្យបានស៊ីជម្រៅឡើយ។

**គម្រោងតាមទន្លេមេ អាចកាត់បន្ថយសន្តិសុខស្បៀងរបស់ខេត្តតាមដងទន្លេ ជាពិសេសនៅពេលរួមផ្សំជាមួយនឹងផលប៉ះពាល់ដែលអាចកើតមានដោយសារការប្រែប្រួលអាកាសធាតុ។** ការប្រែប្រួលអាកាសធាតុអាចនាំមកនូវ (១)កំណើនផលិតភាពកសិកម្មនៅក្នុងអាង (ប្រហែលជា ៣,៦ភាគរយ នៅឆ្នាំ២០៣០) ប៉ុន្តែសន្តិសុខស្បៀង មានការធ្លាក់ចុះដោយសារតំបន់លិចទឹកមានការកើនឡើង (២) ការធ្លាក់ចុះនូវភាពចម្រុះរបស់ត្រី និងស្ថិរភាព ផលិតកម្មវិស័យជលផលដោយសារអត្ថប្រយោជន៍នៃ ការប្រែប្រួលអាកាសធាតុដែលបង្កើតឱ្យមានតំបន់លិចទឹក និងបរិមាណសារធាតុចិញ្ចឹមច្រើនជាងមុន។

ការខាតបង់ក្នុងវិស័យកសិកម្ម អាចមានការទូទាត់សងក្នុងចំណែកណាមួយតាមរយៈការបង្កើតដីកសិកម្មថ្មីដែលជាប់នឹងអាងទឹក និងការផ្តល់នូវសម្ភារៈធារាសាស្ត្រ និងអគ្គិសនី។ ប្រហែលជាមានបញ្ហាមួយចំនួនទាក់ទងនឹងការទទួលបានដោយសមធម៌ ចំពោះការអភិវឌ្ឍនេះ ជាពិសេសចំពោះអ្នកក្រ ពីព្រោះគម្រោងធារាសាស្ត្រធំៗភាគច្រើនផ្តល់ប្រយោជន៍ដល់ថ្នាក់កណ្តាល។

## ប្រព័ន្ធសង្គម : ជីវភាពរស់នៅ និងវប្បធម៌ក្នុងការរស់នៅរបស់ប្រជាជនសហគមន៍ដែលទទួលរងផលប៉ះពាល់

អាងទន្លេមេគង្គក្រោម មានប្រជាជនប្រមាណ ២៩,៦ លាននាក់រស់នៅ និងធ្វើការក្នុងចម្ងាយ ២៥ គីឡូម៉ែត្រពីទន្លេមេគង្គ។ ក្នុងចំណោមប្រជាជនទាំងនេះ មានប្រជាជន ២,១ លាននាក់ គឺជាប្រជាជនសហគមន៍មូលដ្ឋានរស់នៅតាមបណ្តោយទន្លេក្នុងចម្ងាយ ៥គីឡូម៉ែត្រពីមាត់ទន្លេ ហើយប្រជាជនទាំងនេះ គឺជាអ្នកដែលគេរំពឹងថាទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលពីទំនប់វារីអគ្គិសនីតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម។ ក្នុងចំណោមប្រជាជនខាងលើ **ប្រជាជនប្រមាណ ១០៦.៩៤២ នាក់ នឹងទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីគម្រោងតាមទន្លេមេនៃអាងទន្លេមេគង្គក្រោមទាំង ១២ ដោយរួមមានការបាត់បង់ផ្ទះសម្បែង ដីធ្លី និងមានការរុះរើលំនៅដ្ឋាន។ លើសពីនេះ មានមនុស្សលើសពី ២ លាននាក់ក្នុងស្រុកចំនួន ៤៧ ដែលរស់នៅក្នុងបរិវេណអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនី កន្លែងទំនប់ទឹក និងផ្នែកខាងក្រោមជាប់នឹងគម្រោងតាមទន្លេមេ**

**ក្នុងអាងមេគង្គក្រោមចំនួន ១១ ដែលបានស្នើឡើង ប្រឈមនឹងហានិភ័យខ្ពស់នៃផលប៉ះពាល់ដោយប្រយោល ពីគម្រោងទាំងនេះ។**

គម្រោងវារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ ហាក់ដូចជាមានផលប៉ះពាល់យ៉ាងខ្លាំងដល់សហគមន៍នៅតាមដងទន្លេ ដោយមានការរំខានដល់របៀបរស់នៅ វប្បធម៌ និងស្មារតីសហគមន៍។ គម្រោងតាមទន្លេមេដែលបានស្នើឡើង នឹងរារាំងដល់សហគមន៍ក្នុងការទទួលបានអាហារគ្រប់គ្រាន់ប្រកបដោយគុណភាព ក៏ដូចជាបង្កើននូវកម្រិតនៃគ្រោះថ្នាក់ ឬហានិភ័យ ដែលអ្នកទាំងនោះត្រូវប្រឈម។

គម្រោងតាមទន្លេមេខ្លះ បានបង្កឱ្យភូមិមួយចំនួនធ្វើការផ្លាស់ទីលំនៅ ពី២ដង ៣ដង ឬ៤ដងក្នុងរយៈពេល ១៥ឆ្នាំ។ ការផ្លាស់ទីជាចាំបាច់ម្តងហើយម្តងទៀតក្នុងរយៈពេលដ៏ខ្លី គឺជាកត្តាបង្កើតនូវភាពក្រីក្រ ហើយហេតុការណ៍នេះ នឹងកើតមានឡើងចំពោះប្រជាជនសហគមន៍ ដោយសារការរីកចំរើនយ៉ាងឆាប់រហ័សនៃការសាងសង់គម្រោងវារីអគ្គីសនី ហើយហានិភ័យនៃការផ្លាស់ទីលំនៅជាច្រើនលើកច្រើនសារអាចកើតមានយ៉ាងច្រើនចំពោះប្រជាជនសហគមន៍ទទួលរងផលប៉ះពាល់ក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។

បទពិសោធន៍ក្នុងការផ្តល់នូវការសម្របខ្លួន និងកម្មវិធីគាំទ្រឱ្យបានទាន់ពេល ស៊ីសង្វាក់គ្នា និងមានរយៈពេលយូរអង្វែង ដល់សហគមន៍ទទួលរងផលប៉ះពាល់ដោយវារីអគ្គិសនីនៅតាមតំបន់អាងទន្លេមេគង្គក្រោម មិនទាន់បានល្អនៅឡើយទេ។ ជាញឹកញាប់ ការងារទាំងនេះតម្រូវឱ្យមានសមត្ថភាព និងវិធីសាស្ត្រក្នុងការគ្រប់គ្រងថវិកា និងគម្រោង ហើយកត្តាទាំងនេះមិនទាន់មានឡើយ។

## សេចក្តីសង្ខេប នៃឱកាស និងហានិភ័យផ្នែកសេដ្ឋកិច្ចនៃគម្រោងវារីអគ្គិសនីតាមទន្លេមេទាំង ១២ ចំពោះបណ្តាប្រទេសនៅតាមអាងទន្លេមេគង្គក្រោម

**ប្រទេសកម្ពុជា**

- ផលវិបាកយ៉ាងធ្ងន់ធ្ងរដល់វិស័យជលផល និងអ្នកនេសាទ សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ
- អត្ថប្រយោជន៍យ៉ាងច្រើនពីសន្តិសុខនៃការអភិវឌ្ឍវិស័យថាមពល និងថាមពលដែលមានតម្លៃទាបជាងមុនសម្រាប់វិស័យឧស្សាហកម្ម និងការពង្រីកសេដ្ឋកិច្ចរយៈពេលវែង
- ការខាតបង់ក្នុងវិស័យជលផល អាចមានច្រើនជាងអត្ថប្រយោជន៍ទទួលបានពីការផលិតថាមពលយ៉ាងហោចណាស់ក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម

| ឱកាស | ហានិភ័យ |
|---|---|
| ▪ អត្ថប្រយោជន៍យ៉ាងច្រើនពីការផ្គត់ផ្គង់ថាមពលថ្នាក់ជាតិ ដែលមានស្ថេរភាព និងមានតម្លៃទាបជាងមុន (ជំនួសការនាំចូលប្រេងឥន្ធនៈ ដែលមានតម្លៃថ្លៃ)<br>▪ បង្កើនការប្រកួតប្រជែងក្នុងវិស័យផលិតកម្ម<br>▪ បង្កើនប្រាក់ចំណូលពីការនាំចេញថាមពល និងការបង់ពន្ធ<br>▪ បង្កើននូវតំបន់លិចទឹក និងផលិតភាពកសិកម្ម នៅតាមទីតាំងមួយចំនួន<br>▪ មានភាពបត់បែនជាយុទ្ធសាស្ត្ររយៈពេលវែង ក្នុងការផ្គត់ផ្គង់ថាមពលនៅពេលរយៈពេលសម្បទានត្រូវបញ្ចប់ | ▪ បាត់បង់ធនធានជលផល និងមានផលប៉ះពាល់យ៉ាងខ្លាំងដល់សន្តិសុខស្បៀង<br>▪ ការរំខានដល់ជីវភាពរស់នៅរបស់អ្នកនេសាទជាង ១,៦ លាននាក់<br>▪ មានការធ្លាក់ចុះនៃផលិតផលក្នុងស្រុកសរុបតាមរយៈការខាតបង់ផ្នែកសេដ្ឋកិច្ច ក្នុងវិស័យជលផល និងកសិកម្ម<br>▪ សេវាបន្ទាប់បន្សំ និងដំណើរការផលិតត្រូវទទួលរងផលប៉ះពាល់<br>▪ ការបាត់បង់កំទេចកំណរ និងសារធាតុចិញ្ចឹមចាំបាច់សម្រាប់ប្រព័ន្ធទន្លេសាប និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរផ្សេងៗ លើផលិតកម្មសំខាន់ ព្រៃលិចទឹក និងត្រីនៅក្នុងតំបន់ ឬត្រីធ្វើបំលាស់ទី<br>▪ ការបាត់បង់ដំណាំតាមច្រាំងទន្លេ ដែលអាចមានសារៈសំខាន់យ៉ាងខ្លាំងដល់សហគមន៍មូលដ្ឋាន<br>▪ ការបាត់បង់ដីមានជីជាតិ និងផលិតភាពកសិកម្មក្នុងវាលទំនាបលិចទឹក<br>▪ ការបាត់បង់ធនធានសម្រាប់វិស័យទេសចរណ៍ និងប្រាក់ |

<table>
<tr><td></td><td>ចំណូលពីវិស័យទេសចរណ៍<br>▪ កង្វះខាតបង្គោលភ្លើងថ្នាក់ជាតិ អាចរារាំងដល់ការចែកចាយថាមពល<br>▪ ការបាត់បង់ជីវៈចម្រុះ</td></tr>
<tr><td colspan="2">ប្រទេសឡាវ<br>▪ អាចនឹងផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចជាច្រើន ប៉ុន្តែអត្ថប្រយោជន៍ អាចនឹងមិនបានបែងចែកឱ្យបានស្មើគ្នា<br>▪ ផលប៉ះពាល់ជាអវិជ្ជមានដល់សហគមន៍ងាយរងគ្រោះអាចនឹងមានច្រើន<br>▪ ការចំណាយរបស់រដ្ឋាភិបាលឡាវដែលបានមកពីប្រាក់ចំណូលដែលបានកើនឡើង អាចកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន</td></tr>
<tr><td>ឱកាស</td><td>ហានិភ័យ</td></tr>
<tr><td>▪ អត្ថប្រយោជន៍យ៉ាងច្រើនពីថវិកាបន្ថែមក្នុងសេដ្ឋកិច្ចតាមរយៈការវិនិយោគដោយផ្ទាល់ពីបរទេសក្នុងគម្រោងវារីអគ្គិសនីតាមទន្លេមេនៃអាងទន្លេមេគង្គក្រោម<br>▪ អាចទទួលបានប្រាក់ចំណេញពីប្រាក់ចំណូលក្នុងដំណាក់កាលសម្បទាន អាស្រ័យលើការរៀបចំកិច្ចព្រមព្រៀងហិរញ្ញវត្ថុ និងសមត្ថភាពការត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់<br>▪ អាចទទួលបានផលប្រយោជន៍យ៉ាងច្រើនបន្ទាប់ពីបញ្ចប់ដំណាក់កាលសម្បទានរយៈពេល២៥ឆ្នាំ ហើយគម្រោងត្រូវបានផ្ទេរទៅឱ្យរដ្ឋាភិបាលឡាវ<br>▪ អត្ថប្រយោជន៍នៃការកើនឡើងនូវដីលិចទឹក និងផលិតភាពកសិកម្មនៅតំបន់មួយចំនួន<br>▪ ការលើកកម្ពស់ការធ្វើចរាចរផ្លូវទឹកសម្រាប់នាវាធុនមធ្យម និងធុនធំនៅភាគខាងលើនៃទីក្រុងវៀងច័ន្ទ</td><td>▪ អាចកើតមាននូវអតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ដោយសារការកើនឡើងនូវវិស័យវារីអគ្គិសនី<br>▪ ការបាត់បង់ធនធានជលផល អាចជះឥទ្ធិពលដល់សន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាជនងាយរងគ្រោះ<br>▪ ការបាត់បង់ដំណាំតាមច្រាំងទន្លេ ដែលមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ប្រទេសឡាវ<br>▪ ការបាត់បង់ធនធានទេសចរណ៍ដែលមានតម្លៃជាច្រើន<br>▪ ការបាត់បង់ជីវៈចម្រុះ</td></tr>
</table>

| | |
|---|---|
| ▪ ភាពបត់បែនជាយុទ្ធសាស្ត្ររយៈពេលវែង នៅពេលសម្បទានត្រូវបញ្ចប់ | |
| **ប្រទេសថៃ**<br>▪ ផលប្រយោជន៍ទូទៅដល់សេដ្ឋកិច្ច បើទោះបីជាមិនមានផលប្រយោជន៍អ្វីសំខាន់ដល់សេដ្ឋកិច្ចក៏ដោយ<br>▪ ហានិភ័យផ្នែកសេដ្ឋកិច្ចដល់ជីវភាពរបស់ប្រជាសហគមន៍រស់នៅតាមដងទន្លេក្នុងផ្ទៃអាងទន្លេមេគង្គ | |
| **ឱកាស** | **ហានិភ័យ** |
| ▪ នឹងទទួលបានអត្ថប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ចពីថាមពលនាំចូល<br>▪ ការលើកកម្ពស់ការធ្វើចរាចរផ្លូវទឹកសម្រាប់នាវាធុនមធ្យម និងធុនធំនៅភាគខាងលើនៃអាងទន្លេមេគង្គក្រោម | ▪ ការបាត់បង់ក្នុងវិស័យជលផល<br>▪ ការបាត់បង់ដីកសិកម្ម<br>▪ ការបាត់បង់ដែលអាចកើតមានឡើងចំពោះធនធានសម្រាប់វិស័យទេសចរណ៍ធម្មជាតិ |
| **ប្រទេសវៀតណាម**<br>▪ ហាក់ដូចជាខាតបង់ជារួមដល់សេដ្ឋកិច្ច<br>▪ ការបាត់បង់កើតមានឡើងច្រើនចំពោះសហគមន៍ក្រីក្រក្នុងតំបន់ដីសណ្តទន្លេមេគង្គ | |
| **ឱកាស** | **ហានិភ័យ** |
| នឹងទទួលបានអត្ថប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ចពីថាមពលនាំចូល | ▪ មានការធ្លាក់ចុះយ៉ាងខ្លាំងនូវផលនេសាទទឹកសាប និងផលនេសាទ និងទិន្នផលពីវារីវប្បកម្ម ដូចជាមានផលប៉ះពាល់ដល់ប្រជាជនរស់នៅតាមដែនដីសណ្តទន្លេមេគង្គ ជាពិសេសអ្នកក្រីក្រ<br>▪ ការបាត់បង់កំទេចកំណរ និងសារធាតុចិញ្ចឹមសំខាន់ៗ មានផល ប៉ះពាល់ដល់កំទេចកំណរតំបន់ដែនដីសណ្ត វិស័យជលផល (ទន្លេមេគង្គ និងសមុទ្រ) និងកសិកម្មមានផលប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ច |

## សេចក្ដីសន្និដ្ឋានសង្ខេប

គម្រោងវារីអគ្គិសនីតាមដងទន្លេមេនឹងនាំមកនូវថាមពល និងអត្ថប្រយោជន៍ពីប្រាក់ចំណូល ឬការវិនិយោគបន្ថែមដល់តំបន់។ យ៉ាងណាមិញ គម្រោងទាំងនេះក៏នាំមកនូវហានិភ័យ និងភាពមិនប្រាកដប្រជានៃបញ្ហាមួយចំនួនទាក់ទងនឹងបញ្ហាកង្វល់ផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ចរបស់សហគមន៍ និងបណ្ដាប្រទេសនៅតាមទន្លេមេគង្គ ក៏ដូចជាការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់អាងទន្លេមេគង្គ។ ជាសរុប ក្រុមការងារធ្វើការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ទាញសេចក្ដីសន្និដ្ឋានចំពោះបញ្ហាកង្វល់ជាយុទ្ធសាស្ត្រចំបងៗ ដូចខាងក្រោម:

### *ការផលិតថាមពល និងសន្តិសុខ*

**ទំនប់វារីអគ្គិសនីតាមទន្លេមេ នាំមកនូវការចូលរួមចំណែកជាសក្ដានុពលជាច្រើនដល់ការផលិតថាមពលសម្រាប់តំបន់អាងទន្លេមេគង្គក្រោម ដោយមាន ២៣ ភាគរយនៃសក្ដានុពលវារីអគ្គិសនីតាមលក្ខណៈបច្ចេកទេសក្នុងបណ្ដាប្រទេសនៅអាងទន្លេមេគង្គក្រោមទាំង ៤ ហើយមានសមត្ថភាពតម្លើងចំនួន ១១ ភាគរយនៅត្រឹមឆ្នាំ ២០២៥។** វារីអគ្គិសនីក្នុងអាងទន្លេមេគង្គមានទ្រង់ទ្រាយតូច ប៉ុន្តែជាផ្នែកមួយដ៏សំខាន់នៃវិស័យថាមពលនៅអាងទន្លេមេគង្គក្រោម ដែលមានការពឹងផ្អែកលើថាមពលផូស៊ីល។ ការកើនឡើងនូវតម្រូវការអគ្គិសនីរហូតដល់ឆ្នាំ ២០២៥ នឹងធ្វើឱ្យវារីអគ្គិសនីនៅតែដើរតួនាទីសំខាន់ នៅពេលប្រទេសទាំងនេះធ្វើការពង្រីកប្រភពឥន្ធនៈ កាត់បន្ថយការបញ្ចេញឧស្ម័នកាបូន និងបង្កើតពាណិជ្ជកម្មថ្នាក់តំបន់។ គម្រោងវារីអគ្គិសនីតាមដងទន្លេមេនៃអាងមេគង្គក្រោមទាំងនេះ បង្កើនថាមពល ៨ ភាគរយ ដល់តម្រូវការថ្នាក់តំបន់នៅឆ្នាំ ២០២៥ ប្រសិនបើគម្រោងទាំងនេះត្រូវបានធ្វើឡើង។

**វារីអគ្គិសនីតាមទន្លេមេនៃអាងមេគង្គក្រោម មិនដើរតួនាទីអ្វីសំខាន់ក្នុងការធានាឱ្យមានការលូតលាស់ល្អប្រសើរ ក្នុងវិស័យថាមពលថ្នាក់តំបន់នៃអាងទន្លេមេគង្គក្រោម ប៉ុន្តែអវត្តមាននៃគម្រោងទាំងនេះ នឹងដាក់កម្រិតសមត្ថភាពរបស់ប្រទេសកម្ពុជា ក្នុងការបង្កើតជម្រើសការផ្គត់ផ្គង់នៅក្នុងមូលដ្ឋាន និងការរកប្រាក់ចំណូលតាមរយៈការនាំចេញ។** លើសពីនេះ ទោះបីជាអត្ថប្រយោជន៍បានមកពីវិស័យថាមពលភាគច្រើន បានទៅប្រទេសឡាវក៏ដោយ ក៏គម្រោងទាំងនេះមានសារៈសំខាន់យ៉ាងខ្លាំងចំពោះប្រទេសកម្ពុជា ដែលជាប្រទេសមួយមានជម្រើសតិចតួចក្រៅពីការនាំចូលឥន្ធនៈផូស៊ីលដែលមានតម្លៃថ្លៃ។ ចំណែកឯប្រទេសឡាវជាប្រទេសមានបទពិសោធន៍ក្នុងការផលិតវារីអគ្គិសនី មានសក្ដានុពលវារីអគ្គិសនីតាមដៃទន្លេគ្រប់គ្រាន់ ដើម្បីធានាបាននូវការលូតលាស់ល្អក្នុងរយៈពេលមធ្យម និងផលិតថាមពលអគ្គិសនីសម្រាប់ការផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញដោយមិនចាំបាច់មានគម្រោងតាមដងទន្លេមេនៃអាងទន្លេមេគង្គ។

**ការត្រៀមសម្រាប់ការប្រែប្រួលអាកាសធាតុនៅពេលបច្ចុប្បន្ន អាចជួយពង្រឹងសក្តានុពលរបស់ដៃទន្លេនៃអាងទន្លេមេគង្គក្រោម សម្រាប់វិស័យថាមពល និងវារីអគ្គិសនីតាមដងទន្លេមេនៃអាងទន្លេមេគង្គក្រោម។** ដៃទន្លេមេគង្គភាគច្រើន ដែលមានសក្តានុពលសម្រាប់វារីអគ្គិសនីខ្លាំង ត្រូវបានព្យាករទុកថានឹងមានកំណើនសរុបក្នុងការបញ្ចេញទឹកប្រចាំឆ្នាំ តាមរយៈកំណើនលំហូរទឹកនៅក្នុងរដូវវស្សាដោយសារការប្រែប្រួលអាកាសធាតុ។

**ជម្រើសផ្សេងៗដើម្បីទប់ផ្លូវទឹកទាំងស្រុង ដើម្បីផលិតអគ្គិសនី នៅមិនទាន់បានសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ។** ជាទូទៅ គំនិតច្នៃប្រឌិតថ្មីៗលើផ្នែកបច្ចេកទេស និងគ្រប់គ្រងមួយចំនួនសម្រាប់ វារីអគ្គិសនីនៅតាមទន្លេធំៗនៅតាមដងទន្លេមេគង្គមិនទាន់បានសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ។ ថ្វីត្បិតតែទិន្នផលថាមពល ដែលទទួលបានពីគម្រោងនីមួយៗ អាចធ្វើឱ្យមានឧបសគ្គតិចតួចក្នុងផ្នែកខ្លះនៃប្រព័ន្ធខ្សែទឹកក៏ដោយ ក៏ឧបករណ៍ផលិតអគ្គិសនីដាក់តាមខ្សែទឹក និងការធ្វើឱ្យប្រែប្រួលចរន្តទឹក តម្រូវឱ្យមានការសិក្សាពីសមិទ្ធិផលលម្អិត ដោយពិចារណាលើសក្តានុពលដែលអាចកើតមានបណ្តាលមកពីការថយចុះយ៉ាងច្រើននៃប្រព័ន្ធធម្មជាតិ ការប៉ះពាល់ដល់ជីវភាពរស់នៅ និងនិរន្តភាពនៃថាមពលវារីអគ្គិសនី និងគោលបំណងនៃការគ្រប់គ្រងធនធានទឹកនៅទូទាំងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព។

### ***ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ***

**ថាមពលវារីអគ្គិសនីរបស់អាងទន្លេមេគង្គក្រោម ផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចយ៉ាងច្រើនដល់វិស័យថាមពលក្នុងតំបន់ ហើយផលប្រយោជន៍ភាគច្រើន (ប្រមណជា ៧០%) ផ្តល់ឱ្យប្រទេសឡាវ។** សំណើគម្រោងទំនប់វារីអគ្គិសនីទាំង ១២ របស់អាងទន្លេមេគង្គក្រោម មានរៀបរាប់ពីឱកាសពិសេសក្នុងការបង្កើតប្រាក់ចំណូលក្នុងប្រទេសដែលមានទំនប់វារីអគ្គិសនី ដោយមានចំណូលប្រចាំឆ្នាំចាប់ពី ៣ ទៅ ៤ ពាន់លានដុល្លាសម្រាប់ប្រទេសឡាវ និងកម្ពុជា។ រដ្ឋាភិបាលនៃប្រទេសម្ចាស់គម្រោងអាចទទួលបានចំណូល ២៥ ទៅ ៣១% ពីចំណូលក្នុងអំឡុងពេលសម្បទាន (ជាធម្មតាមានរយៈពេល ២៥ឆ្នាំ) ហើយនឹងកើនឡើងជិត ១០០% បន្ទាប់ពីរយៈពេលសម្បទាននេះ។

**ប្រសិនបើមានការគ្រប់គ្រងបានត្រឹមត្រូវ គម្រោងថាមពលវារីអគ្គិសនីនៅអាងទន្លេមេគង្គក្រោម អាចនឹងផ្តល់ផលចំណេញ ច្រើនដល់ចំណូលជាតិ ព្រមទាំងអាចចូលរួមយ៉ាងច្រើនដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសម្ចាស់គម្រោង។** គម្រោងទំនប់វារីអគ្គិសនីថាមពលវារីអគ្គីសនីទាំង១២របស់អាងទន្លេមេគង្គក្រោម គឺជាការវិនិយោគដែលត្រូវចំណាយទឹកប្រាក់ ២៥ ពាន់លានដុល្លានៅក្នុងសេដ្ឋកិច្ចតំបន់។ ៥០% នៃលំហូរការវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលមានទំនាក់ទំនងជាមួយនឹងថាមពលវារីអគ្គិសនី ទំនងជាស្ថិតក្នុងបន្ទុកនៃប្រទេសម្ចាស់គម្រោង។

**សមត្ថភាពជាតិ និងសមត្ថភាពក្នុងតំបន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមត្ថភាពគម្រោង និងការអនុវត្តប្រកបដោយជោគជ័យនៃយន្តការបែងចែកផលប្រយោជន៍ នឹងអាចកើតមាន ប៉ុន្តែមិនទាន់គ្រប់គ្រាន់ក្នុងការធានាថា កំណើនផលប្រយោជន៍នៅថ្នាក់ជាតិត្រូវបញ្ជូនមកថ្នាក់មូលដ្ឋានទេ។** ក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម អង្គការហិរញ្ញវត្ថុអន្តរជាតិ មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនសមត្ថភាព ដែលចាំបាច់ដើម្បីបង្វែរកំណើនប្រាក់ចំណូលទៅជាការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងសមធម៌។

**ការបាត់បង់លើវិស័យជលផល និងកសិកម្ម ដោយសារតែទំនប់វារីអគ្គិសនី មានទំហំធំជាងផលប្រយោជន៍ជាក់ស្តែងរបស់វិស័យទាំងពីរនេះ។** ជលផល និងកសិកម្ម ដែលជាវិស័យពីរក្នុងចំណោមវិស័យដ៏សំខាន់សម្រាប់សេដ្ឋកិច្ចផ្អែកលើធនធានធម្មជាតិរបស់អាងទន្លេមេគង្គក្រោម នឹងរងការខាតបង់ ៥០០ លានដុល្លាក្នុង១ឆ្នាំ ដែលផលប្រយោជន៍ទទួលបានពីផលនេសាទបានពីអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនី និងធារាសាស្ត្រថ្មីដែលនឹងអាចមានត្រឹមតែ ៣០ លានដុល្លាប៉ុណ្ណោះ ក្នុង១ឆ្នាំ។ ប្រសិនបើគេយល់ដឹងយ៉ាងច្បាស់ពីផលប៉ះពាល់លើសេដ្ឋកិច្ច ការនេសាទតំបន់ឆ្នេរ និងតំបន់ដីសណ្តនោះ ពេលនោះការប៉ាន់ស្មានពីការបាត់បង់ទំនងជាមានការកើនលើងគួរជាទីបារម្ភ។ **សូម្បីមានវិធានការទប់ស្កាត់ភាពក្រីក្រ ដែលពាក់ព័ន្ធទៅនឹង គម្រោងវារីអគ្គិសនីតាមបែបទំនើបក្នុងតំបន់ក៏ដោយ ក៏គម្រោងទំនប់វារីអគ្គិសនីនៅអាងទន្លេមេគង្គក្រោម នឹងបង្កឱ្យមានវិសមភាពកាន់តែច្រើនឡើង ហើយក្នុងរយៈពេលខ្លី និងរយៈពេលមធ្យមធ្វើឱ្យភាពក្រីក្ររបស់ប្រជាជននៅតាមប្រទេសអាងទន្លេមេគង្គក្រោម កាន់តែមានសភាពធ្ងន់ធ្ងរថែមទៀត។**

### *ផលប៉ះពាលលើប្រព័ន្ធបរិស្ថាន និង នានាភាពនៃប្រព័ន្ធបរិស្ថាន*

**គម្រោងទំបន់វារីអគ្គិសនីនៅតាមអាងទន្លេមេគង្គក្រោម អាចបង្កឱ្យមានឥទ្ធិពលថែមទៀតក្នុងអាងស្តុកទឹកបន្ថែមទៀត នាំឱ្យប៉ះពាល់ដល់ប្រព័ន្ធបរិស្ថានដែលពឹងអាស្រ័យលើទន្លេមេគង្គ ហើយផលប៉ះពាល់ភាគច្រើនមិនអាចជៀសវៀងបាន ប្រសិនបើគម្រោងត្រូវតែអនុវត្តនោះ។** គម្រោងទំនប់វារីអគ្គិសនី អាងទន្លេមេគង្គក្រោម ស្ទើឡើងនៅពេលដែលរបបជលវិទ្យាទន្លេមេគង្គកំពុងតែមានដំណើរការក្នុងរយៈពេលនៃការផ្លាស់ប្តូរចម្រុះដឹកនាំ ដោយការអភិវឌ្ឍវារីអគ្គិសនីឆាប់រហ័ស នៅតាមដៃទន្លេនៃអាងទន្លេមេគង្គក្រោម និងនៅតាមទំនប់វារីអគ្គិសនីនៅទន្លេមេគង្គលើក្នុងប្រទេសចិន។ គម្រោងទំនប់វារីអគ្គិសនី អាងទន្លេមេគង្គក្រោម នឹងបង្កការគំរាមកំហែងជាច្រើនកាន់តែខ្លាំងឡើង និងប៉ះពាល់ដល់ទំនាក់ទំនងទៅវិញទៅមកនៃប្រព័ន្ធអេកូឡូស៊ីទន្លេមេគង្គ ដោយសារការបែងចែកប្រព័ន្ធនេះទៅជាផ្នែកតូច ហើយមិនសូវមានផលិតភាព។

**គម្រោងទំនប់វារីអគ្គិសនីតាមអាងទន្លេមេគង្គក្រោម នឹងប៉ះពាល់ទឹកជំនន់ដោយសារបណ្តាញនៃអាងស្តុកទឹករបស់គម្រោង ដោយការបង្វែរទឹកទន្លេមេគង្គ ៥៥% ចូលអាងស្តុកទឹក ដែលអាចបង្កឱ្យមានការប្រែប្រួលយ៉ាងឆាប់រហ័ស និងក្នុងបរិមាណច្រើនដល់កម្រិតទឹកផ្នែកខាងលើតាមការកំណត់ពេលវេលាប្រចាំថ្ងៃ និងប្រចាំម៉ោង។ ការអភិវឌ្ឍទូទៅនៃវារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គ និងដៃទន្លេ នឹងកាត់បន្ថយយ៉ាងច្រើននូវលំហូរកំទេចកំណល់ និងបង្កការរំខានដល់រដូវ របបទឹក** និង**អេកូឡូស៊ី។** គម្រោងវារីអគ្គិសនីនៅតាមដៃទន្លេ និងនៅទន្លេមេគង្គលើ នឹងប៉ះពាល់ដល់ជម្រៅទឹកជំនន់ និងទំនាបលិចទឹកដោយសារលំហូរយ៉ាងទៀងទាត់នៅគ្រប់រដូវ។

**គម្រោងទំនប់វារីអគ្គិសនី អាចបង្កឱ្យមានការបាត់បង់ជារៀងរហូតនូវវារីជាតិ និងជីវសាស្ត្រចម្រុះលើដីដែលមានសារៈសំខាន់ជាសកល** និងការបាត់បង់រហូតនៃអេកូឡូស៊ីទន្លេមេគង្គដែលមិនអាចជួសជុល ឬទូទាត់សងបាន។ តំបន់ដីសើមចំនួន ១៧% នៅតាមទន្លេមេគង្គនឹងត្រូវបាត់បង់ ហើយប្រភេទសត្វមួយចំនួន នៅតាមតំបន់ទន្លេមេគង្គនឹងត្រូវផុតពូជ។

### *ជលផល និងសន្តិសុខស្បៀង*

**គិតត្រឹមឆ្នាំ ២០៣០ ប្រសិនបើមានការសាងសង់ទំនប់វារីអគ្គិសនីទាំង ១១ ជាតិប្រូតេអ៊ីនដែលប្រឈមនឹងការបាត់បង់មានប្រហែលជា ១១០% នៃផលិតកម្មបសុសត្វប្រចាំឆ្នាំរបស់ ប្រទេសកម្ពុជា និងប្រទេសឡាវសព្វថ្ងៃ។** ការនេសាទពីទំនប់វារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ នឹងអាចទទួលបានយ៉ាងច្រើនចំនួន ១០% បើធៀបនឹងផលចាប់ដែលបានបាត់បង់។ ពេលសាងសង់ទំនប់រួច ទំនប់វារីអគ្គិសនីនោះមិនបានទុកចន្លោះ ប្រភេទណាមួយ ដើម្បីឱ្យត្រីគ្រប់ទំហំ និងក្នុងចំនួនច្រើនដើម្បីឆ្លងកាត់ឡើយ។

**ហានិភ័យ និងការខាតបង់ ដែលកើតមានបណ្តាលមកពីប្រព័ន្ធអេកូឡូស៊ីក្នុងទឹក និងដីសើមទន្លេមេគង្គនឹងបង្កឱ្យមានកំណើនអសន្តិសុខស្បៀងដល់ប្រជាជនរាប់លាននាក់។** សហគមន៍ជនបទ និងសហគមន៍ក្នុងទីប្រជុំជនដែលរស់នៅចំងាយ ១៥ គីឡូម៉ែត្រ ពីទន្លេមេគង្គ ពីទីតាំងសង់ទំនប់នឹងទទួលរងផលប៉ះពាល់ ជាពិសេសជួបប្រទះអសន្តិសុខស្បៀងខ្លាំង ដោយសារការធ្លាក់ចុះផលនេសាទ និងការបាត់បង់នៃសកម្មភាពកសិកម្ម និងចម្ការដំណាំនៅតាមដងទន្លេសម្រាប់ទ្រទ្រង់ជីវភាពរស់នៅ។

**ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលយ៉ាងច្រើនលើឥទ្ធិពលសន្តិសុខស្បៀង បណ្តាលមកពីទំនប់វារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ ដោយធ្វើឱ្យធ្លាក់ចុះផលិតភាពផ្នែកជលផល និងកសិកម្មក្នុងស្ថានភាពកំពុងមានកំណើននៃតម្រូវការស្បៀង។**

សេវា និងមូលដ្ឋានតាមស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់សង្គមស៊ីវិលដែលត្រូវការចាំបាច់ ដើម្បីដោះស្រាយបញ្ហាវិបត្តិស្បៀងដែលស្ថិតក្នុងចម្ងាយប្រមាណ ១.៥០០ គីឡូម៉ែត្រ នៅតាមមាត់ទន្លេគឺមានវិសាលភាពធំធេង និងហួសពីសមត្ថភាពបច្ចុប្បន្ននៃតំបន់អាងទន្លេមេគង្គក្រោម និងរដ្ឋាភិបាល។

ទំហំនៃហានិភ័យរបស់ប្រទេសកម្ពុជា ប្រទេសឡាវ និងសេដ្ឋកិច្ចតំបន់ដែនដីសណ្តប្រទេសវៀតណាម ចាំបាច់ត្រូវធ្វើការវាយតម្លៃឱ្យបានល្អិតល្អន់អំពីផលប៉ះពាល់បណ្តាលមកពីសន្តិសុខស្បៀង និងជីវភាពរស់នៅ ការរកដំណោះស្រាយជាក់ស្តែង និងការបង្កើតជម្រើសសម្រាប់ការផ្គត់ផ្គង់ស្បៀង មុនពេលធ្វើការសម្រេចលើគម្រោងទំនប់វារីអគ្គិសនីនានា។

## *ប្រព័ន្ធសង្គម : ការប្រកបរបរចិញ្ចឹមជីវិត និងវប្បធម៌នៃការរស់នៅ*

**ក្នុងរយៈពេលខ្លី និងមធ្យម គម្រោងទំនប់វារីអគ្គិសនីនៅតាមអាងទន្លេមេគង្គក្រោម នឹងកាត់បន្ថយការប្រកបរបរចិញ្ចឹមជីវិតរបស់សហគមន៍ក្រីក្រនៅក្នុងខេត្តដែលរស់នៅតាមមាត់ទន្លេមេគង្គ។** ទំនប់វារីអគ្គិសនីថាមពលវារីអគ្គិសនីនៅអាងទន្លេមេគង្គក្រោម នឹងប៉ះពាល់អវិជ្ជមានដល់ប្រជាជនក្នុងសហគមន៍រស់នៅតាមដងទន្លេមេគង្គរាប់លាននាក់ ដែលប្រកបរបរចិញ្ចឹមជីវិត ដោយពឹងផ្អែកលើទន្លេ និងធនធានធម្មជាតិរបស់ទន្លេ។ ប្រជាជនយ៉ាងតិច ២,១ លាននាក់ នឹងទទួលរងប៉ះពាល់ដោយផ្ទាល់ និងប្រយោល ប្រសិនបើគម្រោងទំនប់វារីអគ្គិសនីដាក់ឱ្យដំណើរការ។

ចំពោះសហគមន៍រស់នៅតាមតំបន់តាមទន្លេ ទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងប្រយោល គម្រោងទំនប់វារីអគ្គិសនី នឹងបង្កឱ្យមានការប្រែប្រួលដែលគួរឱ្យកត់សម្គាល់មួយក្នុងការទទួលបាន និងគ្រប់គ្រងធនធានសំខាន់សម្រាប់ចិញ្ចឹមជីវិត និងរបៀបរស់នៅ: ឧទាហរណ៍ របៀបដែលពួកគេរស់នៅ ធ្វើការ កំសាន្ត និងទំនាក់ទំនងគ្នាពីមួយថ្ងៃទៅមួយថ្ងៃ សន្តិសុខក្នុងសហគមន៍ និងកម្រិតហានិភ័យដែលពួកគេត្រូវប្រឈមមុខ និងវប្បធម៌របស់ពួកគេ ពោលគឺ កេរ្តិ៍មរតក ប្រពៃណី និងតម្លៃរួមរបស់គេ។

## *កិច្ចសហប្រតិបត្តិក្នុងតំបន់ និងជម្លោះក្នុងតំបន់*

ក្នុងខណៈពេលកំពុងសាងសង់ និងប្រតិបត្តិទំនប់ ការអភិវឌ្ឍដែលស្នើឡើង អាចធ្វើឱ្យ មានផលប៉ះពាល់តំបន់នៅតាមដងទន្លេ និងភាពតានតឹងជាអន្តរជាតិក្នុងប្រទេសតាមអាងទន្លេមេគង្គក្រោម ដោយសារតែ (១)ការធ្លាក់ចុះនៃភាពស្រស់បំព្រងនៃប្រព័ន្ធអេកូឡូស៊ី (២) កាត់បន្ថយកំទេចកំណរ និងសារធាតុចិញ្ចឹម (៣) ការរំខានដល់ការប្រើប្រាស់ទឹកទន្លេមេគង្គ និង (៤) កាត់បន្ថយផលិតភាពនៃការនេសាទ និងកសិកម្ម និងអសន្តិសុខស្បៀងទូទៅនៅតាមអាងទឹកតូច និងដែនដីសណ្តដែលរងការប៉ះពាល់។

ក្របខ័ណ្ឌនៃបទដ្ឋាន និងសន្តិសុខតំបន់ទាក់ទងនឹងឥទ្ធិពលផ្លូវទឹកខាងក្រោម និងតាមខ្សែទឹក និងការរៀបចំស្ថាប័នសម្រាប់អនុវត្តមិនទាន់មានការរីកចម្រើនឱ្យបានគ្រប់គ្រាន់ និងមិនទាន់គ្រប់លក្ខណៈក្នុងការគ្រប់គ្រងហានិភ័យ គម្រោងទំនប់វារីអគ្គិសនីនៅឡើយទេ។

គម្រោងទំនប់វារីអគ្គិសនីនៅអាងទន្លេមេគង្គក្រោម បង្កើតឱ្យមានឱកាសក្នុងការពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់លើផ្នែកថាមពលស្របតាមការរៀបចំផែនការជាតិ និងអនុតំបន់ទន្លេមេគង្គ។

***ភាពមិនប្រាកដប្រជា***

ហានិភ័យជាច្រើនដែលពាក់ព័ន្ធជាមួយនឹងដំណើរការអភិវឌ្ឍទំនប់វារីអគ្គិសនី មិនអាចកាត់បន្ថយបាននៅក្នុងពេលនេះទេ ដោយសារតែហានិភ័យទាំងនោះអាចជាការបាត់បង់រហូត និងមិនអាចកើតមានឡើងវិញនូវធនធាន បរិស្ថាន សង្គម និងសេដ្ឋកិច្ច។

មានកង្វះខាតជាច្រើន និងធ្ងន់ធ្ងរលើការរៀបចំនីតិវិធី និងស្ថាប័នដើម្បីធានាឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃការសាងសង់ និងការប្រតិបត្តិរបស់គម្រោង និងចន្លោះខ្វះខាតនៅក្នុងសមត្ថភាពជាតិក្នុងការចែករំលែកផលប្រយោជន៍ប្រកបទៅដោយសមធម៌។

សមត្ថភាពចាំបាច់នៅជាតិ ទាំងផ្នែកធនធានមនុស្ស ទាំងជំនាញ តម្រូវការច្រើន ប៉ុន្តែនៅពេលនេះពុំទាន់មានសមត្ថភាពនេះពេញលេញ ដើម្បីមើល ត្រួតពិនិត្យ តាមដាន និងពង្រឹងការការពារ និងបទដ្ឋាននៃការប្រតិបត្តិនៅឡើយ។

ប្រទេសម្ចាស់គម្រោងប្រឈមនឹងភាពមិនប្រាកដប្រជា និងកង្វះខាតចំណេះដឹងស្តីពីការអភិវឌ្ឍ។ សមត្ថភាពចំណេះដឹងស្តីពីទន្លេមេគង្គ គឺមិនគ្រប់គ្រាន់សម្រាប់ការផ្តល់ព័ត៌មានជាមុន និងការសម្រេចចិត្តប្រកបដោយការទទួលខុសត្រូវលើការសាងសង់ទំនប់វារីអគ្គិសនីនៅពេលនេះទេ។

## ជម្រើសយុទ្ធសាស្ត្រ និងអនុសាសន៍

ការអភិវឌ្ឍទន្លេមេនៃទន្លេមេគង្គដែលបានស្នើសុំឡើង គឺជាការសម្រេចជាយុទ្ធសាស្ត្រដ៏សំខាន់បំផុតដែលប្រទេសទន្លេមេគង្គក្រោម មិនធ្លាប់បានធ្វើកន្លងមកទាក់ទងនឹងការប្រើប្រាស់រួមនៃធនធាន។ គោលដៅរបស់ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន គឺដើម្បីផ្លាស់ប្តូរការសម្រេចចិត្តជាយុទ្ធសាស្ត្រទាក់ទងនឹងគម្រោងដែលបានស្នើសុំ ពោលគឺដើម្បីជួយសម្រួលដល់ការសម្រេចចិត្ត និងផែនការនានា ដើម្បីឱ្យការអភិវឌ្ឍមាន សមធម៌ និងមាននិរន្តរភាពផ្នែកបរិស្ថាន។ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាននេះត្រូវបានរៀបចំឡើង ដើម្បីជួយវិភាគពីលក្ខខណ្ឌច្បាស់លាស់នៃការវិនិយោគពាក់ព័ន្ធនឹងជម្រើសយុទ្ធសាស្ត្រនានា ដូចជាថាតើមានការបាត់បង់អ្វីខ្លះ ទទួលប្រយោជន៍អ្វីខ្លះ និងតើនរណាជាអ្នកខាតបង់ និងនរណាជាអ្នកទទួលផលពីការអភិវឌ្ឍនេះ?

ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន នឹងលើកឡើងនូវសំណួរមូលដ្ឋានមួយថាតើ *"ធ្វើទំនប់ ឬមិនធ្វើទំនប់វារីអគ្គិសនីតាមផ្លូវទឹកទន្លេ មេគង្គឬទេ?"* ដើម្បីឆ្លើយតបនឹងសំណួរនេះ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានធ្វើការរៀបរាប់ និងប្រឹក្សាយោបល់ ដោយដាក់ចេញនូវជម្រើសយុទ្ធសាស្ត្របួនសម្រាប់ប្រទេសទន្លេមេគង្គក្រោម:

១. ពុំមានការសាងសង់ទំនប់វារីអគ្គិសនី។

២. ពន្យារការសម្រេចចិត្តសម្រាប់ការសាងសង់ទំនប់ ក្នុងរយៈពេលកំណត់មួយ។

៣. ការអភិវឌ្ឍថាមពលវារីអគ្គិសនីជាបណ្ដើរៗ។

៤. ការអភិវឌ្ឍគម្រោងវារីអគ្គិសនីដែលបានស្នើសុំ ដោយផ្អែកលើតម្រូវការទីផ្សារ។

ផ្អែកលើដំណាក់កាលវាយតម្លៃទាំងបួន និងលទ្ធផលរកឃើញរបស់ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាននេះ ក្រុមជំនាញការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានវាយតម្លៃលម្អិតពីជម្រើសនីមួយៗនៃជម្រើសទាំងបួននេះ។ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានផ្ដល់អនុសាសន៍លម្អិតមួយចំនួនសម្រាប់ជម្រើសយុទ្ធសាស្ត្រនីមួយៗ ដូច្នេះរដ្ឋាភិបាលនៃប្រទេសទន្លេមេគង្គក្រោម មានគោលការណ៍ណែនាំសម្រាប់បញ្ហាសំខាន់ៗ នៅពេលខ្លួនធ្វើការអនុម័តយកយុទ្ធសាស្ត្រ។ គំនូសតាងលំហូរខាងក្រោមពីការសម្រេចចិត្តលើកឡើងយ៉ាងសង្ខេបពីអនុសាសន៍របស់ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ទាក់ទងនឹងជម្រើសយុទ្ធសាស្ត្រនីមួយៗនៃជម្រើសយុទ្ធសាស្ត្រទាំងបួននេះ។

| ជម្រើសយុទ្ធសាស្ត្រ | មធ្យោបាយអនុវត្តសកម្មភាពសម្រាប់ជម្រើសយុទ្ធសាស្ត្រនីមួយៗ |
|---|---|
| **១ ពុំមានទំនប់**<br>ពុំមានការអភិវឌ្ឍទំនប់វារីអគ្គិសនីតាមទន្លេមេ<br><br>**២** ពន្យារការសម្រេចចិត្តសម្រាប់ការសាងសង់ទំនប់វារីអគ្គិសនីក្នុងរយៈពេលកំណត់មួយ | ១.១. គ្រប់គ្រងការផ្លាស់ប្តូរលំហូរ និងសំណល់ ពីទំនប់វារីអគ្គិសនីរបស់ប្រទេសចិន និងទំនប់វារីអគ្គិសនីដៃទន្លេ។<br>១.២. ស្វែងយល់ពីលទ្ធភាពផ្តល់កញ្ចប់កែសម្រួលផ្នែករចនាសម្ព័ន្ធរួម ពីម្ចាស់ជំនួយ<br>១.៣. លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងធនធានទឹក និងធនធានធម្មជាតិ និងសេវាប្រព័ន្ធអេកូឡូស៊ី<br>១.៤. ជំរុញការវិនិយោគលើជម្រើសថាមពលកើតឡើងវិញ និង DSM នៅក្នុងប្រទេសតាមអាងទន្លេមេគង្គក្រោម<br>១.៥. រៀបចំប្លង់ជម្រើសសម្រាប់ការទាញយកថាមពលពីផ្លូវទឹកទន្លេមេគង្គ ដោយពុំចាំបាច់សាងសង់ទំនប់វារីអគ្គិសនីតាមដៃទន្លេទាំងមូល។ |
| | ២.១. ព្រមព្រៀងលើផែនទីបង្ហាញផ្លូវ ដែលមានចំណុចនៃការធ្វើសេចក្តីសម្រេចសម្រាប់ធ្វើការពិចារណាឡើងវិញថា "ត្រូវសាងសង់ ឬ មិនត្រូវសាងសង់ទំនប់វារីអគ្គិសនី"។<br>២.២. រៀបចំប្លង់ជម្រើស ដើម្បីទាញយកថាមពលទន្លេមេគង្គ ដោយពុំចាំបាច់សាងសង់ទំនប់វារីអគ្គិសនីនៅតាមដៃទន្លេទាំងមូល។<br>២.៣. កែលម្អប្លង់អនុវត្តការងារ សុវត្ថិភាព និងគ្រប់គ្រងផលប៉ះពាល់របស់គម្រោងដែលបានស្នើសុំ ដើម្បីអនុវត្តទៅតាមស្តង់ដារដែលបានព្រមព្រៀង។<br>២.៤. លើកកម្ពស់ប្រសិទ្ធភាពរបស់វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងការការពារសង្គមដែលបានព្រមព្រៀង។<br>២.៥. លើកកម្ពស់ការយល់ដឹងពីធនធានធម្មជាតិ សង្គម និងវប្បធម៌ នឹងដែនកំណត់របស់ធនធានទាំងនោះ ចំពោះការអភិវឌ្ឍប្រកបដោយនិរន្តរភាព។<br>២.៦. លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងធនធានទឹក និងធម្មជាតិព្រមទាំងសេវាប្រព័ន្ធអេកូឡូស៊ី។<br>២.៧. អភិវឌ្ឍសមត្ថភាពរបស់គ្រឹះស្ថានដែលមានស្រាប់ ដើម្បីគ្រប់គ្រង ពិនិត្យតាមដាន អនុវត្តច្បាប់សម្រាប់វារីអគ្គិសនី។<br>២.៨. បង្កើតគ្រឹះស្ថានថ្មីៗ ដើម្បីរៀបចំផែនការ និងគ្រប់គ្រងវារីអគ្គិសនីនាពេលអនាគត ដែលបានមកពីទន្លេមេនៃទន្លេមេគង្គ។<br>២.៩. រៀបចំយន្តការមូលនិធិតំបន់ទន្លេមេគង្គ។ |
| **៣ ការអភិវឌ្ឍជាបណ្តើរៗ**<br>ចាប់ផ្តើមដំណើរការដោយប្រុងប្រយ័ត្ន និងតាមការគ្រោងទុក (ជម្រើសសំខាន់ៗ ២)<br><br>**៣ក *គម្រោងបច្ចុប្បន្ន***<br>ប្រើប្រាស់គម្រោងដែលមានស្រាប់ជាមួយនឹងការសាងសង់ទំនបដែលបានស្នើទាំងអស់<br><br>**៣ខ *ជម្រើស***<br>ការប្រើប្រាស់ប្លង់ជម្រើសដែលមានទប់ទន្លេមេតែមួយផ្នែកប៉ុណ្ណោះ | ៣.១. រៀបចំផែនការតាមដំណាក់កាល សម្រាប់ទំនប់វារីអគ្គិសនីតាមទន្លេមេនៃទន្លេមេគង្គ ដែលបានសាងសង់រួមគ្នា :<br>៣.១.១. ការពិនិត្យតាមដានទូទៅនៃការសាងសង់ និងដំណើរការ សាងសង់ទំនប់វារីអគ្គិសនី។<br>៣.១.២. ការអនុវត្តច្បាប់។<br>៣.១.៣. ការរៀនសូត្រពីបទពិសោធន៍ ដែលបានរៀបចំ និងឱ្យបានទាន់ពេលវេលា។<br>៣.១.៤. ភាពបត់បែនក្នុងការអនុវត្ត ដែលមានសមត្ថភាពផ្លាស់ប្តូរផែនការអនុវត្តគម្រោង ទទួលយកគម្រោងជម្រើស។<br>៣.១.៥. ពិចារណាលើប្លង់ជម្រើស ដែលមានការសាងសង់ទំនប់វារីអគ្គិសនី<br>៣.២. អនុវត្តវិធានការខាងលើចំពោះផ្នែកទី ២ ប៉ុន្តែមានរយៈពេលកំណត់ខ្លីជាងមុន។ |
| **៤ ទីផ្សារ**<br>ការអភិវឌ្ឍគម្រោងវារីអគ្គិសនីដែលបានស្នើសុំ ដោយផ្អែកលើតម្រូវការទីផ្សារ | ៣.១. គម្រោងវារីអគ្គិសនីដែលបានស្នើឡើងៗ គួរត្រូវរៀបចំឡើង និងសាងសង់យ៉ាងលឿនបើក្រុមហ៊ុនអភិវឌ្ឍន៍ និងប្រទេសម្ចាស់គំរោងដែលជាអ្នកត្រួតពិនិត្យអាចធ្វើបាន ដើម្បី បំពេញតាមតម្រូវការទីផ្សារថាមពលអគ្គិសនី<br>៣.២. ពុំមានផែនការពិតប្រាកដទេ :<br>៤.២.១. ការពិនិត្យតាមដានទូទៅនៃការសាងសង់ និងដំណើរការសាងសង់ទំនប់វារីអគ្គិសនី<br>៤.២.២. ការអនុវត្តច្បាប់<br>៤.២.៣. ការរៀនសូត្រពីបទពិសោធន៍ តាមពេលដែលត្រូវការដោយមានពេលវេលាតិចតួច ដើម្បីដាក់បញ្ចូល និងឆ្លុះបញ្ចាំងទៅលើបទពិសោធន៍ដែលទទួលបាន<br>៤.២.៤. ភាពបទបែនតិចតួចក្នុងការអនុវត្ត និងសមត្ថភាពផ្លាស់ប្តូរផែនការ<br>៤.៣. អនុវត្តវិធានការខាងលើចំពោះផ្នែកទី ២ ប៉ុន្តែមានរយៈពេលកាន់តែខ្លី។ |

Formatted: Not Highlight

អនុសាសន៍ទូលំទូលាយសម្រាប់ជម្រើសយុទ្ធសាស្ត្រនីមួយៗ មានបញ្ចូលក្នុងរបាយការណ៍មេ ដើម្បីជួយផ្តល់ប្រឹក្សាដល់ប្រទេសទន្លេមេគង្គក្រោមលើមធ្យោបាយធ្វើសកម្មភាពអ្វីខ្លះដែលប្រទេសទាំងនោះសម្រេចជាចុងក្រោយទាក់ទងនឹងសំណើគម្រោងទំនប់វារីអគ្គិសនីទាំងអស់នេះ។

ដំណើរការការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន បានផ្តួចផ្តើមឡើងនៅក្នុងបរិបទមួយ ដែលភាគីពាក់ព័ន្ធមានគំនិតខុសៗគ្នាស្តីពីបញ្ហាអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី។ គំនិតខុសគ្នាទាំងនេះ ទំនងជាឆ្លុះបញ្ចាំងពីសិទ្ធិអំណាចតាមវិស័យរបស់ក្រសួង និងភ្នាក់ងារជំនាញ និងបេសកម្មរបស់អង្គការអន្តរជាតិ និងអង្គការក្នុងស្រុក។ ជាក់ស្តែង នៅពេលចូលរួមក្នុងសមាសភាពជាជំនាញការ មិនមែនជាមន្ត្រីរាជការ ឬមិនមែនជាអ្នកតំណាងអង្គភាពរបស់ខ្លួន ក្រុមជំនាញការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន រកឃើញថា មានមូលដ្ឋានរួមមួយចំនួនពីភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងដំណើរការប៉ាន់ប្រមាណ។ ក្នុងអំឡុងពេលនៃដំណើរការពិគ្រោះយោបល់រយៈពេល ១៦ខែ នៃកិច្ចប្រជុំទល់មុខគ្នា និងកិច្ចប្រជុំរួមជាមួយនឹងក្រសួងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធចំនួន ៦០ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៤០ នៅក្នុងប្រទេសទន្លេមេគង្គក្រោមនីមួយៗ នោះ ភាគីពាក់ព័ន្ធភាគច្រើន សំដែងពីការព្រួយបារម្ភអំពីផលប៉ះពាល់ពីគម្រោងស្នើឡើង ចង់ឃើញភស្តុតាងគួរឱ្យជឿជាក់ពីតម្រូវការសម្រាប់គម្រោងដែលបានស្នើឡើង ហើយយល់ថាការពិគ្រោះយោបល់ និងពិភាក្សាជាមួយនឹងរដ្ឋាភិបាលម្ចាស់គម្រោង និងសហគមន៍ប៉ះពាល់មិនទាន់បានធ្វើឱ្យបានគ្រប់គ្រាន់នៅឡើយ។ ភាគីពាក់ព័ន្ធដែលបានចូលរួមដំណើរការការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថានជាច្រើនយល់ថា អ្នកធ្វើការសម្រេចផ្នែកនយោបាយគប្បីពិចារណាត្រឹមត្រូវចំពោះជម្រើសយុទ្ធសាស្ត្រនៃការពន្យារពេលលើការសម្រេចក្នុងការអភិវឌ្ឍ វារីអគ្គិសនីរហូតដល់មានការកាត់បន្ថយនូវភាពមិនប្រាកដប្រជាសំខាន់ៗ មានការពិចារណាជិតដល់លើជម្រើសនានា និងមានការឯកភាពគ្នាលើវិធានការគ្រប់គ្រងហានិភ័យដោយសារការអភិវឌ្ឍ តាមរយៈដំណើរការរួមគ្នាទ្វេភាគី និងដឹកនាំដោយគណៈកម្មការទន្លេមេគង្គ។

លទ្ធផលរកឃើញ និងសេចក្តីសន្និដ្ឋានរបស់ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថានទាក់ទងនឹងហានិភ័យសំខាន់ៗ ភាពមិនប្រាកដប្រជា និងកង្វះខាតលើផ្នែកចំណេះដឹង ក៏ដូចជាទស្សនៈរួមរបស់ភាគីពាក់ព័ន្ធភាគច្រើនដែលបានចូលរួមក្នុងដំណើរការនៃការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថានស្តីពីតម្រូវការសម្រាប់ប្រឹក្សា និងសិក្សាបន្ថែមទៀត ធ្វើឱ្យក្រុមការងារធ្វើការប៉ាន់ប្រមាណរើសយកជម្រើសជាយុទ្ធសាស្ត្រទី២ដើម្បីផ្តល់ជាអនុសាសន៍៖ ការពន្យាពេលអភិវឌ្ឍទំនប់វារីអគ្គិសនីដោយមានខ្លឹមសារសង្ខេបដូចខាងក្រោម។

**អនុសាសន៍សំខាន់ៗរបស់ក្រុមជំនាញការធ្វើការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន**

បន្ទាប់ពីវិភាគពីផលប៉ះពាល់ដែលអាចកើតមាន និងផលប្រយោជន៍ពាក់ព័ន្ធនឹងគម្រោងទំនប់វារីអគ្គិសនីនេះ និងបន្ទាប់ពីមានកម្មវិធីពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយស្ថាប័នរដ្ឋាភិបាល និងទីភ្នាក់ងារមិនមែនរដ្ឋាភិបាលជាង ១០០ រួចមក ក្រុមជំនាញការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន សម្រេចដាក់ចេញអនុសាសន៍សំខាន់ៗលើចំណុចមួយចំនួនដូចខាងក្រោម :

- ដោយសារសារៈសំខាន់ផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងអេកូឡូស៊ីរបស់ទន្លេមេគង្គ ពីព្រោះប្រព័ន្ធលំហូរតាមបែបធម្មជាតិមានទំនាក់ទំនងនឹងប្រទេសទាំងបួននៅផ្នែកខាងក្រោមទន្លេមេគង្គ។
- ដោយសារស្ថានភាពគំរាមកំហែងចេះតែកើនឡើងនៃប្រព័ន្ធធម្មជាតិ និងធនធាននៅក្នុងតំបន់ និងសម្ពាធកាន់តែច្រើនឡើងលើប្រព័ន្ធធម្មជាតិ និងធនធានទាំងនោះ។
- ដោយសារឥទ្ធិពលដែលអាចកើតមានសំខាន់ៗ និងភាពមិនប្រាកដប្រជាដែលមានទំនាក់ទំនងនឹងគម្រោងទំនប់វារីអគ្គិសនី ដែលបានស្នើឡើង។
- ដោយសារតម្រូវការសម្រាប់វិធីសាស្ត្រថ្មីមួយនៃការអភិវឌ្ឍទន្លេមេគង្គដើម្បីបំពេញតម្រូវការកាន់តែប្រសើរឡើងរបស់ប្រទេសនៅទន្លេមេគង្គក្រោម និងសហគមន៍នៅជាប់ទន្លេក្នុងទស្សវត្សទី ២១ នេះ :

ក្រុមជំនាញការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ផ្តល់នូវអនុសាសន៍ដូចខាងក្រោម :

១. **គប្បីពន្យារពេលការសម្រេចលើការសាងសង់ទំនប់វារីអគ្គិសនីតាមដងទន្លេមេ រយៈពេល ១០ឆ្នាំ (ជម្រើសយុទ្ធសាស្ត្រទី២) ដោយមានការវាយតម្លៃនៅរៀងរាល់បីឆ្នាំម្តង ដើម្បីធានាថាសកម្មភាពចាំបាច់ក្នុងអំឡុងពេលពន្យារពេលនឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព។**

២. ដោយសារអាទិភាពខ្ពស់បំផុត អំឡុងពេលពន្យារពេលនេះ នឹងមានបញ្ចូលការអនុវត្តយ៉ាងទូលំទូលាយមួយនៃការសិក្សាគម្រោងលម្អិតពីសមិទ្ធិលទ្ធភាពលើការបង្វែរទឹកក្នុងផ្នែកខ្លះនៃដៃទន្លេ និងប្រព័ន្ធច្នៃប្រឌិតថ្មីៗ សម្រាប់ការទាញយកថាមពលពីទន្លេមេនៃទន្លេមេគង្គ ទៅតាមវិធីណាមួយដែលមិនចាំបាច់សង់ទំនប់វារីអគ្គិសនីកាត់ទទឹងទន្លេទាំងមូល។ ការងារនេះទាមទារឱ្យមានការចូលរួមពីរដ្ឋាភិបាលក្នុងភាពជាដៃគូជាមួយនឹងគណៈកម្មការទន្លេមេគង្គ ធនាគារអភិវឌ្ឍន៍ពហុភាគី និងក្រុមហ៊ុនអភិវឌ្ឍន៍។

៣. អំឡុងពេលពន្យារពេលនេះ ក៏គួរតែបញ្ចូលការវាយតម្លៃយ៉ាងទូលំទូលាយមួយ និងការតាមដានយ៉ាងឆាប់រហ័សលើគម្រោងប្រភពទឹក ដែលអាចធ្វើបាន និងមាននិរន្តភាពផ្នែកអេកូឡូស៊ី យោងតាមការអនុវត្តដ៏ល្អបំផុតជាលក្ខណៈអន្តរជាតិនាពេលបច្ចុប្បន្ន រួមទាំងការបន្ថែមបច្ចេកវិទ្យាទំនើបលើគម្រោងដែលមានស្រាប់ និងគម្រោងច្នៃប្រឌិតថ្មីៗ។

៤. អំឡុងពេលនៃការពន្យារនេះចាំបាច់ត្រូវចាប់ផ្តើមដោយមានការបែងចែកជាលក្ខខណៈប្រព័ន្ធនៃរបាយការណ៍នៃការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាននៅក្នុងប្រទេសទន្លេមេគង្គ

ក្រោមនីមួយៗជាភាសាជាតិ និងមានការពិគ្រោះយោបល់ជាមួយនឹងភ្នាក់ងារជំនាញក្រសួងពាក់ព័ន្ធនៅតាមប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។

៥. **មិនគួរយកទន្លេមេនៃទន្លេមេគង្គមកប្រើប្រាស់ធ្វើជាករណីសាកល្បងសម្រាប់បង្ហាញពីប្រសិទ្ធភាព និងកែលម្អបច្ចេកវិទ្យាវារីអគ្គិសនីទំនប់ទាំងមូលទេ។**

### ជំហានបន្ទាប់ដែលត្រូវអនុវត្តជាបន្ទាន់

នៅឯសិក្ខាសាលាបូកសរុបប្រចាំតំបន់នៃដំណើរការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ការពិភាក្សាថ្នាក់ជាតិបានផ្តល់អនុសាសន៍ស្តីពីអ្វីដែលនឹងត្រូវបញ្ចូលក្នុងរបាយការណ៍បូកសរុប នៃការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន នៅពេលត្រូវបញ្ជូនទៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។ អនុសាសន៍ស្តីពីដំណើរការនៅជំហានបន្ទាប់ ពិតជាមានភាពស៊ីសង្វាក់គ្នាពីក្រុមមួយទៅក្រុមមួយទៀត។ គោលបំណងរួម គឺដើម្បីធានាថាការពិគ្រោះយោបល់ជាយុទ្ធសាស្ត្រស្តីពីរបាយការណ៍នៃការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ត្រូវតែធ្វើឡើងនៅក្នុងប្រទេសនីមួយៗ មុនពេលធ្វើសេចក្តីសម្រេចលើគម្រោងជាក់លាក់ណាមួយ។

សរុបមក ជាអនុសាសន៍គឺថា គួរតែផ្សព្វផ្សាយជាលក្ខណៈប្រព័ន្ធនូវរបាយការណ៍នៃការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន ជាភាសាជាតិក្នុងប្រទេសនីមួយៗនៅទន្លេមេគង្គក្រោម ហើយគួរតែមានផ្តល់ជំនួយ ដើម្បីសម្របសម្រួលដល់ការពិគ្រោះយោបល់លើរបាយការណ៍នេះជាមួយនឹងក្រសួងស្ថាប័ន និងទីភ្នាក់ងារពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល មុនពេលធ្វើសេចក្តីសម្រេចលើគម្រោងទំនប់វារីអគ្គិសនីណាមួយ។ ក្រុមការងារថ្នាក់ជាតិបានលើកឡើងពីជំហានមួយចំនួននៅក្នុងដំណើរការនេះ ដើម្បីបង្កើនផលប្រយោជន៍របស់របាយការណ៍នៃការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាននេះទៅ ដល់ប្រទេសនៅតាមទន្លេមេគង្គក្រោម ដោយរួមមានដូចជា:

- ការពិចារណាលើរបាយការណ៍នេះ ដោយគណៈកម្មាធិការចម្រុះរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
- ការពិចារណាលើរបាយការណ៍នេះ ដោយគណៈកម្មាធិការជាតិទន្លេមេគង្គ។
- ការពិគ្រោះយោបល់បច្ចេកទេសបន្ថែមទៀតលើរបាយការណ៍នេះជាមួយនឹងក្រសួង ស្ថាប័ន និងភ្នាក់ងារពាក់ព័ន្ធក្នុងប្រទេសនីមួយៗ។
- ការពិចារណាលើរបាយការណ៍នេះ ដោយគណៈរដ្ឋមន្ត្រីជាតិ
- ការពិចារណាលើរបាយការណ៍នេះ ដោយគណៈកម្មាធិការព្រឹទ្ធសភាផ្នែកធនធានធម្មជាតិ និងបរិស្ថាន
- កោះប្រជុំពហុភាគីពាក់ព័ន្ធនៅក្នុងប្រទេសនីមួយៗ និងនៅថ្នាក់តំបន់ ដើម្បីពិភាក្សាពីរបាយការណ៍នេះ

- បង្កើតក្រុមការងារបច្ចេកទេសប្រចាំតំបន់ស្តីពីបញ្ហាយុទ្ធសាស្ត្រសំខាន់ៗ ប្រសិនបើនៅមានភាពមិនប្រាកដប្រជា និងហានិភ័យធ្ងន់ធ្ងរ។

អនុសាសន៍នានារបស់ក្រុមជំនាញការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាននេះ កើតចេញពីការទទួលស្គាល់តម្រូវការឱ្យមានការប្រុងប្រយ័ត្នខ្ពស់បំផុតក្នុងការសម្រេចចិត្តលើការអភិវឌ្ឍ នៅពេលដែលការសម្រេចនោះ ប្រឈមនឹងគ្រោះថ្នាក់ នៅពេលមានការគំរាមកំហែងច្បាស់លាស់ និងការខូចខាតផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ចមិនអាចស្តារឡើងវិញបានដោយសារគម្រោងទំនប់វារីអគ្គិសនីដែលបានស្នើឡើង។ ជានិច្ចកាល ការសម្រេចលើការអភិវឌ្ឍសំខាន់ៗពាក់ព័ន្ធនឹងការថ្លឹងថ្លែង ពីការចំណេញ ខាតបង់ និងការផ្លាស់ប្តូរ។ គោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពចាំបាច់ត្រូវធានាថា ការថ្លឹងថ្លែងពីចំណេញ ខាតបង់ និងការផ្លាស់ប្តូរ នឹងមិនបង្កឱ្យមានការខូចខាតជារៀងរហូត មិនបញ្ចប់ជម្រើសសម្រាប់មនុស្សជំនាន់ក្រោយ និងមិនមានការបែងចែកមិនស្មើគ្នានូវចំណាយ និងផលប្រយោជន៍ក្នុងចំណោមសហគមន៍ និងតំបន់នៅតាមទីតាំងនៃគម្រោង។ នៅក្នុងចំណោមសំណើគម្រោងទំនប់វារីអគ្គិសនីទាំង១២ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាន រកឃើញថាការខូចខាតជារៀងរហូត នឹងអាចកើតមាន ហើយបើទោះបីជាមានវិធានការបញ្ចៀស និងកាត់បន្ថយការខូចខាតក៏ដោយ ក៏នៅតែមានកង្វះខាតយ៉ាងធ្ងន់ធ្ងរលើផ្នែកចំណេះដឹង ហើយសមត្ថភាពរបស់ស្ថាប័ននៅមិនគ្រប់គ្រាន់ ដើម្បីអនុវត្ត និងពង្រឹងវិធានការទាំងនេះឱ្យមានប្រសិទ្ធភាពដែរ។ សំខាន់ជាងនេះទៀត ភស្តុតាងបង្ហាញថា ជម្រើសនៃការទាញយកថាមពលដោយពុំចាំបាច់សាងសង់ទំនប់វារីអគ្គិសនីពេញទន្លេមេទាំងមូល និងជម្រើសតាមដៃទន្លេផ្សេងៗទៀត មិនទាន់ត្រូវបានលើកយកមកពិចារណាឱ្យគ្រប់ជ្រុងជ្រោយនៅឡើយទេ។

យើងត្រូវការពេលវេលាបន្ថែមទៀត ដើម្បីបង្កើនការយល់ដឹង និងសមត្ថភាពកាន់តែល្អ ដើម្បីស្វែងយល់ពីជម្រើសផ្សេងៗឱ្យបានកាន់តែប្រសើរ និងដើម្បីអង្កេតពីមធ្យោបាយផ្សេងៗ ដើម្បីជៀសវាងការខូចខាតដែលអាចប៉ះពាល់ដល់សុខុមាលភាពថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។